# ចាប់ផ្ដើមជីវិតថ្មីជាមួយព្រះយេស៊ូវគ្រិស្ត

# BEGINNING A NEW LIFE
# IN CHRIST

# សេចក្ដីពិតខាងវិញ្ញាណ

# SPRIRITUAL TRUTHS

| | | |
|---|---|---|
| First Printing | 4,000 copies | February 2004 |
| Second Printing | 2,000 copies | September 2009 |
| Third Printing | 2,000 copies | September 2010 |

© រក្សាសិទ្ធិដោយ*ព្រះបន្ទូលនៃជីវិត*, ឆ្នាំ ២០០៤, ២០០៩, ២០១០

A Training Book of
***Words of Life Ministries and***
***Antioch Institute***

យើងខ្ញុំទទួលស្វាគមន៍មតិរិះគន់ស្ថាបនា និងយោបល់ផ្សេងៗពីលោកអ្នក។ ប្រសិនបើលោកអ្នកឃើញមានកំហុសណាមួយក្នុងសៀវភៅ សូមទំនាក់ទំនងយើងខ្ញុំតាមរយៈប្រអប់សំបុត្រ ២៥៨១ ភ្នំពេញ ៣ ឬតាមអ៊ីមែលៈ info@asiaforjesus.com សូមអរគុណ!

# មាតិកា

## Table of Contents


| | |
|---|---|
| មេរៀនទី១: ការយាងមកលើកទីមួយ និងការវិលមកវិញរបស់ព្រះគ្រិស្ត | ៧ |
| មេរៀនទី១: សេចក្តីពិតខាងវិញ្ញាណ | ១៣ |
| មេរៀនទី២: ការធ្វើដំណើររបស់ព្រះគ្រិស្តទៅកាន់ប្រទេសអេស៊ីព្ទ និងការជ្រមុជទឹក | ១៧ |
| មេរៀនទី២: សេចក្តីពិតខាងវិញ្ញាណ | ២៣ |
| មេរៀនទី៣: ការល្បួងព្រះយេស៊ូគ្រិស្ត | ២៧ |
| មេរៀនទី៣: សេចក្តីពិតខាងវិញ្ញាណ | ៣១ |
| មេរៀនទី៤: ការដកសេចក្តីភ័យខ្លាចចេញពីអ្នកនេសាទមនុស្ស | ៣៧ |
| មេរៀនទី៤: សេចក្តីពិតខាងវិញ្ញាណ | ៤៣ |
| មេរៀនទី៥: សេចក្តីស្រឡាញ់ជាអត្ថន័យនៃការងាររបស់ព្រះគ្រិស្ត នៅលើផែនដី | ៤៩ |
| មេរៀនទី៥: សេចក្តីពិតខាងវិញ្ញាណ | ៥៥ |
| មេរៀនទី៦: អំពើក្បត់ និងការលើកលែងទោស | ៦១ |
| មេរៀនទី៦: សេចក្តីពិតខាងវិញ្ញាណ | ៦៧ |
| មេរៀនទី៧: ព្រះយេស៊ូគ្រិស្តនៅលើឈើឆ្កាង | ៧៣ |
| មេរៀនទី៧: សេចក្តីពិតខាងវិញ្ញាណ | ៧៩ |
| មេរៀនទី៨: ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រិស្ត | ៨៣ |
| មេរៀនទី៨: សេចក្តីពិតខាងវិញ្ញាណ | ៨៧ |

# របៀបប្រើសៀវភៅរឿងដំណឹងល្អអំពីព្រះយេស៊ូ
# និង
# សៀវភៅចាប់ផ្ដើមជីវិតថ្មីជាមួយព្រះគ្រិស្ដ

១- ចាប់ផ្ដើមការប្រជុំគ្នាដោយមានការអធិស្ឋានខ្លីមួយ ដើម្បីសុំឱ្យល់រឿង។

២- អានរឿងទៅអ្នកដែលចូលរួម ឬក៏អានទាំងអស់គ្នា។

៣- អ្នកដឹកនាំគួរតែសួរសំនួរផ្ទាល់មាត់នៅពេលបញ្ចប់រឿង។ គោលបំណងនៃសំណួរ គឺពិនិត្យទៅលើការយល់ដឹងអំពីរឿង មិនមែនសម្រាប់ពិភាក្សាទេ។

៤- អាននូវសេចក្ដីពិតផ្នែកព្រលឹងវិញ្ញាណ។ អនុញ្ញាតិឱ្យសមាជិកមានសេរីភាពក្នុងការពិភាក្សាក្នុងសេចក្ដីពិតនីមួយៗ។ តែសូមឱ្យប្រុងប្រយ័ត្ន មិនត្រូវប្រកែកគ្នាឡើយ។ គឺគ្រាន់តែគេយល់នូវសេចក្ដីទាំងនោះ។

៥- ទុកពេលឱ្យមានការចែកចាយនូវសំណូមអធិស្ឋានជាក្រុម។

៦- អធិស្ឋានយ៉ាងជាក់លាក់សម្រាប់តម្រូវការនីមួយៗនៅក្នុងក្រុម។

# មេរៀនទី១

## ការយាងមកលើកទីមួយ និងការវិលមកវិញរបស់ព្រះគ្រិស្ត

ម៉ាថាយ ១ និង ២៤

*«ដូច្នេះ ចូរប្រុងស្មារតីឱ្យមែនទែន ដ្បិតអ្នករាល់គ្នាពុំដឹងថា ព្រះអម្ចាស់របស់អ្នករាល់គ្នានឹងមកដល់នៅពេលណាឡើយ ។ ដូច្នេះ អ្នករាល់គ្នាត្រូវត្រៀមខ្លួនជានិច្ច ដ្បិតបុត្រមនុស្សនឹងមកដល់នៅវេលាណាដែលអ្នករាល់គ្នាពុំបានគិត »* (ម៉ាថាយ ២៤:៤២, ៤៤)។

*** បើអាចសំណូមពរឱ្យសិស្សយកក្រដាស់ និងប៊ិចមកជាមួយ**

នៅក្នុងសម័យដែលរ៉ូមបានត្រួតត្រាប្រទេសអ៊ីស្រាអែល នោះមានស្ត្រីក្រមុំម្នាក់ឈ្មោះមារាដែលបានភ្ជាប់ពាក្យជាមួយបុរសម្នាក់ឈ្មោះយូសែប ។ ក្រោយមកនាងមារាក៏មានផ្ទៃពោះមុនពេលដែលពួកគេបានរៀបការ ហើយក្រោយពេលដែលយូសែបបានដឹងរឿងនោះគាត់ក៏ចង់ផ្តាច់ពាក្យជាមួយនិងនាងម៉ារា។ ដូច្នេះហើយមានយប់មួយនោះគាត់បានសម្រេចចិត្តនឹងលះលែងជាមួយ និងនាងមារាដោយសម្ងាត់ដោយព្រោះគាត់មិនចង់ឱ្យនាងបាក់មុខ។

នៅពេលដែលគាត់កំពុងតែគិតនោះក៏ស្រាប់តែមានទេវតានៃព្រះបានលេចមកឯគាត់ហើយទេវតាក៏បានប្រាប់គាត់ឱ្យទៅរៀបការជាមួយនឹងនាងមារា ព្រោះនាងមិនបានក្បត់ចិត្តគាត់ឡើយគឺនាងមានផ្ទៃពោះដោយសារព្រះវិញ្ញាណបរិសុទ្ធទេ។ ទេវតាក៏បានប្រាប់ទៅយូសែបទៀតថា នាងម៉ារានឹងប្រសូតបុត្រមួយទៅតាមទំនាយរបស់ព្យាការីជនជាតិយូដាឈ្មោះអេសាយដែលគាត់បាននិយាយថា «ឱស្ត្រីព្រហ្មចារីនឹងមានគត៌ហើយប្រសូតបានបុត្រាមួយអង្គថ្វាយព្រះនាមថា **អេម៉ាញូអែល** ដែលប្រែថា «**ព្រះអង្គទ្រង់គង់ជាមួយ**»។

ដូច្នេះហើយយូសែបបានជឿគ្រប់ទាំងអ្វីដែលទេវតាបានប្រាប់រួចក៏យកមារាធ្វើជាភរិយា ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ពួកគេមិនបាន មានទំនាក់ទំនងផ្លូវភេទជាមួយគ្នាទាល់តែទារកនោះបានកើតមកចាប់កំណើត ហើយគេក៏ដាក់ឱ្យព្រះនាម

ដល់ទារកតូចនោះហៅថា «*យេស៊ូ*»។

នៅ ក្នុង ព្រះគម្ពីរ មាន ការ ទស្សន៍ទាយ ជា ច្រើន អំពី ការ យាង មកវិញ របស់ព្រះយេស៊ូគ្រិស្ត ។ ទាំងការប្រសូតក៏ដូចជាការដែលគេឆ្កាងព្រះអង្គ និងការដែលទ្រង់មានព្រះជន្មរស់ឡើងវិញ សុទ្ធតែមាននៅក្នុងទំនាយសញ្ញាចាស់ ។ ព្រះយេស៊ូខ្លួនឯងក៏បានមានព្រះបន្ទូលជាច្រើនដែលទាក់ទងទៅនឹងថា ទ្រង់ជាអ្នកណាហើយមកពីណា ។ តែក៏មានសេចក្តី ទំនាយខ្លះនៅក្នុងគម្ពីរសញ្ញាថ្មីដែលមិនទាន់បានសម្រេចដែរ ។ ដែលសេចក្តីទំនាយនោះបានប្រាប់យើងថា ព្រះយេស៊ូនឹងយាងមកផែនដីម្តងទៀត ។ ការដែលទ្រង់យាងមកជាលើកទីមួយនោះគឺមកក្នុងឋានៈជាអ្នកដែល ទាប ថោក ប៉ុន្តែការដែលទ្រង់យាងមកលើកទីពីរនេះ នឹង មានការ ខុស ប្លែក ពីមុន ។

ព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់អ្នកដែលដើរតាមទ្រង់អំពីការដែលទ្រង់នឹងយាងមកវិញ ក្នុងពេលដែលទ្រង់កំពុងបង្រៀនគេនៅលើភ្នំអូលីវ ហើយក៏ជាការដែលឆ្លើយតបទៅនឹងការចោទសួរថា៖ «តើអ្វីទៅដែលជាសញ្ញានៃការយាងត្រលប់មកវិញរបស់ទ្រង់នៅគ្រាចុងក្រោយបង្អស់»? ព្រះគ្រិស្តបានឆ្លើយទៅគេជាមួយនឹងការព្រមានដោយទ្រង់បានប្រាប់យើងឱ្យមានការប្រុងប្រយ័ត្ន ដើម្បីកុំឱ្យមានអ្នកណាមកបោកប្រាស់យើងបាន ។ ហើយទ្រង់ក៏មានព្រះបន្ទូលទៀតថា នៅពេលដែលការយាងមកវិញរបស់ទ្រង់ជិតកៀកមកដល់ នោះនឹងមានមនុស្សជាច្រើនប្រើឈ្មោះរបស់ទ្រង់ដើម្បីបោកប្រាស់ដល់អ្នកដទៃ ។

ពួកគេនឹងនិយាយថា «ខ្ញុំជាព្រះគ្រិស្ត» ដែលគួរឱ្យស្តាយ គឺមានមនុស្សជាច្រើនបានជឿលើហោរាក្លែងក្លាយទាំងនោះនិងទៅតាមហោរាក្លែងក្លាយទាំងអស់នោះ ។ ហើយនៅពេលនោះផងដែរក៏មានជម្លោះសង្គ្រាមច្រើនកើតឡើងនៅក្នុងចំណោមមនុស្ស ឬជាតិសាសន៍ផ្សេង «នៅក្នុងពិភពលោក ។ព្រមទាំងមានភាពចលាចលយ៉ាងខ្លាំងដូចជា គ្រោះធម្មជាតិជំងឺនិងរញ្ជួយផែនដីជាដើម ប៉ុន្តែការទាំងអស់នោះគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះគឺនឹងមានការឈឺចាប់ជាច្រើនជាងនេះទៅទៀតនៅពេលដែលជិតចុងបំផុតនៃផែនដី ។

មនុស្សគេនឹងក្បត់គ្នាទៅវិញទៅមក ហើយនឹងសម្លាប់គ្នា ។ គេនឹង ស្អប់គ្នាដោយសំអាងលើសេចក្តីជំនឿរបស់គេចំពោះព្រះគ្រិស្ត ។ ការមិនគោរពច្បាប់នឹងរីកចម្រើនច្រើនឡើងៗ ហើយសេចក្តីស្រឡាញ់រវាងមនុស្សនិងមនុស្សនឹងបាត់បង់ ។

ប៉ុន្តែទោះបីការទាំងនេះកើតឡើងយ៉ាងណាក៏ដោយ ក៏ដំណឹងល្អរបស់ព្រះគ្រិស្តនៅតែបន្តចែកចាយទៅដល់គ្រប់ប្រជាជាតិទាំងអស់បានឮ នោះទើបដល់ថ្ងៃចុងបំផុត។

នោះនឹងមានការពិបាក ឬការច្រួលច្របល់កើតឡើងទូទាំងពិភពលោក ដូច្នេះហើយកុំជឿហោរាក្លែងក្លាយ និងគ្រិស្តបរិស័ទក្លែងក្លាយដែលដើរពីកន្លែងមួយទៅកន្លែងមួយដើម្បីធ្វើការអស្ចារ្យជាច្រើននោះ។ ពួកទាំងនោះគ្រាន់តែព្យាយាមដើម្បីបោកប្រាសគ្រប់មនុស្ស ជាពិសេសអស់អ្នកដែលជឿដល់ព្រះយេស៊ូ។ ហើយ ចង់ឱ្យមនុស្សនៅតែបន្តធ្វើនូវអ្វីដែលខ្លួនចង់ធ្វើ គឺយើងនឹងមើលឃើញតែប្រយោជន៍ផ្ទាល់ខ្លួន ហើយគ្រិស្តបរិស័ទជាច្រើននឹងបោះបង់ចោលសេចក្តីជំនឿ។ ព្រះជាម្ចាស់នឹងធ្វើឱ្យថ្ងៃនៃដ៏អាក្រក់ និងវេទនានោះមានរយៈពេលខ្លី។

ដូច្នេះសូមកុំជឿលើហោរាក្លែងក្លាយ និងព្រះគ្រិស្តក្លែងក្លាយ។ ពួកគេនឹងធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទៀតដើម្បីធ្វើទីសំគាល់ និងការអស្ចារ្យជាច្រើន។ ពួកគេទាំងនេះគឺគ្រាន់តែព្យាយាមដើម្បីបោកបញ្ឆោតមនុស្សតែប៉ុណ្ណោះ។ ពួកគេខ្លះអាចជាអ្នកដែលបានថ្វាយជីវិតខ្លួនដល់ព្រះគ្រិស្តហើយ។ ប៉ុន្តែ ថ្ងៃមួយនៅពេលដែលមានផ្លេកបន្ទោរពីទិសខាងកើតទៅទិសខាងលិចនោះកូនមនុស្សនឹងយាងមក។ បន្ទាប់ពីភាពចលាចល នោះព្រះអាទិត្យនឹងទៅជាងងឹតព្រះច័ន្ទនឹងគ្មានពន្លឺ ផ្កាយនឹងធ្លាក់ចុះមកពីលើមេឃ ហើយអំណាចនៃស្ថានសួគ៌នឹងត្រូវរង្គើរនោះសញ្ញានៃកូនមនុស្សនឹងលេចឡើងនៅលើស្ថានសួគ៌ ហើយនឹងមានគ្រប់ជាតិសាសន៍ឬកុលសម្ព័ន្ធនៅលើពិភពលោកនេះនឹងស្រែកឡើង នោះគេនឹងឃើញកូនមនុស្សយាងមកនៅលើពពកជាមួយនឹងអំណាចដ៏អស្ចារ្យ។ ទ្រង់នឹងបញ្ជូនទេវតារបស់ទ្រង់ជាមួយនិងសម្លេងផ្លុំត្រែ ហើយអស់អ្នកដែលជឿដល់ព្រះគ្រិស្តនឹងមកប្រជុំគ្នា។ ប៉ុន្តែសួរថាពេលណាដែលព្រះគ្រិស្តនឹងយាងមក គឺគ្មាននណាម្នាក់ដឹងទេ សូម្បីតែទេវតាក៏មិនដឹងដែរ លើកលែងតែព្រះវរបិតា «ឱដូច្នេះឱ្យអ្នករាល់គ្នាប្រុងប្រៀបខ្លួនជាស្រេចដែរ ដ្បិតកូនមនុស្សនឹងមកនៅវេលាណាដែលអ្នករាល់គ្នាមិនគិត»។

## សំណួរផ្ទាល់មាត់

១- តើព្រះយេស៊ូបានកើតនៅប្រទេសណា?

២- តើម្ដាយឪពុកនៅលើផែនដីរបស់ព្រះយេស៊ូមានឈ្មោះអ្វី?

៣- តើមានអព្ភូតហេតុអស្ចារ្យអ្វីក្នុងការយាងមកលើកទីមួយរបស់ព្រះគ្រិស្ត?

៤- ព្យាការីអេសាយបានទស្សន៍ទាយថាព្រះគ្រិស្តនឹងប្រសូត្រចេញពីស្ត្រីព្រហ្មចារី ហើយនិងត្រូវបានគេហៅថា អេម៉ាញូអែលដែលមានន័យថា____________

៥- ព្រះគ្រិស្តបានប្រាប់ទៅអ្នកដែលដើរតាមទ្រង់ឱ្យមានការប្រុងប្រយ័តក្នុងការបោកប្រាស់របស់មនុស្សប្រភេទណា?

៦- នៅពេលដែលព្រះយេស៊ូបង្រៀននៅលើភ្នំអូលីវនោះ តើសំណួរអ្វី ដែល សិស្សបានសួរទៅទ្រង់?

៧- ទ្រង់បានមានព្រះបន្ទូលថាមានមនុស្សជាច្រើននឹងប្រកាសខ្លួនថាជាអ្នកណា?

៨- ព្រះយេស៊ូបានលើកនូវហេតុការណ៍អាក្រក់បួនយ៉ាងដែលកើតមានឡើងមុនពេលដែលទ្រង់យាងមកតើជាហេតុការណ៍អាក្រក់អ្វីខ្លះ?

ក____________________ ខ____________________

គ____________________ ឃ____________________

៩- ព្រះយេស៊ូបានមានព្រះបន្ទូលថា អ្នកដើរតាមទ្រង់នឹងត្រូវឈឺចាប់ដោយសារតែគេបានជឿដល់ទ្រង់។ តើមានអ្វីទៀតដែលព្រះគ្រិស្តបានមានព្រះបន្ទូលឱ្យអ្ន ក ដែលដើរតាមទ្រង់ធ្វើទៅកាន់គ្នាទៅវិញទៅមក?

១០-ព្រះយេស៊ូមានព្រះបន្ទូលថា ព្យាការីក្លែងក្លាយនឹងមានអំណាចធ្វើអ្វីដែលសូម្បីតែគ្រិស្តបរិស័ទក៏មានការភ័ណ្ឌច្រឡំដែរ?

១១-ព្រះយេស៊ូបានមានព្រះបន្ទូលថា ការយាងមករបស់ទ្រង់នឹងដូចជាហេតុការណ៍អ្វីនៅក្នុងធម្មជាតិ?

១២-តើនឹងមានការអ្វីកើតឡើងចំពោះព្រះអាទិត្យព្រះច័ន្ទ និងផ្កាយនៅពេលដែលព្រះយេស៊ូយាងមកលើកទីពីរ?

១៣-តើប្រភេទឧបករណ៍ភ្លេងអ្វីដែលទេវតានឹងយកមកប្រគុំក្នុងការដែលហៅប្រជុំអស់អ្នកដែលជឿព្រះគ្រិស្ត?

១៤-តើវាស្ត្ររបស់ព្រះនឹងប្រជុំគ្នានៅកន្លែងណា ?

១៥-អ្នកណាជាអ្នកដឹងថាព្រះគ្រីស្ទនឹងយាងមកនៅពេលណា ?

១៦-តើមានប្រតិកម្មយ៉ាងដូចម្ដេចនៅពេលដែលមាននណាម្នាក់បានធ្វើការអស្ចារ្យ ដែលមិននៅក្នុងព្រះនាមព្រះគ្រិស្ត ឬក៏អះអាងថា រូបគេជាព្រះគ្រិស្ត ?

## មេរៀនទី១

# សេចក្ដីពិតខាងវិញ្ញាណ

ម៉ាថាយ ១ និង ២៤

១- ព្រះគ្រិស្តទ្រង់នឹងយាងមកម្ដងទៀតជាមួយនិងអំណាច និងសិរីរុងរឿងរបស់ទ្រង់ ដូចដែលទ្រង់បានយាងមកលើកទីមួយ ដើម្បីសម្រេចនូវសេចក្ដីទំនាយរបស់ពួកព្យាការី ។ មានសាសនាក្លែងក្លាយ ព្យាការីក្លែងក្លាយ និងមនុស្សដែលប្រកាសថាខ្លួនជាព្រះជាច្រើន។ នៅពេលដែលព្រះយេស៊ូយាងមកម្ដងទៀតនឹងមិនមានការសង្ស័យទៀតថា ទ្រង់ជានរណាទេ។ ព្រះគម្ពីរបានចែងថា ពេលនោះគ្រប់ជង្គង់ទាំងអស់នឹងលុតក្រាបអណ្ដាតទាំងអស់ថ្លែងប្រាប់ថា ព្រះយេស៊ូគ្រិស្តជាព្រះ។ អស់អ្នកណាដែលមកឯយើងហើយប្រកាសថា ជាព្យាការីថ្មីជាព្រះគ្រិស្ត គឺជាព្យាការីក្លែងក្លាយ និងជាអ្នកកុហកបោកប្រាស។

២- ទ្រង់នឹងប្រមូលប្រជារាស្ត្ររបស់ទ្រង់ពីចុងនៃស្ថានសួគ៌ម្ខាងទៅចុងស្ថានសួគ៌ម្ខាង។

* ព្រះគ្រិស្តសន្យាថា ទ្រង់នឹងយាងត្រលប់មកវិញ គឺទ្រង់ពិតជាយាងមកវិញមែន។ ទ្រង់សន្យាថាទ្រង់នឹងប្រមូលប្រជារាស្ត្ររបស់ព្រះអង្គ ទ្រង់ពិតជាធ្វើ។

* នៅពេលដែលយើងយាងព្រះយេស៊ូមកគង់នៅក្នុងជីវិត នៅពេលដែលយើងប្រគល់ដួងចិត្តរបស់យើងដល់ព្រះអង្គ ទ្រង់សន្យាថា ទ្រង់នឹងមិនដែលចាកចោលយើងឬបោះបង់យើងចោលទេ។ ទីនេះបានន័យថា ទោះបីយើងមានអំពើបាបយ៉ាងណាក៏ដោយ (យើងពិតជាមានបាប) គឺព្រះទ្រង់ស្មោះត្រង់នឹងរក្សាសេចក្ដីសន្យារបស់ទ្រង់។ វាមិនជាបញ្ហាអ្វីទេ ទោះជាមានអ្វីកើតឡើងចំពោះយើង ឬក៏អ្វីដែលយើងធ្វើយ៉ាងណាក៏ដោយ ប្រសិនបើយើងបានប្រគល់ជីវិតរបស់យើងដល់ព្រះយេស៊ូទ្រង់នឹងយកយើងទៅឯស្ថានសួគ៌ជាមួយព្រះអង្គ ហើយនៅពេលដែលទ្រង់យាងត្រលប់មកវិញយើងនឹងជួបទ្រង់នៅលើពពក។

៣-វាស្ត្ររបស់ព្រះជាម្ចាស់នឹងមានការឈឺចាប់ដោយសារគេដើរតាមទ្រង់។ ព្រះគម្ពីរបង្រៀនយើងថា នៅពេលដែលពិភពលោកឈានជិតដល់ចុងបំផុតនោះ មនុស្សលោកនឹងអាក្រក់ទៅៗ។ ពួកគេពោរពេញទៅដោយសេចក្ដីសំអប់គ្នា សម្លាប់ និងក្បត់គ្នាទៅវិញទៅមកថែមទៀត។ ព្រះគម្ពីរបានចែងថា នឹងមានមនុស្សជាច្រើនស្អប់អ្នកដែលដើរតាមព្រះយេស៊ូ។ ប្រហែលជាលោកអ្នកធ្លាប់មានបទពិសោធន៍រួចមកហើយ ពីការដែលអ្នកដ៏ទៃបៀតបៀនអ្នក ដោយសារតែអ្នកបានសម្រេចចិត្តដើរតាមព្រះយេស៊ូ ។ តើអត្តចរិតអស់អ្នកដែលនៅជុំវិញអ្នកមានការផ្លាស់ប្ដូរយ៉ាងណា នៅពេលដែលអ្នកបានយាងព្រះយេស៊ូមកគង់នៅក្នុងជីវិតរបស់អ្នក? តើអ្នកដែលមានការស្និទ្ធស្នាលដូចជា មិត្តភក្ដិ ក្រុមគ្រួសារមានការបៀតបៀនអ្នកដែរឬទេ នៅពេលដែលអ្នកបានសំរេចចិត្តដើរតាមព្រះយេស៊ូ?

ព្រះគម្ពីរបង្រៀនយើងថា យើងត្រូវស្រឡាញ់អ្នកទាំងនោះ (ម៉ាថាយ ៥:៤៣-៤៨) ត្រូវតែស្រឡាញ់អ្នកដែលស្អប់យើង និងអ្នកដែលធ្វើឱ្យយើងឈឺចាប់ យើងត្រូវតែស្រឡាញ់គេ និងអធិស្ឋានឱ្យគេ។ នេះជាអ្វីដែលព្រះយេស៊ូធ្វើជាមួយអស់អ្នកដែលធ្វើទុក្ខព្រះអង្គ និងអ្នកដែលបញ្ជូនទ្រង់។ ហើយដើម្បី ធ្វើជាអ្នកដើរតាមព្រះយេស៊ូគ្រិស្ដ គឺត្រូវដើរតាមគំរូនៃសេចក្ដីស្រឡាញ់របស់ទ្រង់ ។ ព្រះគម្ពីរ ក៏បានបង្រៀនយើងផងដែរថា នឹងមានព្រះពរដ៏ពិសេសសម្រាប់អស់ដែលឈឺចាប់ ឬអស់អ្នកដែលត្រូវគេបៀតបៀនដោយព្រោះតែដើរតាមព្រះគ្រិស្ដ។

វាជាការពិត ព្រះគម្ពីរបានប្រាប់យើងថា ចូររាប់វាជាសេចក្ដីអំណរ ព្រោះនៅថ្ងៃណាមួយនឹងមានការបង់ថ្លៃចំពោះការនោះ។

* សូមឱ្យយើងម្នាក់ៗនៅក្នុងក្រុមនេះចែកចាយបទពិសោធន៍អំពីអ្វីដែលកើតមានចំពោះអ្នក តាំងពីអ្នកបានទទួលជឿព្រះយេស៊ូគ្រិស្ដ។ សង្ឃឹមថានេះជារឿងដ៏ល្អមួយ ប៉ុន្តែ ប្រហែលជាវាមិនអញ្ចឹងទេមើលទៅ។ តើមានអ្នកណាធ្លាប់ទទួលការឈឺចាប់ដោយសារបានទទួលព្រះយេស៊ូគ្រិស្ដទេ? សូមឱ្យយើងអធិស្ឋានឱ្យអ្នកទាំងនោះ។

* ប៉ុន្តែមុនពេលដែលយើងអធិស្ឋាន សូម ឱ្យអស់អ្នកដែលមានសៀវភៅកត់ត្រា ហើយកត់ឈ្មោះសមាជិកម្នាក់ៗនៅក្នុងក្រុមនៅក្នុងបញ្ជីអធិស្ឋាន ។ នៅក្រោមឈ្មោះនីមួយៗយើងសរសេរនូវសំណូមអធិស្ឋាន។ ហើយសូមឱ្យយើងចងចាំឈ្មោះអស់អ្នកដែល ចង់ទទួលព្រះគ្រិស្ដ។ ប្រាប់ពីការនេះទៅដល់មិត្តភក្ដិរបស់យើង ដើម្បីឱ្យយើងបានចូលរួមជាមួយគាត់ដោយសម្លាញ់របស់យើង ដើម្បីធ្វើសង្គ្រាម

ខាងវិញ្ញាណនោះ។

* នៅពេលដែលយើងបញ្ចប់សប្តាហ៍នេះ សូមឱ្យយើងយល់ព្រមអធិស្ឋានឱ្យគ្នារាល់ថ្ងៃ។ ទុកសំណូមពរអធិស្ឋាននេះនៅក្នុងបន្ទប់ដេករបស់យើង ហើយមុនពេលដែលអ្នកចូលដំណេក ឬក៏ក្រោកឡើងដើម្បីងាយចងចាំអធិស្ឋានឱ្យពួកគេ។

* សូមយើងបញ្ចប់ការប្រជុំ ដោយអរព្រះគុណព្រះចំពោះសេចក្តីសន្យាដ៏អស្ចារ្យរបស់ទ្រង់។ សូមអរព្រះគុណដល់ទ្រង់ដែលទ្រង់បានយាងមកផែនដីជាលើកទីមួយដើម្បីសង្គ្រោះយើងពីអំពើបាប ហើយចំពោះការសន្យានៃពីការយាងមកលើកទីពីររបស់ទ្រង់។ សូមទ្រង់ជួយយើងមានការស្មោះត្រង់ដើម្បីអធិស្ឋានឱ្យគ្នាទៅវិញទៅមក។

## មេរៀនទី២
# ការធ្វើដំណើររបស់ព្រះគ្រិស្តទៅកាន់ប្រទេសអេស៊ីព្ទ និងការជ្រមុជទឹក

ម៉ាថាយ ២-៣

*«ពេលដែលព្រះយេស៊ូទទួលពិធីជ្រមុជទឹករួចហើយ ទ្រង់យាងឡើងពីទឹក ស្រាប់តែផ្ទៃមេឃបើកចំហ ព្រះអង្គទតឃើញព្រះវិញ្ញាណរបស់ព្រះជាម្ចាស់យាងមកដូចសត្វព្រាបមកសណ្ឋិតលើព្រះអង្គ ពេលនោះមានព្រះសូរសៀងមកពីលើមេឃមកថា៖ នេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះអង្គណាស់» ម៉ាថាយ ៣:១៦-១៧។*

<u>រំលឹក</u>

១- ឈ្មោះមាតារបស់ព្រះគ្រិស្តគឺ________________។

២- ព្យាការីអេសាយបាននិយាយថាព្រះយេស៊ូនឹងត្រូវបានគេហៅថា អេម៉ាញូអែល ដែលប្រែថាព្រះ______________________________________។

៣- នៅលើភ្នំអូលីវនៅពេលដែលសិស្សបានសួរទៅទ្រង់អំពីការយាងត្រលប់មកផែនដីវិញរបស់ទ្រង់នោះព្រះយេស៊ូបានមានព្រះបន្ទូលថា ពួកគេត្រូវតែមានការប្រុងប្រយ័ត្នផងដែរ នោះគេនឹងមិនត្រូវ____________________ល្បួង។

៤- ព្រះយេស៊ូមានព្រះបន្ទូលថានឹងមានមនុស្សជាច្រើនមកអះអាងខ្លួនឯងថាជា ________________________________________________។

៥- ព្រះយេស៊ូបានមានព្រះបន្ទូលថា នឹងមានគ្រោះអាក្រក់កើតឡើងនៅ លើផែនដីនេះដូចជា_________________និង_________________។

៦- ព្រះយេស៊ូបានព្រះបន្ទូលថា សូម្បីតែអ្នកដែលដើរតាមព្រះគ្រិស្តក៏រងការ ឈឺ

ចាប់ដែរ តើដោយសារអ្វី?

៧- ព្រះយេស៊ូបានមានព្រះបន្ទូលថា ការយាងត្រលប់មករបស់ទ្រង់ដូចទៅនឹងហេតុការណ៍អ្វីនៅក្នុងធម្មជាតិ?

៨- តើពួកទេវតានឹងប្រមូលផ្តុំពួករាស្ត្ររបស់ព្រះនៅទីណា?

៩- តើនរណាដែលដឹងថាពេលណាព្រះគ្រិស្ត និងយាងមកវិញ?

១០-តើយើងគួរមានប្រតិកម្មយ៉ាងណា នៅពេលដែលមានអ្នកខ្លះបានធ្វើការអស្ចារ្យមិននៅក្នុងនាមរបស់ព្រះយេស៊ូ ហើយប្រកាសថាខ្លួនជាព្រះគ្រិស្ត?

១១-ខ្ញុំគួររាប់ខ្លួនខ្ញុំថាជា______________________________នៅពេលដែលមាននរណាម្នាក់ចំអកឡកឡឺយឱ្យខ្ញុំដោយសារតែព្រះគ្រិស្ត។

១២-ខ្ញុំគួរតែរាប់អានអស់អ្នកដែលឡកឡឺយឱ្យខ្ញុំ ព្រោះព្រះគ្រិស្តនៅជាមួយ____ ____________។

ព្រះយេស៊ូគ្រិស្តបានប្រសូតនៅក្នុងភូមិបេថ្លេហិម ហើយបានរស់នៅទីនោះរហូតដល់ពេលដែលព្យាការីមកពីទិសខាងកើតមកសួរសុខទុក្ខទ្រង់។ ព្យាការីទាំងនោះបានមកពីទិសខាងកើតដោយដើរតាមពន្លឺរបស់ផ្កាយរហូតទៅដល់ទីក្រុងយេរូសាឡឹម ក៏ចូលទៅសួរស្តេចហេរូឌថា តើស្តេចថ្មីរបស់អ៊ីស្រាអែលនោះនៅទីណា ព្រោះគេបានឃើញផ្កាយរបស់ទ្រង់។

នៅពេលស្តេចហេរូឌ និងមន្ត្រីរបស់ខ្លួនបានឮដូច្នោះ ក៏កើតមានក្តីបារម្ភជាខ្លាំង។ ដូច្នេះស្តេចហេរូឌក៏បានធ្វើការកោះប្រជុំសម្ងាត់មួយជាមួយនិងអ្នកជំនួយការផ្នែកសាសនារបស់គាត់។ ទ្រង់ក៏បានសួរទៅអ្នកទាំងនោះថា តើនៅក្នុងអត្ថបទគម្ពីរបាននិយាយថាស្តេចនៃសាសន៍យូដាដែលប្រសូតតាមសេចក្តីសន្យានោះនឹងប្រសូតនៅទីណា ហើយពួកគេក៏ឆ្លើយប្រាប់ទ្រង់ថា តាមទំនាយរបស់ព្យាការី បុត្រនោះនឹងត្រូវប្រសូត្រនៅក្នុងភូមិបេថ្លេហឹម។

ស្តេចហេរូឌក៏បានប្រាប់ទៅព្យាការីទាំងនោះអំពីកន្លែងដែលត្រូវទៅ។ តែមុនពេលដែលព្យាការីទាំងនោះចាកចេញពីវាំងទ្រង់ក៏ជជីកសួរពួកគេពីពេលដែលបានឃើញពន្លឺរបស់ផ្កាយនោះ ដើម្បីឱ្យដឹងច្បាស់ថា តើបុត្រានោះអាយុប៉ុន្មាន។ព្យាការីទាំងនោះក៏បន្តរដំណើរទៅភូមិបេថ្លេហឹម ហើយពន្លឺផ្កាយក៏បាននាំពួកគេឱ្យទៅដល់

ផ្ទះ ដែល ព្រះយេស៊ូ ស្នាក់ នៅ នោះ  ពួកព្យាការីក៏បាន ចូល ទៅថ្វាយ បង្គំ ព្រះយេស៊ូ ហើយ ក៏ បាននាំនូវ របស់ មានតំលៃមកថ្វាយ ដល់ ទ្រង់ដូចជា មាស គ្រឿងក្រអូប ជ័រល្វីងទេស។

មុនពេលដែលគេចាកចេញទៅកន្លែងគេវិញនោះ ព្រះជាម្ចាស់បានពន្យល់សប្តិថា ពួកគេមិនត្រូវទៅផ្ទះវិញតាមទីក្រុងយេរូសាឡឹមដូចដែលស្តេចហេរូឌបានប្រាប់នោះទេ ពួកគេក៏បានធ្វើដំណើរទៅតាមផ្លូវផ្សេងទៀត។

យូសែបក៏បានយល់សប្តិផងដែរពីព្រះអម្ចាស់ដែលទ្រង់ចង់ឱ្យគាត់ចាកចេញជាបន្ទាន់ជាមួយម៉ារា និងបុត្រតូច។ ពួកគេបានទៅនៅក្នុងប្រទេសអេស៊ីព្ទរហូតដល់ពេលដែលគាត់បានទទួលពាក្យបង្គាប់ពីព្រះអម្ចាស់ទៀត។ ព្រះជាម្ចាស់បានប្រាប់ទៅយូសែបថា ហេរូឌមានបំណងនឹងសម្លាប់បុត្រតូចដែលការនេះនឹងបានសម្រេចតាម សេចក្តី ទំនាយ ដែល មាន នៅ ក្នុង គម្ពីរ សញ្ញា ចាស់ *«អញ បាន ហៅ កូន អញ ឱ្យចេញពីស្រុកអេស៊ីព្ទ»*។

ស្តេចហេរូឌបានចាប់ផ្តើមតាមសម្លាប់ក្មេងៗ ទ្រង់បានសម្លាប់អស់ទាំងទារកប្រុសៗដែលមានអាយុពីរឆ្នាំ និងក្រោមនោះនៅក្នុងស្រុកបេថ្លេហឹម និងតំបន់ទាំងឡាយដែលនៅក្បែរនោះ។

បន្ទាប់ពីស្តេចហេរ៉ូឌបានសុគត ព្រះជាម្ចាស់ក៏បានមានព្រះបន្ទូលទៅកាន់យូសែបម្តងទៀតថា ឱ្យត្រលប់មកប្រទេសអ៊ីស្រាអែលវិញ។ យូសែបក៏ស្តាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយក៏គាត់ក៏ធ្វើដំណើរទៅកាន់ខេត្តមួយប៉ែកខាងជើងខេត្តយូដាឈ្មោះថា កាលីឡេ ពួកគេក៏បានរស់នៅក្នុងភូមិមួយឈ្មោះថា ណាសារ៉ែត។

ហើយ កាល សម័យ នោះ មាន បុរស ម្នាក់ ឈ្មោះ ហៅ ថា  យ៉ូហាន បាន មកអធិប្បាយនៅស្រុកយូដា គាត់បានប្រកាសថាចូរ «ប្រែចិត្ត ដ្បិតនគររបស់ព្រះគឺជិតដល់ហើយ» ។ យ៉ូហានបានស្លៀកពាក់អាវធ្វើពីរោមចៀម និងខ្សែក្រវ៉ាត់ស្បែកនៅចង្កេះ ម្ហូបរបស់គាត់គឺសត្វកណ្តូប និងទឹកឃ្មុំព្រៃ។មានមនុស្សជាច្រើនដែលមកតាំងពីស្រុកយូដាក្រុងយេរ៉ូសាឡឹម និងតំបន់ទាំងឡាយដែលនៅជុំវិញទន្លេយ័រដាន់បានជ្រមុជទឹកនៅក្នុងទន្លេយ័រដាន់ដើម្បីសារភាពនូវអំពើបាបរបស់ពួកគេ។ ហើយជាមួយគ្នានោះក៏មានអ្នកដឹកនាំសាសនាអាចារ្យផារិស៊ី និងពួកសាឌូស៊ីក៏បានមកស្តាប់ការអធិប្បាយរបស់លោកយ៉ូហានដែរ។  លោកយ៉ូហានបានហៅពួកទាំងនោះថា «ពូជពស់វែក» ព្រោះគេបានទុកចិត្តទៅនឹងសាសនាដែលជាកេរ្តិ៍មរតកនិងជា

ប្រពៃណីរបស់ពួកគេ ឱ្យជួយសង្គ្រោះ ដោយមិនបាច់ជឿថា គេត្រូវតែលន់តួបាបរបស់ពួកគេនោះឡើយ។

នៅពេលដែលយ៉ូហានអធិប្បាយលោកបាននិយាយថានិងមានម្នាក់ទៀតនឹងមកដែលនឹងជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ និងភ្លើង។ ហើយគាត់បាននិយាយទៀតថា មួយអង្គនោះនឹងបំបែកមនុស្ស ហើយនិងប្រមូលផ្តុំអស់អ្នកដែលបានដាក់សេចក្តីជំនឿទៅលើទ្រង់ហើយដាក់អស់អ្នកដែលមិនព្រមជឿទៅក្នុងភ្លើងដែលឆេះអស់កល្បជានិច្ច។

ព្រះគ្រិស្តក៏បាន យាងពី ស្រុកការលីឡេមកកាន់ឯលោកយ៉ូហានដែលនៅឯទន្លេយ័រដាន់ ដើម្បីទទួលពីធីជ្រមុជទឹកពីលោក។ លោកយ៉ូហានព្យាយាមបដិសេធមិន ព្រមធ្វើពិធីជ្រមុជទឹកឱ្យទ្រង់ទេដោយគាត់គិតថា គាត់មិនមានតំលៃសមនឹងជ្រមុជ ទឹក ឱ្យ ព្រះយេស៊ូ ទេ តែ ព្រះយេស៊ូ នៅ តែ ឱ្យ លោក ជ្រមុជ ទឹក ឱ្យ ដើម្បីឱ្យគ្រប់ទាំងសេចក្តីសុចរិតបានសម្រេច។

នៅពេលដែលបានទទួលពិធីជ្រមុជទឹកពីលោកយ៉ូហានហើយ នោះទ្រង់ក៏ងើបឡើងពីទឹក ហើយគ្រប់គ្នាអាចមើលឃើញមេឃបើកចំហមកចំពោះទ្រង់។ ព្រះវិញ្ញាណបរិសុទ្ធក៏បានបន្ទាបខ្លួនមកសណ្ឋិតលើទ្រង់ដូចជាសត្វព្រាប និងមានសម្លេងមកពីលើមេឃថា «នេះជាកូនស្ងួនភ្ងារបស់អញជាទីពេញចិត្តអញណាស់»។

## សំណួរផ្ទាល់មាត់

១- តើមនុស្សប្រភេទណាបានមកជួបព្រះយេស៊ូគ្រិស្ត? ហើយពួកគេបានថ្វាយអ្វីដល់ទ្រង់?

២- តើពួកមនុស្សទាំងនោះបានឈប់លើកទីមួយនៅក្នុងទីក្រុងអ្វី? ហើយតើគេបាននិយាយជាមួយអ្នកណា?

៣- ហេតុអ្វីនបានជាព្រះឱ្យយូសែបគេចទៅស្រុកអេស៊ីព្ទ?

៤- តើយូសែបទៅទីណាក្រោយពេលដែលស្តេចហេរូឌស្លាប់?

៥- តើលោកយ៉ូហានបាប់ទីស្ទអធិប្បាយនៅទីណា?

៦- តើគាត់មើលទៅដូចជាអ្វី?

៧- តើគាត់អធិប្បាយអំពីអ្វីទៅកាន់ប្រជាជន?

៨- តើនឹងមានអ្វីកើតឡើងចំពោះអ្នកដែលបានប្រែចិត្តលន់តួរអំពើបាបរបស់ខ្លួន?

៩- ហេតុអ្វីជាលោកយ៉ូហានបាន ហៅពួកអាចារ្យផារិស៊ី និងពួកសាដូស៊ីថាជាពូជពស់វែក?

១០-លោកយ៉ូហាន បាន និយាយ ថា មាន ម្នាក់ នឹង មក ដែលមានឋានៈធំ ជាងគាត់ ហើយគាត់និយាយថា មួយអង្គនោះនឹងធ្វើការបែងចែកពិភពលោក តើទ្រង់នឹងធ្វើយ៉ាងដូចម្តេច?

១១-តើអ្នកណាមកតាំងពីស្រុកកាលីឡេ ដើម្បីមកទទួលបុណ្យជ្រមុជទឹកពីលោកយ៉ូហាន?

១២-ព្រះយេស៊ូបានជំនះឱ្យលោកយ៉ូហានធ្វើពិធីជ្រមុជទឹកឱ្យ ទ្រង់ទោះបើជា លោកយ៉ូហានមិនហ៊ានក៏ដោយ តើហេតុផលអ្វីដែលព្រះគ្រិស្តបានលើក ឡើង?

១៣-តើមានអ្វីកើតឡើងនៅពេលដែលព្រះគ្រិស្តងើបឡើងមកពីទឹកវិញ?

## មេរៀនទី២
# សេចក្ដីពិតខាងវិញ្ញាណ
ម៉ាថាយ ២-៣

១. យើងអាចទទួលបទពិសោធដ៏ពិសេសរបស់ព្រះនៅក្នុងជីវិតរបស់យើង នៅពេលដែលយើងស្ដាប់តាមបង្គាប់ទ្រង់ទាំងស្រុង ។ ព្រះជាម្ចាស់បានបង្គាប់ឱ្យលោកយ៉ូសែបធ្វើការងារជាច្រើន ដែលគាត់មិនត្រូវធ្វើសោះ ។ គាត់បានស្ដាប់បង្គាប់ព្រះដោយព្រមរៀបការជាមួយនាងមារាទោះបីជានាងមានផ្ទៃពោះហើយក៏ដោយ គាត់បានទុកចិត្តលើព្រះជាម្ចាស់ ។ ទោះបីការមានផ្ទៃពោះរបស់នាងជាការដែលគាត់ពិបាកយល់ក៏ដោយ។ ហើយក្រោយមកម្ដងទៀតក្នុងពេលដែលគេកំពុងរស់នៅក្នុងភូមិបេថ្លេហិម ព្រះជាម្ចាស់បានប្រាប់ឱ្យគេភៀសខ្លួនទៅនៅប្រទេសអេស៊ីព្ទ។ ប្រទេសអេស៊ីព្ទ គឺជាប្រទេសផ្សេង ដែលប្រើភាសានិយាយផ្សេង ហើយថែមទាំងគោរព និងថ្វាយបង្គំព្រះក្លែងក្លាយទៀត។ ការដែលភៀសខ្លួនបែបនេះមិនមែនជាការងាយស្រួលសម្រាប់បុរសដែលមានប្រពន្ធនិងមានកូនខ្ចីនោះទេ ។ តែទោះជាយ៉ាងណា គាត់ជ្រើសរើសក្នុងការស្ដាប់បង្គាប់ព្រះ។ ជាលទ្ធផលព្រះយេស៊ូបានមានព្រះជន្មគេចផុតពីការតាមសម្លាប់។

ក៏ដូចជាការដែលព្រះបានរៀបចំគម្រោងការណ៍ដ៏ពិសេសសម្រាប់ឱ្យយ៉ូសែបនោះ ព្រះក៏បានរៀបចំផ្លូវឱ្យយើងម្នាក់ៗផងដែរ។ ព្រះគម្ពីរបានចែងថាទ្រង់បានស្គាល់យើងតាំងពីយើងនៅក្នុងផ្ទៃរបស់ម្ដាយយើងម្ល៉េះ គឺទ្រង់បានស្គាល់យើង ហើយទ្រង់បានមានផែនការដ៏ពិសេសសម្រាប់ជីវិតរបស់យើង។ ប្រសិនបើយើងចង់មានបទពិសោធពីការល្អរបស់ព្រះសម្រាប់ជីវិតរបស់យើង និងកូនចៅរបស់យើង យើងត្រូវស្ដាប់បង្គាប់នូវការណែនាំរបស់ទ្រង់មកដល់យើងទាំងអស់គ្នាយ៉ាងប្រុងប្រយ័ត្ន។ ព្រះគម្ពីរបានចែងមកទៀតថា ព្រះជាម្ចាស់ទ្រង់មានបំណងដើម្បីមានព្រះបន្ទូលមកកាន់យើងម្នាក់ៗ នៅក្នុងដួងចិត្តរបស់យើង នៅពេលដែលយើងអធិស្ឋាន និងអានព្រះបន្ទូលរបស់ទ្រង់។ ទ្រង់ចង់ដឹកនាំយើងទៅដល់ជីវិតដ៏ពេញបរិបូរជាមួយទ្រង់។ ជាច្រើនលើកច្រើនសា ព្រះជាម្ចាស់តែងមានបន្ទូលមកដោយផ្ទាល់មកកាន់យើងនៅ

ពេលដែលយើងអធិស្ឋាន និងអានព្រះបន្ទូលរបស់ទ្រង់។ទ្រង់បានបង្ហាញយើងអំពីស្ថានភាពជាក់លាក់ អត្តចរិតជាក់លាក់ ហើយការសម្រេចចិត្តជាក់លាក់ដែលយើងបានធ្វើ។ យើងត្រូវតែធ្វើការជ្រើសរើស ទោះបីជាពេលនោះមិនទាន់មកដល់ក៏ដោយ គឺយើងធ្វើដូចជាលោកយ៉ូសែបបានធ្វើ។ គាត់បានធ្វើការសម្រេចចិត្តស្តាប់បង្គាប់ព្រះជាម្ចាស់ ទោះបីជាស្ថានការណ៍នោះលំបាកយ៉ាងណាក៏ដោយ។

* តើព្រះជាម្ចាស់មានបន្ទូលមកកាន់លោកអ្នក អំពីការជាក់លាក់ណាមួយនៅក្នុងជីវិតរបស់លោកអ្នកទេ? តើទ្រង់មានបន្ទូលឱ្យលោកអ្នកធ្វើការផ្លាស់ប្តូរអ្វីមួយនៅក្នុងជីវិតដែលជាការលំបាកសម្រាប់លោកអ្នកដើម្បីផ្លាស់ប្តូរវាទេ? ប្រសិនបើមានតើលោកអ្នកអាចចែកចាយឱ្យក្រុមបានដឹងផងបានទេ? ហើយអ្នកនៅក្នុងក្រុមត្រូវកត់ត្រា សំណូមពរអធិស្ឋានរបស់លោកអ្នក។ ព្រះជាម្ចាស់ចង់ប្រទានកម្លាំងដល់លោកអ្នកដើម្បីស្តាប់តាមផែនការរបស់ទ្រង់នៅក្នុងជីវិតរបស់យើង។

២ មុនពេលព្រះយេស៊ូបានយាងត្រលប់ទៅស្ថានសួគ៌វិញ ក្រោយពេលដែលទ្រង់មានព្រះជន្មរស់ឡើងវិញ ទ្រង់បានប្រទានបញ្ញត្តដល់អស់អ្នកដែលដើរតាមទ្រង់។ ចូរយើងរំលឹកឡើងវិញ នូវពាក្យចុងក្រោយរបស់ព្រះយេស៊ូគ្រិស្ត មុនពេលដែលទ្រង់យាងត្រលប់ទៅស្ថានសួគ៌វិញ «ដូច្នេះ ចូរទៅបង្កើតសិស្សឱ្យមាននៅគ្រប់ទាំងសាសន៍ ហើយធ្វើពិធីជ្រមុជទឹកឱ្យពួកគេ ដោយនូវព្រះនាមព្រះបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ហើយបង្រៀនគេឱ្យកាន់តាមគ្រប់ទាំងសេចក្តីដែលខ្ញុំបានបង្គាប់ដល់អ្នករាល់គ្នា មើលខ្ញុំ និងនៅជាមួយអ្នករហូតដល់បំផុតកល្ប។នៅក្រោយការសិក្សានេះ យើងនឹងបានរៀនពីរបៀបដែលត្រូវចេញទៅប្រាប់អ្នកដទៃអំពីព្រះយេស៊ូ ហើយមានបញ្ញត្តមួយដែលយើងខ្លួនឯងត្រូវតែធ្វើតាមដែរគឺ «យើងត្រូវធ្វើពិធីជ្រមុជទឹក នៅក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងដោយព្រះនាមព្រះវិញ្ញាណបរិសុទ្ធ»។

* ពិធីជ្រមុជទឹក គឺជាសកម្មភាពសាមញ្ញមួយនៃការស្តាប់បង្គាប់។ តាមរយៈគំរូនេះយើងបានតំកើងព្រះនាមព្រះយេស៊ូគ្រិស្ត។ ការជ្រមុជទៅក្នុងទឹកក្នុងនាមជាមនុស្សដែលគោរពកោតខ្លាចព្រះ គឺជ្រមុជរូបកាយរបស់អ្នកទៅក្នុងទឹកមួយភ្លែត ហើយងើបឡើង។

* ព្រះយេស៊ូមិនបានធ្វើពិធីជ្រមុជទឹកកាលទ្រង់នៅជាទារកទេ។ នៅក្នុងដំណឹងល្អរបស់លោកលូកា យើងបានដឹងថា ព្រះយេស៊ូបានយកទៅវិហារកាលទ្រង់

នៅជាទារក។ ពួកសង្ឃមានឱ្យពរដល់ទ្រង់ និងឪពុកម្ដាយរបស់ទ្រង់ តែនោះមិនមែនជាពិធីជ្រមុជទឹកទេ។

* ការជ្រមុជទឹក គឺជាជំរើសដែលទ្រង់ជ្រើសរើសដោយខ្លួនឯងមិនមែនជាអ្វីមួយដែលឪពុកម្ដាយរបស់ទ្រង់ធ្វើឱ្យទ្រង់ទេ។ តាមរយៈគំរូរបស់ព្រះយេស៊ូគ្រិស្ដ យើងក៏គួរទៅដោយខ្លួនយើងផ្ទាល់ ហើយរកមនុស្សរបស់ព្រះដើម្បីធ្វើពិធីជ្រមុជទឹកឱ្យយើង។

* នេះមិនមែនជាពិធីសាសនាដែលបញ្ជាក់ថា អ្នកនៅក្នុងផ្នែកណាមួយ ឬនិកាយណាមួយនោះទេ ហើយក៏មិនមែនជាពិធីខាងព្រលឹងវិញ្ញាណដែលជំរះយើងពីអំពើបាបនោះដែរ។ នេះ គឺជានិមិត្តសញ្ញាដែលបង្ហាញជាសាធារណៈមួយនៃការប្ដេជ្ញារបស់យើង ក្នុងការដើរតាមព្រះយេស៊ូគ្រិស្ដ។ ព្រះគម្ពីរបានបង្រៀនយើងថា ពិធីជ្រមុជទឹក គឺជារូបភាពនៃការកប់ និងការរស់ឡើងវិញនៃព្រះយេស៊ូគ្រិស្ដ។ នៅពេលដែលយើងទទួលពិធីជ្រមុជទឹក យើងប្រគល់ខ្លួនយើង ចូលរួមក្នុងការកប់ និងការរស់ឡើងវិញជាមួយព្រះយេស៊ូដែរ។

**- តើលោកអ្នកគិតយ៉ាងណាអំពីពិធីជ្រមុជទឹក? តើអ្នកគិតថា វាជាការលំបាកមួយក្នុងការជ្រមុជទឹកនៅក្នុងព្រះគ្រិស្ដទេ? តើអ្នកត្រូវការទទួលពិធីជ្រមុជទឹកឬទេ? តើអ្នកចង់ទទួលពិធីជ្រមុជទឹកឬទេ?**

## មេរៀនទី៣

# ការល្បួងព្រះយេស៊ូគ្រិស្ត

ម៉ាថាយ ៤

*«មនុស្សមិនមែនរស់ដោយសារតែអាហារប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ព្រះបន្ទូល ដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ដែរ»* ម៉ាថាយ ៤:៤

<u>រំលឹក</u>

១- ព្យាការីអេសាយទាយថាព្រះយេស៊ូនឹងត្រូវបានគេហៅថាអេម៉ាញូអែល ដែលប្រែថាព្រះ «______________________»។

២- ព្រះយេស៊ូមានព្រះបន្ទូលថា នៅពេលដែលទ្រង់យាងត្រលប់មកផែនដីវិញនោះនិងដូចជា________________________________________។

៣- ព្រះយេស៊ូមានព្រះបន្ទូលថា នៅពេលដែលទ្រង់យាងត្រលប់មកកាន់ផែនដីវិញនោះ គេនឹងឃើញទ្រង់យាងមកនៅក្នុង______________ដោយមានអំណាចដ៏អស្ចារ្យ និងសិរីរុងរឿងរបស់ទ្រង់។

៤- ព្រះយេស៊ូមានព្រះបន្ទូលថា មុនពេលដែលទ្រង់យាងមកនោះនឹងមានមនុស្សជាច្រើនអាចធ្វើការអស្ចារ្យ ដើម្បីបង្ហាញថា គេគឺជាទ្រង់។ យើងត្រូវតែប្រុងប្រយ័ត្ន ដើម្បីកុំ___________________ដោយសារព្យាការីក្លែងក្លាយទាំងនោះ។

៥- ព្រះយេស៊ូមានព្រះបន្ទូលថាយើងគួរតែចាត់ទុកខ្លួនយើងថាជា________នៅពេលដែលអ្នកដទៃធ្វើឱ្យយើងឈឺចាប់ដោយសារតែព្រះគ្រិស្ត ព្រោះថាយើងនឹងបានទទួលរង្វាន់ ហើយទ្រង់ក៏មានព្រះបន្ទូលទៀតថាយើងគួរតែរាប់អានអ្នកទាំងនោះដោយ______________________________។

៦- ព្រះយេស៊ូមានព្រះបន្ទូលថា អ្នកដែលដឹងថាពេលណាទ្រង់នឹងយាងមកផែនដីវិញ គឺមានតែម្នាក់ទេគឺ_________________________។

៧- បុរសម្នាក់ឈ្មោះ________________________បានអធិប្បាយអំពីការប្រែចិត្តដែលបុរសនោះពាក់អាវរោមសត្វហើយបរិភោគសត្វកណ្តូបជាអាហារ ។

៨- មានមនុស្សជាច្រើនបានមកសុំធ្វើពិធីជ្រមុជទឹកអំពីលោកយ៉ូហាន ហើយលន់តួរ__________________________________________របស់ពូកគេ។

៩- លោកយ៉ូហានបានមានប្រសាសន៍ថា មួយអង្គដែលនឹងបំបែកមនុស្សនៅលើពិភពលោកនេះ និងអស់អ្នកដែលបដិសេធទ្រង់នោះនឹងត្រូវថ្កោលទោសទៅ____

__________________________________________________។

១០- ព្រះយេស៊ូបានមកសុំឱ្យយ៉ូហាន៍ឱ្យទ្រង់។

១១- នៅពេលដែលព្រះយេស៊ូបានទទួលពិធីជ្រមុជទឹករួចហើយនោះ_____បានចុះមកដូចជាសត្វព្រាបហើយមាន___________________ពីស្ថានសួគ៌មក។

១២- ពាក្យចុងក្រោយមុនពេលដែលព្រះយេស៊ូយាងត្រលប់ទៅស្ថានសួគ៌វិញទ្រង់បានប្រាប់ទៅសិស្សរបស់ទ្រង៏ឱ្យដល់អស់អ្នកដែលទទួលទ្រង់ជាព្រះសង្គ្រោះ។

១៣- ការជ្រមុជទឹកជានិមិត្តរូបនៃ____________និង____________របស់ព្រះយេស៊ូ។

១៤- យើងត្រូវទទួលពិធីជ្រមុជទឹក___________________មិនមែន ពីព្រោះតែវា______________________សម្រាប់អំពើបាបយើងទេ។ ប៉ុន្តែ វាជានិមិត្តសញ្ញាដែលបញ្ជាក់ខ្លួនរបស់យើងទៅនឹង________________________។

ក្រោយពីទ្រង់បានទទួលពិធីជ្រមុជទឹករួចហើយ នោះព្រះវិញ្ញាណបរិសុទ្ធក៏បាននាំទ្រង់ឱ្យទៅកន្លែងដែលត្រូវអារក្សល្បួង។ ព្រះយេស៊ូបានតមអត់អាហារនៅទីនោះសែសិបយប់សែសិបថ្ងៃ ហើយក្រោយពីការតមនេះ ហើយទ្រង់បានឃ្លានយ៉ាងខ្លាំង គឺពេលនោះហើយដែលអារក្សមកឯព្រះយេស៊ូ ហើយនិយាយទៅកាន់ទ្រង់ថា «ប្រសិនបើអ្នកជាកូនរបស់ព្រះមែននោះចូរបង្គាប់ឱ្យថ្មទាំងនេះក្លាយទៅជានំបុ័ងទៅ» ព្រះយេស៊ូបានមានព្រះបន្ទូលតបវិញដោយប្រើអត្ថបទគម្ពីរដែលមាននៅក្នុងសញ្ញាចាស់ថា *« មនុស្ស មិនមែនរស់ ដោយសារតែនំបុ័ង ប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះមកដែរ»*។

បន្ទាប់មកអារក្សក៏យកទ្រង់ទៅលើកំពូលនៃព្រះវិហារនៅក្នុងទីក្រុងយេរូសាឡឹម។ អារក្សក៏និយាយទៅកាន់ទ្រង់ថា «បើអ្នកជាព្រះរាជបុត្រានៃព្រះមែន ចូរ

ទំលាក់ខ្លួនអ្នកទៅក្រោមចុះ នោះព្រះនឹងចាត់ទេវតារបស់ទ្រង់ឱ្យមកទ្រអ្នកដោយដៃ ក្រែងលោជើងរបស់ អ្នកទង្គិច នឹង ថ្ម » នោះ ព្រះ យេស៊ូក៏មាន ព្រះ បន្ទូល ទៅវិញដោយលើកព្រះ បន្ទូល ព្រះ មកទៀតថា *«ចូរកុំឱ្យឯងល្បួង ព្រះ ជាម្ចាស់ ជា ព្រះនៃឯងឡើយ»*។

ក្រោយមកទៀតអារក្សក៏នាំទ្រង់ទៅលើកំពូលភ្នំដ៏ខ្ពស់ដែលអាចមើលឃើញគ្រប់ទាំងអាណាចក្រទាំងអស់នៅលើផែនដី ។ នោះអារក្សនិយាយថា «យើងនឹងឱ្យ អាណា ចក្រ ទាំង នេះ ទៅ ឯង ប្រសិន បើ ឯង ក្រាប ចុះ ហើយថ្វាយបង្គំយើង » ព្រះយេស៊ូក៏តបទៅថា *«នែសាតាំងចូរឯងថយចេញពីអញទៅដ្បិតមានសេចក្តីចែងទុកមកថា ឯងត្រូវតែថ្វាយបង្គំដល់ព្រះអម្ចាស់ជាព្រះនៃឯង ហើយត្រូវគោរពដល់ទ្រង់តែមួយប៉ុណ្ណោះ»* នោះអារក្សក៏ថយចេញពីទ្រង់ទៅរួចក៏មានទេវតាមកបម្រើទ្រង់។

## សំណួរផ្ទាល់មាត់

១- តើព្រះវិញ្ញាណបរិសុទ្ធបានយកព្រះយេស៊ូទៅល្បួងនៅកន្លែងណា?

២- តើព្រះយេស៊ូធ្វើអ្វីអស់រយៈពេលសែសិបយប់សែសិបថ្ងៃមុនពេលដែលអារក្សមកល្បួងទ្រង់?

៣- នៅក្នុងសេចក្តីល្បួងពីរដំបូងអារក្សបានព្យាយាមឱ្យព្រះយេស៊ូបង្ហាញថាទ្រង់ជានរណា?

៤- នៅក្នុងសេចក្តីល្បួងលើកទីមួយ តើអារក្សព្យាយាមឱ្យព្រះគ្រិស្តជប់ដុំថ្មឱ្យទៅជាអ្វី?

៥- តើព្រះគ្រិស្តយកឈ្នះអារក្សនៅក្នុងការល្បួងលើកទីមួយដោយរបៀបណា?

៦- នៅក្នុងការល្បួងទីពីរ តើអារក្សព្យាយាមឱ្យព្រះគ្រិស្តធ្វើអ្វីនៅពេលដែលវានាំទ្រង់ទៅលើកំពូលខ្ពស់នៃព្រះវិហារ?

៧- តើព្រះយេស៊ូយកឈ្នះអារក្សនៅក្នុងការល្បួងទីពីរនេះដោយរបៀបណា?

៨- នៅក្នុងសេចក្តីល្បួងលើកទីបី អារក្សបានសន្យាថា នឹងឱ្យផែនដីទាំងមូលទៅទ្រង់ ប្រសិនបើទ្រង់ព្រមធ្វើការមួយឱ្យវា តើវាព្យាយាមឱ្យទ្រង់ធ្វើអ្វី?

៩- តើព្រះយកជ័យជំនះលើការល្បួងទីបីនេះដោយរបៀបណា?

១០-តើអ្នកណាមកបម្រើព្រះយេស៊ូក្រោយពេលដែលទ្រង់បានដេញអារក្សចេញឆ្ងាយ?

## មេរៀនទី៣

## សេចក្តីពិតខាងវិញ្ញាណ

ម៉ាថាយ ៤

១- យើងនឹងទទួលការល្បួង បើទោះបីជាក្រោយពេលដែលយើងបានប្រគល់ជីវិតទៅព្រះគ្រិស្តក៏ដោយ។ យើងមិនបាច់ចេញទៅដើម្បីឱ្យមានការល្បួងពីអារក្សដូចជាព្រះគ្រិស្តនោះទេ។ ព្រះគម្ពីរបានប្រាប់យើងថា យើងមិនត្រឹមតែទទួលការល្បួងពីអារក្ស ប៉ុន្តែ តាមរយៈចំណង់ប្រាថ្នារបស់យើងផងដែរ (យ៉ាកុប១:១៤)។ព្រះគម្ពីរក៏បាននិយាយទៀតថា នៅក្នុងចិត្តរបស់យើងមានការពីរដែលប្រឆាំងគ្នាជាប្រចាំ គឺមួយពីចិត្តដែលមានបំណងប្រាថ្នាចង់ធ្វើការល្អ មួយទៀតគឺចិត្តដែលមានបំណងប្រាថ្នាចង់ធ្វើការអាក្រក់ *«ពីព្រោះ ខ្ញុំមិនយល់ពីការដែលខ្ញុំប្រព្រឹត្តិនោះទេ តែការអាក្រក់ដែលខ្ញុំមិនចង់ធ្វើនោះបែរជាខ្ញុំធ្វើទៅវិញ» (រ៉ូម ៧:១៥, ១៩)* ។

២- យើងនឹងទទួលសេចក្តីល្បួងពីព្រោះយើងមានលក្ខណៈធម្មជាតិពីរយ៉ាងនៅក្នុងជីវិតរបស់យើង។ មួយ គឺជាវិញ្ញាណនៃសាច់ឈាម ហើយមួយទៀតគឺជាវិញ្ញាណរបស់ព្រះជាម្ចាស់ (ព្រះវិញ្ញាណបរិសុទ្ធ) នៅក្នុងយើងកាឡាទី ៥:១៦-១៧ *«ខ្ញុំប្រាប់ថា ចូរដើរនៅក្នុងព្រះវិញ្ញាណនោះអ្នករាល់គ្នានឹងមិនបំពេញសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាមនោះទេ តែសេចក្តីទាំងពីរនោះប្រឆាំងគ្នាដល់ម៉្លេះបានជាអ្នករាល់គ្នាធ្វើការដែលចង់ធ្វើទៅមិនកើត»*។ នឹងមានការប្រឆាំងគ្នាជាប្រចាំ រវាងបំណងចិត្តរបស់អ្នក និងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ទាំងក្នុងការតូច និងការធំ។

៣- យើងអាច យកឈ្នះសេចក្តីកល្បួងបានតាមវិធីដែលព្រះគ្រិស្ត បានធ្វើគឺ ប្រើអំណាចនៃព្រះបន្ទូលរបស់ព្រះ។ នៅក្នុងព្រះគម្ពីរហេព្រើរ ៤:១២ និយាយថា *«ព្រះបន្ទូលរបស់ព្រះរស់នៅ ហើយខ្លាំងពូកែផង ក៏មុតជាងដាវមុខពីរ ទាំងធ្លុះទាល់តែចូលទៅកាត់ព្រលឹងនិងវិញ្ញាណហើយសន្លាក់ និងខួរឆ្អឹងដាច់ពីគ្នា ទាំងពិចារណាអស់ទាំងគំនិតដែលគិតនៅក្នុងចិត្តផង»*។ សូមអានខគម្ពីរនេះម្តងកហើយម្តងទៀត រួចសួរទៅក្រុមថា តើគិតយ៉ាងដូចម្តេចអំពីអត្ថន័យនៃខនេះ?

ព្រះបន្ទូលរបស់ព្រះ គឺមិនមែនគ្រាន់តែជាសៀវភៅសម្រាប់តែប្រៀន ប្រដៅ

ប៉ុណ្ណោះទេ។ តែគឺជាព្រះបន្ទូលដ៏រស់ ដែលព្រះប្រើសម្រាប់និយាយមកកាន់ដួងចិត្ត យើងម្នាក់ៗតាមវិធីផ្សេងៗដោយផ្ទាល់ខ្លួន ។ វានឹងជ្រាតចូលយ៉ាងជ្រៅទៅក្នុងព្រលឹងដែលមានតែព្រះទេដឹងពីការនេះ។

ការសំខាន់បំផុតតែមួយដែលអ្នកដើរតាមព្រះយេស៊ូគ្រិស្តគួរធ្វើនោះគឺចំណាយពេល**ជារៀងរាល់ថ្ងៃ** តែម្នាក់ឯងជាមួយ និងព្រះបិតា។ អារក្សសាតាំងវាធ្វើគ្រប់បែបយ៉ាង ដើម្បីរាំងយើងឱ្យដាច់ចេញពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពីព្រោះដឹងថាព្រះបន្ទូលរបស់ព្រះ ជាប្រភពនៃកម្លាំងរបស់យើង ។ វានឹងប្រាប់យើងថា យើងរវល់ណាស់យើងបានចូលរួមរៀនព្រះបន្ទូលរួចហើយ យើងងងុយគេងណាស់ ព្រះគម្ពីរពិបាកយល់ណាស់ ហើយមានដោះសារជាច្រើន។ ប៉ុន្តែ យើងត្រូវទទួលស្គាល់គំនិតទាំងនេះ គឺវាជាការកុហកបោកប្រាស់។ យើងត្រូវដាក់អទិភាព ដើម្បីចំណាយពេល**ជារៀងរាល់ថ្ងៃ** នៅក្នុងការអធិស្ឋាន និងការអានព្រះបន្ទូលរបស់ព្រះ។

### នេះជាផែនការងាយស្រួលសម្រាប់យើងអនុវត្តន៍តាម៖

១- ចាប់ផ្ដើមចំណាយពេលដ៏ស្ងៀមស្ងាត់តែម្នាក់ឯងជាមួយព្រះដោយនិយាយទៅកាន់ទ្រង់អំពីទឹកចិត្តប៉ុណ្ណាដែលយើងស្រឡាញ់ទ្រង់ ហើយសរសើរព្រះអង្គ ពីភាពអស្ចារ្យទាំងអស់របស់ទ្រង់។

២- អរគុណដល់ទ្រង់សម្រាប់គ្រប់ការដែលទ្រង់បានធ្វើនៅក្នុងជីវិតរបស់យើង ឬការដែលទ្រង់បានឆ្លើយសម្រាប់ការអធិស្ឋានរបស់យើង។

* វាជាល្អបើយើងសរសេរនៅក្នុងផ្នែកនៃសៀវភៅអធិស្ឋានរបស់យើងថា«**អរគុណ**» ឬក៏កត់ត្រាការទាំងនោះដែលព្រះបានធ្វើនៅក្នុងជីវិតរបស់យើង ដោយមានដាក់ថ្ងៃខែផង។ អ្នកអាចកត់ត្រាពីការអស្ចារ្យដែលព្រះបានធ្វើនៅក្នុងជីវិតរបស់អ្នក។

៣- អធិស្ឋានឱ្យអ្នកដទៃ មនុស្សដែលចូលរួមសិក្សាព្រះគម្ពីរជាមួយអ្នក ក្រុមគ្រួសារ មិត្តភក្រ្ត ជាពិសេសសម្រាប់អស់អ្នកដែលមិនទាន់ស្គាល់ព្រះយេស៊ូ នៅឡើយ និងសេចក្តីត្រូវការពិសេស។ បើសិនជាអ្នកមានមនុស្សច្រើនត្រូវអធិស្ឋានឱ្យយើងអាចសរសេរនៅក្នុងក្រដាសផ្សេងៗ ហើយបែងចែកឱ្យគ្រួសារ ឬមិត្តភក្រ្តរបស់អ្នកជួយអធិស្ឋានឱ្យពួកគេមួយអាទិត្យម្តង។

*ឧទាហរណ៍:*

| | |
|---|---|
| **ថ្ងៃចន្ទ** | **ថ្ងៃអង្គារ** |
| -ពូផាម | -យាយ |
| -ពូដាវិឌ | -លោកដារ៉ា |
| -ណារ៉េត | -ណារស់ |

* ជាការល្អ បើសិនជាយើងឈប់មួយភ្លែត ដើម្បីអនុវត្តទាំងអស់គ្នានៅក្នុងចំណុចនេះ។

៤- អាននិងសញ្ជឹងគិតនូវព្រះបន្ទូលរបស់ព្រះ។ ព្រះគម្ពីរបានបង្រៀនយើងថាយើងមិនគួរអានព្រះគម្ពីរដូចជាយើងអានសៀវភៅផ្សេងទេ ប៉ុន្តែ យើងត្រូវធ្វើការសញ្ជឹងគិតផង។ កន្លែងនេះមានន័យថាយើងគួរ៖

- អានដោយយឺតៗ

- អានហើយអានទៀត គិតឱ្យបានស៊ីជំរៅទៅលើអត្ថន័យនៃពាក្យ។ ប្រហែលជាយើងត្រូវអានពីរបីដងមុនពេលដែលយើងពិចារណាទៅលើសេចក្តីពិតដែលព្រះចង់ឱ្យយើងយល់នោះ។

- ដាក់ឈ្មោះរបស់អ្នកទៅក្នុងសេចក្តីពិតនៃព្រះបន្ទូល។ ឧទាហរណ៍ មានខមួយនិយាយថា «ចូរគោរពប្រណិបត្តិឪពុកម្តាយរបស់អ្នក» ជាលក្ខណៈផ្ទាល់ខ្លួននោះមានន័យថា «ដារា អ្នកត្រូវគោរពប្រណិបត្តិដល់ឪពុកម្តាយរបស់អ្នក»។

- អធិស្ឋានខនេះត្រលប់ទៅព្រះវិញ ហើយអរព្រះគុណដល់ទ្រង់សម្រាប់ព្រះពររបស់ទ្រង់។ ចូរទូលសូមនូវតម្រូវការជាចាំបាច់របស់យើង។ ឧទាហរណ៍ «អរគុណទ្រង់សម្រាប់ឪពុកម្តាយរបស់យើង។ ព្រះជាម្ចាស់ទូលបង្គំអរព្រះគុណដល់ព្រះអង្គដែលឆ្លើយតបគ្រប់ទាំងតម្រូវការរបស់ខ្ញុំ ហើយទ្រង់គង់នៅជាមួយយើង ទោះបីជាឪពុកនៅលោកិយមិនបាននៅជាមួយយើងក៏ដោយ»។

នៅក្នុងព្រះគម្ពីរមានសេចក្តីពិតខាងវិញ្ញាណច្រើនណាស់ ដែលព្រះចង់មានទំនាក់ទំនងជាមួយយើងអំពីជីវិតរបស់យើងនៅពេលឥឡូវនេះ។ នេះជាគំរូនៃរបៀបសញ្ជឹងគិតព្រះបន្ទូលរបស់ព្រះជាម្ចាស់។

* ចូរយើងចាប់ផ្តើមពីជំពូកបន្ទាប់ គឺនៅម៉ាថាយជំពូកទី៥

**ចូរយើងផ្អាកមួយភ្លែត ហើយសូមឱ្យគ្រប់គ្នាចំណាយពេលដើម្បីអាននូវបីឬ**

ប្អូនខដំបូង។ បើមាននរណាម្នាក់មិនចេះអាន អ្នកដឹកនាំគួរអានខនេះឱ្យអ្នកនោះស្តាប់ ចំនួនពីរបីដងដោយមិនបាច់ពន្យល់ទេ។

ឥឡូវសូមយើងម្នាក់ៗ ធ្វើការព្យាយាមដើម្បីយល់អត្ថន័យនៃខនេះ ប្រសិនបើជាយើងអាចយល់ សូមដាក់ឈ្មោះរបស់យើងនៅក្នុងខនោះ សូមកុំខ្លាចនឹងអនុញ្ញាតិព្រះវិញ្ញាណបរិសុទ្ធមានព្រះបន្ទូលមកកាន់លោកអ្នក។ នេះគឺជាឧទាហរណ៍មួយប៉ុន្តែ នេះមិនមែនតែបានន័យថា ខនេះមានមធ្យោបាយតែមួយដែលយើងយកមកអនុវត្តនៅក្នុងជីវិតមនុស្សម្នាក់ៗនោះទេ។ មានព្រះបន្ទូលជាច្រើនដែលព្រះជាម្ចាស់មានបន្ទូលមកកាន់ខ្ញុំនៅពេលដែលអានខនេះ។

នៅក្នុងខទី៣ *«មានពរហើយអស់អ្នកដែលមានសេចក្តីកំសត់ខាងវិញ្ញាណដ្បិតនរគរស្ថានសួគ៌ជារបស់ផងអ្នកនោះ»*។ សេចក្តីពិតខាងវិញ្ញាណ៖ នៅក្នុងខទី៣នេះមានន័យថា ខ្ញុំបានទទួលព្រះពរប្រសិនបើខ្ញុំមានសេចក្តីកំសត់ខាងវិញ្ញាណ ពីព្រោះខ្ញុំនឹងបាននគរព្រះជាមរតក។ ឱព្រះជាម្ចាស់អើយសូមជួយឱ្យទូលបង្គំជាមនុស្សដែលមានសេចក្តីកំសត់ខាងវិញ្ញាណ ទូលបង្គំមិនចង់ក្លាយជាអ្នកមានអំនួត ហើយពោរពេញទៅដោយវិញ្ញាណរបស់ខ្លួនឯងនោះទេ។ អរព្រះគុណដល់ព្រះអង្គដែលកូនបានដឹងថា កូននឹងបាននគរស្ថានសួគ៌ជាមរតក ទូលបង្គំជាមនុស្សមានពរពិត។

ខទី៤: *«មានពរហើយអស់អ្នកណាដែលយំសោក ដ្បិតអ្នកនោះនឹងបានសេចក្តីកំសាន្តចិត្ត»*។ សេចក្តីពិតខាងវិញ្ញាណ៖ នៅក្នុងទី៤នេះ វាជាការពិបាកបំផុតសម្រាប់ខ្ញុំក្នុងការដែលស្រមើលស្រមៃ បានទទួលព្រះពរនៅពេលដែលយំសោកនោះ គឺជាពេលដ៏សោកសៅបំផុត។ ប៉ុន្តែក្នុងនាមជាអ្នកដែលដើរតាមព្រះគ្រិស្តខ្ញុំអរព្រះគុណដល់ទ្រង់ ពីព្រោះខ្ញុំដឹងថាខ្ញុំពិតជាបានទទួលព្រះពរ។ គឺមានសេចក្តីសង្ឃឹមសម្រាប់យើង ដែលមានសេចក្តីជំនឿលើព្រះគ្រិស្ត។ ព្រះជាម្ចាស់ប្រទានសេចក្តីសង្ឃឹមដល់យើង ហើយនេះគឺពិតជាសេចក្តីកំសាន្តចិត្តមួយដល់យើង។ ព្រះអង្គអើយកូនសូមអរព្រះគុណដល់ទ្រង់ក្នុងការលួងលោមចិត្ត នៅពេលដែលទទួលបង្គំយំសោក នៅក្នុងពេលដែលម្តាយទទួលបង្គំស្លាប់ទៅ។ ទូលបង្គំសូមអរគុណដល់ទ្រង់ ដែលបានចាត់អ្នកបំរើព្រះអង្គមកជួយលើកទឹកចិត្តទូលបង្គំនៅពេលដែលទូលបង្គំពិបាកចិត្ត។ អរគុណដល់ព្រះវិញ្ញាណបរិសុទ្ធដែលបានលួងលោមព្រលឹងទូលព្រះបង្គំ មែនហើយព្រះជាម្ចាស់អើយ ទូលបង្គំអាចឃើញថា ក្នុងនាមជាអ្នកជឿ ទូលបង្គំបានទទួលព្រះពរនៅពេលដែលទូលបង្គំយំសោក។ ទូលបង្គំស្រឡាញ់ទ្រង់ ដែលទ្រង់ថែរក្សាទូលបង្គំ។

គ្មានរូបមន្តពិសេសណា គ្មានពាក្យពិសេសណា ឬក៏វិធីសាស្ត្រពិសេសណាផ្សេងទៀតឡើយ។ ការដែលសំខាន់នោះ គឺគ្រាន់តែរំពឹងគិតលើព្រះបន្ទូលរបស់ព្រះ ហើយអនុញ្ញាតឱ្យព្រះបន្ទូលរបស់ព្រះជ្រាតចូលក្នុងជម្រៅនៃព្រលឹងរបស់អ្នក។នៅពេលដែលព្រះបន្ទូលរបស់ព្រះជ្រាតចូលក្នុងជីវិតរបស់យើងហើយ គឺព្រះនឹងមានបន្ទូលនៅក្នុងផ្នែកដ៏ជ្រៅជាងគេនោះ។

ដោយធ្វើបែបនេះជាប្រចាំ នោះយើងនឹងកាន់តែមានលក្ខណៈដូចជាព្រះគ្រិស្តនៅគ្រប់ផ្នែកទាំងអស់។ មិនត្រឹមតែជួយយើងឱ្យឈ្នះការល្បួងប៉ុណ្ណោះទេ តែថែមទាំងជួយយើងឱ្យមានសេចក្ដីស្រឡាញ់ ហើយធ្វើគ្រប់សកម្មភាពទាំងអស់ដែលបង្ហាញពីភាពជាកូនរបស់ព្រះនៅផ្នែកនៃជីវិតរបស់យើង។ ការស្គាល់ព្រះតាមរបៀបផ្ទាល់ខ្លួនរបស់យើង គឺជាគន្លឹះក្នុងការទទួលជ័យជំនះក្នុងជីវិតជាគ្រិស្តបរិស័ទ។

*ខ្ញុំបានធ្វើការណែនាំឱ្យចែកជាផ្នែក នៅក្នុងសៀវភៅសម្រាប់សេចក្ដីអធិស្ឋានរបស់អ្នកដែលជាផ្នែកសម្រាប់រំពឹងគិត។ ចូរសរសេរថ្ងៃ ខែ រៀងរាល់ពេលដែលអ្នកបើកគម្ពីររបស់អ្នក ហើយធ្វើការកត់ត្រា យ៉ាងហោចណាស់សេចក្ដីពិតមួយដែលព្រះបានមានបន្ទូលមកកាន់អ្នក។ ជួនកាលវាមានការងាយស្រួលសម្រាប់ការរំពឹងគិតលើព្រះបន្ទូល ប្រសិនបើអ្នកសរសេរនូវគំនិតរបស់អ្នក ឬក៏វាអាចជាការល្អ ត្រលប់ទៅអានការពីមុនដែលព្រះមានបន្ទូលមកកាន់អ្នកនៅក្នុងចិត្ត។ នេះគឺជាលក្ខណៈឯកជន និងជាការប្រពៃបំផុតរវាងអ្នកហើយ និងចៅហ្វាយរបស់អ្នក។

*ខ្ញុំសូមលើកទឹកចិត្តឱ្យលោកអ្នកធ្វើការប្ដេជ្ញាចិត្តដោយខ្លួនអ្នកផ្ទាល់ និងជាមួយក្រុមរបស់អ្នកសម្រាប់ការនោះក្នុងរយៈពេលមួយសប្ដាហ៍។ អ្នកនឹងស្មោះត្រង់ក្នុងការចំណាយពេលយ៉ាងហោចណាស់១៥នាទីជាមួយព្រះវបិតាដោយផ្ទាល់ខ្លួន។ ប្រសិនបើអាចសរសេរនូវពីការមួយក្នុងមួយថ្ងៃដែលព្រះមានបន្ទូលមកកាន់អ្នក។ ប្រសិនបើជាលោកអ្នកមិនចេះអានរកអ្នកណាម្នាក់ដែលអាចអានសម្រាប់អ្នកអាចអានមួយខក្នុងមួយថ្ងៃនៅសប្ដាហ៍បន្ទាប់ ហើយរង់ចាំមើលតើនឹងមានអ្វីកើតឡើង នៅពេលដែលអនុញ្ញាតិឱ្យព្រះបន្ទូលរបស់ព្រះជ្រាតចូលក្នុងជម្រៅចិត្តរបស់អ្នកជារៀងរាល់ថ្ងៃ។

*សូមយើងទាំងអស់គ្នាបន្តអានខនេះ។ សូមកុំអានប្រញាប់ឱ្យឆាប់ចប់មួយជំពូកក្នុងមួយថ្ងៃអី។ នៅពេលដែលលោកអ្នកអានចប់មួយជំពូកពេលណាក៏ដោយចាំចាប់ផ្ដើមអានជំពូកបន្ទាប់ៗទៀត។ សប្ដាហ៍ក្រោយសូមយើងទាំងអស់គ្នាមកវិញ

ហើយចែកចាយបទពិសោធន៍ផ្សេងៗដែលយើងបានទទួលនៅពេលដែលយើងរំពឹងគិតព្រះបន្ទូលរបស់ព្រះ។

# មេរៀនទី៤

# ការដកសេចក្ដីភ័យខ្លាចចេញពីអ្នកនេសាទមនុស្ស

ម៉ាថាយ ៤-៨

*«ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ មនុស្សមានជំនឿតិចអើយ! ហេតុអ្វីបានជាអ្នករាល់គ្នាភិតភ័យដូច្នេះ? ព្រះអង្គក្រោឈរឡើង មានព្រះបន្ទូលគម្រាមខ្យល់ព្យុះ និង សមុទ្រ ពេលនោះសមុទ្រក៏ស្ងប់ឈឹង» ម៉ាថាយ ៨:២៦។*

* ក្នុងនាមជាអ្នកដឹកនាំកុំភ្លេចសួរទៅសមាជិកក្រុមថា តើគេមានលទ្ធភាពក្នុងការអានគម្ពីរ និងអធិស្ឋានរាល់ថ្ងៃដែរឬទេ។ សូមឱ្យម្នាក់ៗនូវឱកាសដើម្បីចែកចាយបទពិសោធដើម្បីលើកទឹកចិត្ត និងកំសាន្តចិត្តពួកគេ។

* ប្រសិនបើការសិក្សារៀងរាល់អាទិត្យជាប្រចាំហើយ ជាការសំខាន់បើមានក្រុមដើម្បីឱ្យគេមានពេលអធិស្ឋានសំណូមពរ និងអធិស្ឋានទូលអង្វរជាមុន។

<u>រំលឹក</u> :

១- ព្យាការីអេសាយបាននិយាយថា ព្រះយេស៊ូ និងត្រូវបានគេហៅថាអេម៉ាញូអែលដែលប្រែថាព្រះ_______________________________________________។

២-នៅលើភ្នំអូលីវ ព្រះយេស៊ូបានបង្រៀនសិស្សរបស់ទ្រង់អំពីការដែលទ្រង់នឹងយាងមកលើកទីពីរ។ ទ្រង់បានប្រាប់ឱ្យពួកគេមានការប្រុងប្រយ័ត្ន ដើម្បីកុំឱ្យទទួលរងនូវ___________________________________ដោយសារព្យាការីក្លែងក្លាយ ឬក្រុមមនុស្សដែលអះអាងខ្លួនឯងថា ជាព្រះគ្រិស្ត ទោះបីជាគេអាចធ្វើការអស្ចារ្យជាច្រើនយ៉ាងណាក៏ដោយ។

៣- ព្រះយេស៊ូមានព្រះបន្ទូលថា នៅពេលដែលទ្រង់យាងត្រលប់មកកាន់ផែនដីវិញ នោះគេនឹងឃើញទ្រង់នៅក្នុង________________________________ដោយមានអំណាចដ៏អស្ចារ្យនិងសិរីរុងរឿងរបស់ទ្រង់។

៤- ព្រះយេស៊ូមានព្រះបន្ទូលថា អ្នកដែលដឹងថាពេលណាទ្រង់នឹងយាងមកផែនដីវិញ គឺមានតែម្នាក់ទេគឺ______________________________។

៥- លោកយ៉ូហានបានធ្វើបុណ្យជ្រមុជទឹកដល់មនុស្សជាច្រើនដែលប្រែចិត្តអំពី________________________________របស់ពួកគេ។

៦- មុនពេលដែលព្រះគ្រិស្តយាងត្រលប់ទៅស្ថានសួគ៌វិញ ទ្រង់បានបញ្ជាអស់ទាំងសិស្សរបស់ទ្រង់______________________________។

៧- លោកយ៉ូហានបានមានប្រសាសន៍ថា មួយអង្គដែលនឹងមកដល់ហើយបែងចែកមនុស្សនៅលើពិភពលោកនេះ និងអស់អ្នកដែលបដិសេធទ្រង់នោះនឹងត្រូវទទួលទោសដែលមិនចេះ______________________________។

៨- នៅក្នុងសេចក្តីល្បួងពីរលើកដំបូងរបស់ព្រះគ្រិស្ត អារក្សព្យាយាមល្បួងលោមឱ្យទ្រង់ធ្វើការអស្ចារ្យដែលអាចបង្ហាញថា ទ្រង់គឺជា______________។

៩- នៅក្នុងសេចក្តីល្បួងទីបីអារក្សបានសុំឱ្យព្រះយេស៊ូ______________វា។

១០- ព្រះយេស៊ូបានឆ្លើយទៅសាតាំងបីដងដោយប្រើ__________នៃ__________

១១- ប្រសិនបើយើងចង់ស្គាល់ព្រះថែមទៀតនោះ ជាការចាំបាច់ក្នុងការចំណាយពេល______________________________ជាមួយទ្រង់រាល់ថ្ងៃ។

១២- តើអ្វីទៅជានិស្ស័យពីរនៅក្នុងយើងដែលតែងតែប្រឆាំងគ្នា? គឺ__________និង______________។

១៣- ប្រសិនបើយើងចង់ឈ្នះនូវសេចក្តីល្បួងវាជាការចាំបាច់ក្នុងការដែលយើងត្រូវចំណាយពេលម្នាក់ឯងជាមួយ____________________ជារៀងរាល់ថ្ងៃ។

១៤- ប្រសិនបើយើងចង់បានដូចជាព្រះគ្រិស្ត វាជាការចាំបាច់ក្នុងការចំណាយពេលវេលាម្នាក់ឯងជាមួយទ្រង់______________________________។

ព្រះយេស៊ូចាប់ផ្តើមបេសកកម្មរបស់ទ្រង់ក្រោយពេលដែលទ្រង់យាងមកពីទីរហោស្ថាន។ គឺទ្រង់បានទៅគ្រប់ទីកន្លែងជុំវិញសមុទ្រកាលីឡេ ហើយនិងបានទ្រង់ផ្ទាល់បានស្នាក់ឱ្យនៅក្រៅពីទីក្រុងនៃស្រុកកាពើណិម។ ទ្រង់បានអធិប្បាយនៅទីនោះនូវប្រធានបទតែមួយដូចដែលលោកយ៉ូហានបានអធិប្បាយ *«ចូរប្រែចិត្តព្រោះនគររបស់ព្រះមកដល់ហើយ»*។

សិស្សពីរនាក់ដំបូងរបស់ព្រះគ្រិស្ត គឺពេត្រុស និងអន់ទ្រេដែលបងប្អូនទាំងពីរនាក់នេះកំពុងតែបង់សំណាញ់ក្នុងសមុទ្រកាលីឡេ ដើម្បីព្យាយាមចាប់ត្រី នោះព្រះគ្រិស្តបានហៅគេថា *«មកតាមខ្ញុំនោះខ្ញុំនឹងឱ្យអ្នករាល់គ្នាក្លាយទៅជាអ្នកនេសាទមនុស្ស»*។

ពីពេលនោះ មកទ្រង់ក៏បានបន្តដំណើររហូតបានជួប និងបុរសម្នាក់ និងកូនប្រុសពីរនាក់របស់គាត់ដែលកំពុងតែអង្គុយនៅក្នុងទូកនេសាទ កំពុងជួសជុលសំណាញ់របស់ពួកគេ។ ទ្រង់ក៏បានហៅកូនប្រុសទាំងពីរនោះឱ្យមកតាមទ្រង់គេទាំងនោះមានឈ្មោះថា យ៉ាកុប និងយ៉ូហាន និងឪពុកមានឈ្មោះថាសេបេដេ។

ដូច្នេះ ព្រះយេស៊ូបានធ្វើដំណើរជុំវិញតំបន់នោះ ដើម្បីបង្រៀននៅក្នុងសាលាប្រជុំរបស់ជនជាតិយូដា។ ផ្សាយដំណឹងអំពីនគររបស់ព្រះ ហើយនិងព្យាបាលជំងឺគ្រប់ប្រភេទ។ នាមរបស់ទ្រង់កាន់តែល្បីឡើងៗរហូតដល់ប្រទេសជិតខាងដូចជាប្រទេសសេរីក៏ចូលមកឱ្យទ្រង់ព្យាបាលជំងឺឱ្យដែរ។

ដូច្នេះ នៅពេលដែលព្រះគ្រិស្តបានឃើញហ្វូងមនុស្សមកតាមនោះទ្រង់ក៏បានហៅសិស្សរបស់ទ្រង់ទៅលើកំពូលភ្នំ។ នៅ ទី នោះ ទ្រង់ ក៏ បាន អង្គុយ ចុះ ហើយបង្រៀនសិស្សរបស់ទ្រង់ពីនគររបស់ព្រះ។ ពេលដែលឮសេចក្តីបង្រៀនទាំងនោះហ្វូងមនុស្សមានការចម្លែកចិត្តយ៉ាងខ្លាំង ព្រោះពួកគេមិនដែលបានឮសេចក្តីបង្រៀនណាដែលមានអំណាចដូចជាសេចក្តីបង្រៀនរបស់ទ្រង់ទេ។

នៅពេលដែលព្រះយេស៊ូយាងចុះមកពីលើភ្នំវិញ នោះហ្វូងមនុស្សបានកកកុញតាមទ្រង់គ្រប់ទីកន្លែង។ មានមនុស្សកើតឃ្លង់ម្នាក់បានមកឯព្រះយេស៊ូសុំឱ្យទ្រង់ព្យាបាលជំងឺរបស់ខ្លួនរំពេចនោះជំងឺរបស់គេក៏បានជា។ ហើយជាមួយគ្នាផងនោះដែរក៏មានទាហានរ៉ូមម្នាក់បានសុំឱ្យព្រះយេស៊ូជួយព្យាបាលជំងឺដល់អ្នកបម្រើរបស់ខ្លួនដែលដេកឈឺនៅឯផ្ទះ ព្រះយេស៊ូក៏បានព្យាបាលជំងឺអ្នកបម្រើរបស់ទាហានរ៉ូមនោះឱ្យជា។

ព្រះយេស៊ូក៏បានយាងទៅផ្ទះរបស់ពេត្រុសដោយសារតែម្តាយក្មេករបស់ពេត្រុសមានជំងឺយ៉ាងធ្ងន់។ ព្រះយេស៊ូបានប៉ះដៃអ្នកជំងឺ នោះជំងឺរបស់គាត់ក៏ចាកចេញពីខ្លួនគាត់ទៅរំពេចនោះ គាត់ក៏បានក្រោកឡើង ហើយបម្រើគ្រប់គ្នានៅក្នុងផ្ទះ។ ដូច្នេះ ហើយព្រះយេស៊ូក៏បានស្នាក់នៅទីនោះ ហើយមើលជំងឺ និងដេញអារក្សអស់ជាច្រើន។ ប៉ុន្តែ នៅ ពេលដែល ទ្រង់បាន ឃើញ បណ្តាជន យ៉ាងច្រើនចោមរោម

ព្រះអង្គ នោះក៏បង្គាប់សិស្សទ្រង់ឱ្យទៅត្រើយម្ខាងនៃសមុទ្រកាលីឡេ។ពេលនោះយប់កាន់តែជ្រៅ គេចាកចេញដំណើរទៅមួយត្រើយម្ខាងនៃសមុទ្រនោះ។រំពេចនោះពេលទូកចេញទៅដល់ពាក់កណ្ដាលក៏ស្រាប់តែមានខ្យល់ព្យុះបក់បោកមកលើ ទូកដោយមានរលកយ៉ាងធំៗ សិស្សដែលភាគច្រើនសុទ្ធតែជាអ្នកនេសាទនោះបានដឹងថា នឹងពួកគេកំពុងតែនៅក្នុងសភាពគ្រោះថ្នាក់ នោះក៏មានការស្លន់ស្លោរ និងភ័យយ៉ាងខ្លាំង។ នៅពេលនោះព្រះយេស៊ូកំពុងតែផ្ទុំលក់ដោយមិនដឹងខ្លួនសោះ។

សិស្សរបស់ទ្រង់បានមកទាំងភ័យដើម្បីដាស់ទ្រង់ «ព្រះអម្ចាស់ជួយពួកយើងផងយើងស្លាប់ឥឡូវហើយ» នោះព្រះយេស៊ូក៏មានព្រះបន្ទូលថា «ឱអ្នកដែលមានជំនឿតិចអើយហេតុអ្វីបានជាអ្នកភ័យខ្លាំងម្លេះ»។ បន្ទាប់មកទ្រង់បានក្រោកឈរឡើង ហើយបាននិយាយទៅកាន់សមុទ្រ និងខ្យល់ស្រាប់តែមានភាពស្ងប់ស្ងាត់លើពេញទាំងផ្ទៃទឹក។ សិស្សទាំងអស់មានការនឹកស្ងើចក៏និយាយថា *«តើមនុស្សនេះជាមនុស្សបែបយ៉ាងណាបានជាទាំងខ្យល់ និងសមុទ្រក៏ស្ដាប់បង្គាប់លោកដូច្នេះ»។*

## សំណួរផ្ទាល់មាត់

១- តើព្រះយេស៊ូបានអធិប្បាយអំពីអ្វីទៅកាន់ហ្វូងមនុស្ស?
២- តើសិស្សពីរនាក់ដំបូងរបស់ព្រះយេស៊ូមានឈ្មោះអ្វី?
៣- តើសិស្សដំបូងនេះមានមុខរបរជាអ្វី?
៤- ហេតុអ្វីបានជាប្រជាជនចង់ឃើញព្រះយេស៊ូខ្លាំងម្ល៉េះ?
៥- ហេតុ អ្វី បាន ជា អ្នក ដើរ តាម ព្រះយេស៊ូ មាន ការ ស្ងើច សរសើរ នូវ អ្វី ដែល ព្រះយេស៊ូបានបង្រៀននៅលើកំពូលភ្នំ?
៦- ក្រោយ ពេល ដែល ព្រះយេស៊ូ យាង ចុះ ពី លើ ភ្នំ មកវិញ ទ្រង់ បាន ព្យាបាល ជំងឺ មនុស្សម្នាក់ តើគាត់មានជំងឺអ្វីដែរ?
៧- ទ្រង់ក៏បានព្យាបាលអ្នកបម្រើរបស់ទាហានរ៉ូម តើអ្នកបម្រើនោះកើតអ្វីដែរ?
៨- ព្រះយេស៊ូបានព្យាបាលសាច់ញ្ញាតិម្នាក់របស់ពេត្រុស តើគាត់ត្រូវជាយ៉ាងម៉េច និងពេត្រុស?
៩- ហេតុអ្វីបានជាព្រះយេស៊ូធ្វើដំណើរទៅឯម្ខាងទៀតនៃសមុទ្រកាលីឡេ?
១០- តើព្រះយេស៊ូបានធ្វើអ្វីនៅលើទូក?
១១- ហេតុអ្វីបានជាសិស្សរបស់ព្រះយេស៊ូមានការភ័យខ្លាច?
១២- ហេតុអ្វីបានជាព្រះយេស៊ូស្ដីបន្ទោសពួកគេ?
១៣- តើសិស្សរបស់ទ្រង់មានប្រតិកម្មយ៉ាងដូចម្ដេចពេលដែលកគេឃើញព្រះយេស៊ូ បានបង្ក្រាបខ្យល់ព្យុះ?

# មេរៀនទី៤

# សេចក្ដីពិតខាងវិញ្ញាណ

ម៉ាថាយ ៤-៨

១- ព្រះយេស៊ូត្រាស់ហៅយើង**ទាំងអស់គ្នា**ឱ្យធ្វើជាអ្នក «នេសាទមនុស្ស»។ សេរីភាពដែលយើងមាននៅក្នុងព្រះគ្រិស្ត គឺជាអ្វីដែលព្រះយេស៊ូបង្គាប់ឱ្យយើងចែកចាយដល់មនុស្សគ្រប់ប្រទេស ទីក្រុង និងអ្នកជិតខាងទាំងអស់នៅលើពិភពលោក។ ទាំងនេះជាពាក្យចុងក្រោយរបស់ទ្រង់ ដល់សាវ័ករបស់ទ្រង់មុនពេលដែលទ្រង់យាងទៅស្ថានសួគ៌។ នៅចុងសប្ដាហ៍ក្រោយនៃការសិក្សានេះ យើងនឹងរៀនអំពីរបៀបដើម្បីចែកចាយសេចក្ដីជំនឿរបស់យើងឱ្យកាន់តែច្បាស់ថែមទៀត។ ទោះបីជាមានមនុស្សនៅក្នុងចំណោមពួកយើង នៅមានការខ្លាចក្នុងការចែកចាយពីព្រះគ្រិស្តប្រាប់ដល់អ្នកដទៃទៀតយើងត្រូវគិតថា «ខ្ញុំជានរណាតើខ្ញុំមានអំណាចអ្វីដើម្បីនាំមនុស្សមកដើរតាមព្រះគ្រិស្ត»? ហើយទោះបើជាខ្ញុំអាចមែន ក៏ខ្ញុំជាមនុស្សម្នាក់ដែលរស់នៅក្នុងផ្នែកតូចមួយនៃពិភពលោកតែប៉ុណ្ណោះ។ តើអាចធ្វើឱ្យព្រះគ្រិស្តរំពឹងថា ខ្ញុំអាចធ្វើឱ្យមានការខុសប្លែកខ្លះនៃផែនដីបានយ៉ាងម៉េច?

ព្រះគម្ពីរបានបង្រៀនយើងថា ទោះបីយើងមានទេពកោសល្យ ពូកែនិយាយយ៉ាងណាក៏ដោយ យើងក៏មិនអាចនាំមនុស្សឱ្យមកដើរតាមព្រះគ្រិស្តបានឡើយ។ នៅពេលដែលយើងថ្វាយចិត្តរបស់យើងទៅដល់ព្រះហើយ គឺមិនមែនជាមនុស្សដែលបណ្ដាលយើងឱ្យនិយាយនោះទេ តែព្រះវិញ្ញាណបរិសុទ្ធនៃព្រះជាអ្នកដែលធ្វើឱ្យយើងប្រែចិត្ត។ នៅក្នុងគម្ពីរយ៉ូហាន ១៦:៨ *«កាលណាទ្រង់បានយាងមកហើយនោះ ទ្រង់នឹងសម្តែងឱ្យមនុស្សដឹងច្បាស់ អំពីអំពើបាបសេចក្តីសុចរិតហើយ និងសេចក្តីជំនុំជំរះ»*។

តួនាទីរបស់យើងដែលជាអ្នកនេសាទមនុស្ស គឺកាន់សំណាញ់នៃជីវិតរបស់យើង ហើយនាំអស់ទាំងត្រីដែលព្រះវិញ្ញាណបរិសុទ្ធបាននាំមកឱ្យយើង។ ជំហានដំបូងបំផុតក្នុងការចែកចាយសេចក្តីជំនឿរបស់យើងពីព្រះគ្រិស្តដល់អ្នកផ្សេងគឺ ជាការចែកចាយនូវអ្វីដែលព្រះគ្រិស្តបានធ្វើការនៅក្នុងជីវិតរបស់យើង។ ការនេះហៅ

ថា «ទីបន្ទាល់»។ ពាក្យថា ធ្វើទីបន្ទាល់ (សាក្សី) ជាពាក្យដែលប្រើក្នុងច្បាប់តុលាការ។ ស្មរបន្ទាល់ ឬសាក្សី គឺបញ្ជាក់លើការអ្វីដែលគេបានដឹងថា ជាការពិតអ្វីដែលពួកគេបានដឹងច្បាស់។ មនុស្សដទៃអាចចោទប្រកាន់ថា អ្នកជាមនុស្សឆ្កួត ហើយមិនជឿលើទីបន្ទាល់មនុស្ស ប៉ុន្តែពួកគេមិនអាចបដិសេធនូវអ្វីដែលលោកអ្នកបានដឹងនោះទេ។

<u>នេះជាលំហាត់ដែលយើងត្រូវធ្វើទាំងអស់គ្នា</u>

- សូមឱ្យគ្រប់គ្នាគិតត្រលប់ក្រោយវិញអំពីជីវិតរបស់គេមុនពេលដែលបានស្គាល់ព្រះគ្រិស្ត។
- បន្ទាប់មកគិតពីរបៀបដែលគេនាំអ្នកឱ្យបានស្គាល់ព្រះគ្រិស្ត។
- គិតអំពីព្រះវិញ្ញាណបរិសុទ្ធយាងចូលមកប៉ះពាល់ចិត្តរបស់អ្នក ហើយអ្នកបានដឹងថាព្រះយេស៊ូគ្រិស្ត គឺជាព្រះជាម្ចាស់ ហើយជីវិតរបស់អ្នកត្រូវការទ្រង់។
- គិតពីការដែលអ្នកបានសម្រេចចិត្តផ្តល់ជីវិតដល់ព្រះគ្រិស្ត។
- នៅចុងក្រោយគិតអំពីការផ្លាស់ប្តូរដែលព្រះគ្រិស្តបាននៅក្នុងជីវិតរបស់អ្នក។
- បន្ទាប់ពីមានពេលដើម្បីគិតពីការនេះនៅក្នុងគំនិតរបស់អ្នក សូមអង្គុយជារង្វង់ ហើយសូមឱ្យម្នាក់ៗចែកចាយទីបន្ទាល់នេះជាមួយក្រុម។

ចំណាំ : *យកល្អម្នាក់ៗកុំឱ្យចំណាយពេលលើសពីបីនាទី*

* ជាមួយគ្នាផងដែរ វាជាពេលមួយដែលក្រុមចាប់ផ្តើមជួយគ្នាទៅវិញទៅមកក្នុងការអធិស្ឋាន នៅក្នុងពេលស្ងៀមស្ងាត់របស់យើងជាមួយនិងព្រះ សម្រាប់មនុស្សទាំងនោះដែលព្រះបានបង្ហាញយើងពីតម្រូវការរបស់គាត់ដែលត្រូវទទួលទ្រង់។ អាចជាអ្នកដែលរៀនជាមួយយើង ឬធ្វើការជាមួយយើង ឬក៏ជាសមាជិកក្រុមគ្រួសាររបស់យើង ដែលមិនទាន់បានទទួលសេចក្តីស្រឡាញ់របស់ព្រះ នៅឡើយ ចូរឱ្យយើងអធិស្ឋានសម្រាប់អ្នកទាំងអស់នោះ។ សូមឱ្យទាំងអស់គ្នាសរសេរនៅក្នុងសៀវភៅអធិស្ឋាន នូវសេចក្តីសំណូមរបស់មនុស្សម្នាក់ៗនៅក្នុងក្រុម។ នេះជាការខំប្រឹងប្រែងរបស់ក្រុមទាំងអស់ ដើម្បីនាំមនុស្សគ្រប់គ្នាទៅឯព្រះគ្រិស្ត។

* ប៉ុន្តែ សូមកុំឱ្យយើងភ្លេចដល់អស់អ្នកដែលរស់នៅឆ្ងាយពីយើងគឺយើងគួរតែអធិស្ឋានឱ្យមនុស្សទាំងអស់នោះផង។

* គំនិតរបស់អ្នកដឹកនាំ ប្រហែលជាអ្នក ឬក៏គ្រូគង្វាលរបស់អ្នកស្គាល់បេសកជន ដែលរស់នៅក្នុងប្រទេសផ្សេង ឬក៏ខេត្តផ្សេងនៅក្នុងប្រទេសនេះ។ ដូច្នេះ សូមយើង អធិស្ឋានសម្រាប់មនុស្សទាំងនោះ គ្រួសាររបស់ពួកគេ និងមនុស្សដែលគេកំពុងតែ ធ្វើការជាមួយ។ សូមធ្វើរបៀបនេះជារៀងរាល់សប្តាហ៍ នៅក្នុងពេលអធិស្ឋានទូល អង្វរ។ តើមាននរណាម្នាក់នៅក្នុងក្រុមបានសរសេរពីតំរូវការពិសេសរបស់បេសក ជនដែលសំណូមអធិស្ឋានទេ? ចូរអធិស្ឋានអំពីការនោះ ហើយស្វែងរកវិធីដែល ក្រុមរបស់អ្នកអាចជួយចែកចាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្តដល់អស់អ្នកដែល នៅកន្លែងឆ្ងាយៗនៅលើផែនដីយើងនេះ។ សូមយើងផ្អាកហើយពិភាក្សាពីការ នេះ ឥឡូវ មុនពេលដែលឈានចូលសេចក្តីខាងវិញ្ញាណទីពីរ។

<u>២- ព្រះយេស៊ូបន្ទោសសិស្សរបស់ទ្រង់ មិនមែនដោយសារតែគេជាស់ព្រះអង្គដើម្បី ឱ្យបញ្ឈប់ខ្យល់ព្យុះនោះទេ តែដោយសារពួកគេពោរពេញដោយការភ័យខ្លាច។</u>

ពួកសាវ័កបានក្រឡេកមើលទៅខ្យល់ព្យុះ ពួកគេបានដឹងថា នេះជាខ្យល់ព្យុះដ៏ អាក្រក់មួយ។ អ្វីដែលគេមិនទាន់បានដឹងនោះ គឺអំណាចរបស់ព្រះជាម្ចាស់នៅក្នុង ជីវិតរបស់ពួកគេ។ ពួកគេមិនទាន់ដឹងច្បាស់ថា ព្រះជាម្ចាស់ធំជាងខ្យល់ព្យុះទាំង អស់នៅក្នុងជីវិតរបស់ពួកគេ ហើយទ្រង់កំពុងតែគង់នៅក្នុងទូកជាមួយនឹងពួកគេ។

ខ្ញុំមានកូនស្រីអាយុមួយឆ្នាំកន្លះម្នាក់ ដែលកំពុងចាប់ផ្តើមស្វែងយល់ពីពិភព លោកដែលនៅជុំវិញនាង។ នាងបានរត់លេងជុំវិញផ្ទះនាងបើកថតតុ បើកគ្រប ឆ្នាំង និងរបស់អ្វីៗទាំងអស់ដែលនាងអាចចាប់យកបាន។ មានថ្ងៃមួយយើងបាន ទៅផ្ទះរបស់មិត្តភក្តិ ហើយទទួលទានអាហារពេលយប់ជាមួយគ្នា។ កូនរបស់ខ្ញុំក៏ លេងនៅលើឥដ្ឋក្នុងបន្ទប់បាយ។ ខណៈពេលដែលយើងកំពុងបរិភោគនោះ ស្រាប់ តែមានឆ្កែខ្មៅធំមួយបានចូលមកក្នុងបន្ទប់ដែលយើងកំពុងហូបបាយ កូនស្រីរបស់ខ្ញុំ បានរត់យ៉ាងលឿនតាមដែលនាងអាចរត់បាន ហើយស្រែកថា «ម៉ាក់ៗ» ខ្ញុំបាន លើកនាងឡើង ពេលនោះរាងកាយរបស់នាងបានសម្រាកនៅលើដៃរបស់ខ្ញុំ។ តើ ហេតុអ្វី? ពីព្រោះនាងបានដឹងថា ខ្ញុំស្រឡាញ់នាង ហើយនាងទុកចិត្តខ្ញុំថា ខ្ញុំអាច ការពារនាងបាន។ នាងបាននៅលើដើមទ្រូងរបស់ខ្ញុំមួយសន្ទុះ ក្រោយពេលដែល នាងដឹងថានាងមានសុវត្ថិភាពហើយ នាងក៏លូកដៃ ហើយលេងជាមួយឆ្កែនោះថែម ទៀត។

យើងទាំងអស់គ្នាជាកូនរបស់ព្រះជាម្ចាស់ តាំងតែពីយើងបានឱ្យទ្រង់គ្រប់គ្រង

លើជីវិតរបស់យើងមកម្ល៉េះ។ ទ្រង់ជាអ្នកការពារយើងទ្រង់ជាអ្នកផ្តល់សុវត្ថិភាពដល់យើង និងផ្តល់សុវត្ថិភាពដល់កូនរបស់យើង។ ទ្រង់ស្រឡាញ់យើង ហើយបើយើងមានការភ័យខ្លាចសូមឱ្យយើងរត់ទៅរកទ្រង់ភ្លាម។ នៅក្នុងព្រះហស្តរបស់ទ្រង់ៗកំចាត់អស់ទាំងការភ័យខ្លាច និងគ្មានការភ័យខ្លាចឡើយ បើសិនជាយើងរស់នៅក្នុងចង្អេងស្លាបនៃការស្តាប់ង្គាប់ដល់ព្រះយេស៊ូគ្រិស្ត។

មានបុរសម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ឈ្មោះថា **ដាវិឌ**។ លោកបានឆ្លងកាត់ការលំបាក និងស្ថានភាពដ៏គួរឱ្យភ័យខ្លាចជាច្រើន គឺដោយសារតែបុរសម្នាក់ឈ្មោះ**ស្តេចសូល** ប៉ុនប៉ងចង់សម្លាប់លោក។ ហើយលោកដាវិឌបានរៀនពីសេចក្តីពិតជាច្រើនអំពីព្រះជាម្ចាស់ ហើយរីកចម្រើនក្នុងការចូលទៅជិតព្រះអង្គលោកបានសរសេរកំណាព្យជាច្រើន ដែលហៅថា «**ទំនុកដំកើង**»។ នេះជាកំណាព្យ ដែលព្រះជាម្ចាស់បានបណ្តាលឱ្យគាត់តែង ដើម្បីបង្រៀនអំពីទ្រង់។ មានកំណាព្យចំនួន ១៥០ ប៉ុន្តែមិន មែន លោកដាវិឌសរសេរទាំងអស់ទេ ប៉ុន្តែទាំងអស់ មាន នៅក្នុងព្រះគម្ពីរសញ្ញាចាស់។ លោកដាវិឌបានសរសេរកំណាព្យជាច្រើននិយាយពីការភ័យខ្លាច ប៉ុន្តែ ខ្ញុំបានជ្រើសរើសកំណាព្យមួយសម្រាប់យើងបានអាន និងរំពឹងគិតនៅក្នុងអាទិត្យនេះ គឺទំនុកដំកើង។ អាននៅពេលដែលយើងអធិស្ឋាន ប្រសិនបើអ្នកមិន មាន ព្រះគម្ពីរ សញ្ញា ចាស់ ខ្ញុំ បាន ចត ចម្លង ក្រដាស សម្រាប់ លោក អ្នក ។ សូមព្រះជាម្ចាស់ បង្រៀន លោក អ្នក ឱ្យ ចេះ ផ្ទេរ អស់ ទាំង ការ ភ័យ ខ្លាច របស់ លោក អ្នក ហើយរត់ចូលទៅក្នុងព្រះហស្តរបស់ទ្រង់ ដែលជាព្រះហស្តនៃសេចក្តីស្រឡាញ់ និងសុវត្ថិភាព។

* សូមយើងបញ្ចប់នៅអាទិត្យនេះដោយការអធិស្ឋាន។ ប៉ុន្តែ ពេលនេះសូមឱ្យយើងម្នាក់ៗស្វែងរកដៃគូរដែលមានភេទដូចគ្នា។ សូមប្រាប់គ្នាទៅវិញទៅមកអំពីការដែលកើតឡើងនៅក្នុងជីវិតរបស់លោកអ្នកដែលលោកអ្នកភ័យខ្លាចជាងគេ។ បន្ទាប់មកអធិស្ឋានឱ្យគ្នាទៅវិញទៅមកអំពីការភ័យខ្លាចនោះ។ សូមឱ្យព្រះជាម្ចាស់ដកអស់ទាំងការភ័យខ្លាចនោះ ហើយ សូមផ្តល់មកវិញ នូវសេចក្តីជំនឿ លើទ្រង់ ។ សូមប្រាប់ព្រះជាម្ចាស់ពីបំណងប្រាថ្នារបស់លោកអ្នក ហើយថ្វាយការទុកចិត្តទាំងអស់ដល់ទ្រង់ ទោះបីស្ថានការណ៍នោះអាក្រក់បែបណាក៏ដោយ។

**ទំនុកតំកើង ២៧**

¹ព្រះអម្ចាស់ជាពន្លឺ និងជាព្រះសង្គ្រោះខ្ញុំ ខ្ញុំមិនខ្លាចអ្វីឡើយ! **ព្រះអម្ចាស់** ជា

ទីជំរករបស់ជីវិតខ្ញុំ ខ្ញុំក៏មិនតក់ស្លុតចំពោះនរណាដែរ។ ២ពេលពួកអ្នកប្រព្រឹត្តិអាក្រក់
គឺបច្ចាមិត្ត និងខ្មាំងសត្រូវរបស់ខ្ញុំនាំគ្នាចូលមកជិត ដើម្បីរកប្រហាជីវិតខ្ញុំ អ្នកទាំង
នោះបែរជាត្រូវជំពប់ដួលវិញ។ ៣បើសិនជាមានកងទ័ពមកឡោមព័ទ្ធខ្ញុំ ក៏ចិត្តខ្ញុំមិន
ភ័យខ្លាចធ្វីដែរ ប្រសិនបើគេមានគ្នាលើកមកច្បាំងនឹងខ្ញុំ ខ្ញុំក៏នៅតែទុកចិត្តសង្ឃឹម
លើព្រះអម្ចាស់ជានិច្ច។ ៤ខ្ញុំទូលសូម**ព្រះអម្ចាស់**នូវសេចក្ដីតែមួយគត់ ហើយខ្ញុំប្រាថ្នា
ចង់បានតែសេចក្ដីនេះឯង គឺឱ្យបានស្នាក់នៅក្នុងព្រះដំណាក់របស់**ព្រះអម្ចាស់**អស់
មួយជីវិត ដើម្បីកោតស្ញប់ស្ញែងភាពថ្កុំថ្កើងរុងរឿងរបស់**ព្រះអម្ចាស់** និងថ្វាយបង្គំព្រះ
អង្គនៅក្នុងព្រះវិហារ ៥ដ្បិតនៅពេលខ្ញុំមានអាសន្ន ព្រះអង្គតែងតែឱ្យខ្ញុំជ្រកនៅក្នុងជំ
រករបស់ព្រះអង្គ ព្រះអង្គតែងលាក់បំពួនខ្ញុំនៅក្នុងព្រះពន្លា ព្រះអង្គលើកខ្ញុំដាក់ថ្មដា។៦
ព្រះអង្គលើកមុខខ្ញុំឡើងឱ្យខ្ពស់ជាងខ្មាំងសត្រូវដែលនៅជុំវិញខ្ញុំ ខ្ញុំនឹងថ្វាយយញ្ញបូ
ជានៅក្នុងព្រះពន្លារបស់ព្រះអង្គ ទាំងស្រែកដោយអំណរខ្ញុំនឹងច្រៀង ខ្ញុំនឹងស្មូត
ទំនុកតំកើងថ្វាយ**ព្រះអម្ចាស់** ។ ៧ឱ**ព្រះអម្ចាស់**អើយ ! សូមទ្រង់ព្រះសណ្ដាប់ស្នូរ
សម្រែករបស់ទូលបង្គំ សូមមេត្តាប្រណីសន្ដោសទូលបង្គំ និងឆ្លើយតបមកទូលបង្គំ
វិញផង។ ៨ចិត្តទូលបង្គំនឹកដល់ព្រះបន្ទូលដែលព្រះអង្គថ្លែងថា «ចូរស្វែងរកយើង»
នោះទូលបង្គំនឹងឆ្លើយថា ឱ**ព្រះអម្ចាស់**អើយ ! ទូលបង្គំស្វែងរកព្រះភ័ក្រព្រះអង្គ
ហើយ ! ៩សូមកុំលាក់ព្រះភ័ក្រនឹងទូលបង្គំ សូមកុំព្រះពិរោធ ហើយបណ្ដេញអ្នក
បម្រើព្រះអង្គ ! ឱព្រះអង្គសង្គ្រោះទូលបង្គំអើយ សូមកុំបោះបង់ចោលទូលបង្គំ
ឡើយ !។ ១០ទោះបីជាឪពុកម្ដាយរបស់ទូលបង្គំបានបោះបង់ទូលបង្គំចោលយ៉ាង
ណាក៏ដោយ ក៏**ព្រះអម្ចាស់**នៅតែទទួលទូលបង្គំជានិច្ច !។ ១១ឱ**ព្រះអម្ចាស់**អើយ !
សូមបង្រៀនទូលបង្គំឱ្យស្គាល់មាគ៌ារបស់ព្រះអង្គ សូមណែនាំទូលបង្គំឱ្យដើរតាមផ្លូវ
ត្រង់ព្រោះទូលបង្គំមានសត្រូវជាច្រើន។ ១២សូមកុំបណ្ដោយឱ្យទូលបង្គំធ្លាក់ទៅក្នុង
កណ្ដាប់ដៃបច្ចាមិត្តរបស់ទូលបង្គំឡើយ ដ្បិតមានសាក្សីក្លែងក្លាយមកនិយាយមូល
បង្កាច់ទូលបង្គំ អ្នកទាំងនោះពោលសុទ្ធតែពាក្យឃោរឃៅ។ ១៣ខ្ញុំជឿជាក់ថា នៅក្នុង
លោកនេះ ខ្ញុំនឹងឃើញសុភមង្គលមកពី**ព្រះអម្ចាស់**ជាមិនខាន។ ១៤ចូរសង្ឃឹមទុក
ចិត្តលើ**ព្រះអម្ចាស់**! ចូរមានកម្លាំង និងមានចិត្តរឹងប៉ឹងឡើង! ចូរសង្ឃឹមទុកចិត្តលើ
**ព្រះអម្ចាស់**ចុះ!។

# មេរៀនទី៥
# សេចក្តីស្រលាញ់
# ជាអត្ថន័យនៃការយាងមករបស់ព្រះគ្រិស្តនៅលើផែនដីនេះ

ម៉ាថាយ ៨-១០

*«កាលព្រះអង្គទតឃើញហ្វូងមហាបណ្តាជន ទ្រង់មានព្រះហឫទ័យអាណិតអាសូរគេពន់ពេកណាស់ ព្រោះអ្នកទាំងនោះអស់កម្លាំងល្វើយ ធ្លាក់ទឹកចិត្ត ប្រៀបបីដូចជាចៀមដែលគ្មានអ្នកគង្វាលថែទាំ» ម៉ាថាយ ៩:៣៦។*

មុនពេលចាប់ផ្តើមមេរៀននេះសូមពិនិត្យមើលថា តើមានលោកអ្នកប៉ុន្មាននាក់ដែលមានពេលដោយផ្ទាល់ខ្លួនជាមួយព្រះគ្រិស្ត។ សូមចាំថា នេះគឺមិនសម្រាប់ការបន្ទោសឬក៏ទិះតៀន តែចូរធ្វើដោយសេចក្តីស្រឡាញ់ លើកទឹកចិត្តគ្នាទៅវិញទៅមកឱ្យរស់នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ។ អញ្ជើញពួកគេឱ្យបន្តការអានព្រះគម្ពីរម៉ាថាយរហូតដល់ចប់។ សួរពួកគេបើសិនជាពួកគេបានអធិស្ឋានដល់អស់អ្នកដែលបានប្រាប់ថា ត្រូវការព្រះគ្រិស្ត។ រកមើលបើសិនជាអ្នកណាម្នាក់មានឱកាសនឹងចែកចាយទីបន្ទាល់នៅក្នុងអាទិត្យនេះ។

**<u>រំលឹក</u>៖**

១-ព្យាការីអេសាយបាននិយាយថា ព្រះយេស៊ូ និងត្រូវបានគេហៅថា អេម៉ាញូអែល ដែលប្រែថា «ព្រះ________________________»។

២- ព្រះយេស៊ូមានព្រះបន្ទូលថា នៅពេលដែលទ្រង់យាងត្រលប់មកកាន់ផែនដីវិញ នោះគេនឹងឃើញទ្រង់នៅមកនៅក្នុង____________________ដោយ មានអំណាចដ៏អស្ចារ្យ និងសិរីរុងរឿងរបស់ទ្រង់។

៣- ព្រះយេស៊ូមានព្រះបន្ទូលថា អ្នកដែលដឹងថាពេលណាទ្រង់នឹងយាងមកផែនដី

វិញមានតែម្នាក់ទេ គឺ______________________________________________។

៤- លោកយ៉ូហានបានធ្វើពិធីជ្រមុជទឹកដល់មនុស្សជាច្រើនដែលប្រែចិត្តចេញពីអំពើ
______________________________________________របស់ពួកគេ។

៥- លោកយ៉ូហានបានមានប្រសាសន៍ថា មួយអង្គដែលនឹងបំបែកមនុស្សនៅលើពិភពលោកនេះ និងអស់អ្នកដែលបដិសេធទ្រង់នោះនឹងត្រូវថ្កោលទោសទៅ____
______________________________________________។

៦- ព្រះយេស៊ូបានឆ្លើយទៅសាតាំងបីដងដោយប្រើ__________នៃ__________។

៧- ប្រសិនបើយើងចង់ដូចជាព្រះគ្រិស្ត វាជាការចាំបាច់ក្នុងការចំណាយពេលវេលាម្នាក់ឯងជាមួយទ្រង់______________________________________________។

៨- ព្រះគ្រិស្តបានហៅយើងទាំងអស់គ្នាឱ្យទៅជា «__________________មនុស្ស»។

៩- តើព្រះយេស៊ូបានធ្វើអ្វីនៅលើទូក?

១០-ហេតុអ្វីបានជាសិស្សរបស់ព្រះយេស៊ូមានការភ័យខ្លាច?

១១-ព្រះយេស៊ូបាននិយាយទៅកាន់សិស្សថា ដោយសារតែពួកគេ__________
ហើយនិងមិនមានជំនឿលើទ្រង់។

១២-ព្រះគម្ពីរបានបង្រៀនយើងថា នៅពេលដែលយើងរស់នៅក្រោមការការពាររបស់ព្រះគ្រិស្តនោះយើងមិនមានការ______________________________។

ក្រោយពីពេលដែលបានឆ្លងខ្យល់ព្យុះដ៏ភ័យខ្លាចនៅកណ្តាលសមុទ្រកាលីឡេរួចមកព្រះយេស៊ូ និងសិស្សរបស់ទ្រង់បានជួបនឹងមនុស្សពីរនាក់ដែលមានអារក្សចូល។ អ្នកទាំងពីនោះរស់នៅក្នុងផ្នូរខ្មោចរំពេចនោះមានម្នាក់ក្នុងចំណោមគេទាំងពីរបានស្រែកយ៉ាងខ្លាំង ទៅព្រះយេស៊ូ «ឱព្រះយេស៊ូ ជាព្រះរាជបុត្រានៃព្រះអើយ តើយើងហើយនឹងទ្រង់មានការអ្វីនឹងគ្នា តើទ្រង់យាងមកទីនេះដើម្បីនឹងធ្វើទុក្ខយើងមុនកំណត់ឬអី? នៅមិនឆ្ងាយពីកន្លែងដែលអារក្សបានចូលមនុស្សនោះមានអ្នកឃ្វាលជ្រូកមួយក្រុមកំពុងតែមើលសត្វជ្រូករបស់ខ្លួនក្បែរមាត់សមុទ្រ។ នោះអារក្សក៏អង្វរព្រះយេស៊ូថា បើសិនគេត្រូវចេញពីរាងកាយរបស់មនុស្សសូមទ្រង់ឱ្យគេចូលទៅក្នុងហ្វូងជ្រូក។ នោះព្រះយេស៊ូក៏មានព្រះបន្ទូលថា «ទៅ»វាក៏ចូលទៅក្នុងហ្វូងជ្រូករួចជ្រូកក៏បោលរត់ចុះតាមភ្នំចោតធ្លាក់ទៅក្នុងសមុទ្រលង់ទឹកស្លាប់ទាំងអស់ទៅ។

អ្នកឃ្វាលចៀមទាំងនោះក៏បានរត់សំដៅទៅទីក្រុង ហើយរៀបរាប់អំពីអ្វីដែលបានកើតឡើងចំពោះមនុស្សពីរនាក់នោះ និងអ្វីដែលកើតឡើងចំពោះជ្រូករបស់ពួកគេ។ មនុស្សនៅទីក្រុងនោះក៏ចេញមកអង្វរឱ្យព្រះយេស៊ូចេញពីតំបន់របស់គេ។ នោះទ្រង់ក៏យាងឡើងទៅលើទូកវិលទៅកាលីឡេវិញ។

នៅពេលដែលទ្រង់បានយាងទៅដល់កាលីឡេនោះមានគេនាំមនុស្ស ខ្វិនម្នាក់មកឱ្យទ្រង់ ទ្រង់ក៏បានព្យាបាលជំងឺរបស់គេ ហើយថែមទាំងបានអត់ទោសបាបឱ្យគេទៀតផង។ អស់អ្នកដែលបានឃើញមានការស្ញើច និងសរសើរដល់ព្រះតែពួកអាចារ្យផារិស៊ីបានគិតថា ព្រះជាអ្នកបោកប្រាស់។

ពេល ដែល ចេញ ពី ទី នោះ ព្រះយេស៊ូ បាន ជួប នឹង អ្នក យក ពន្ធ ម្នាក់ ឈ្មោះ ម៉ាថាយ។ ទ្រង់បានហៅម៉ាថាយឱ្យដើរតាមទ្រង់ ហើយម៉ាថាយក៏ព្រមដើរតាម។ ព្រះយេស៊ូបានទៅបរិភោគជាមួយពួកអ្នកយកពន្ធដទៃ និងក្រុមមនុស្សដែលមានឈ្មោះមិនល្អឯទៀតនៅក្នុងទីក្រុង។ នៅពេលដែលពួកផារិស៊ីបានឃើញក៏សួរទៅសិស្សរបស់ទ្រង់ថា ហេតុអ្វីបានជាព្រះយេស៊ូធ្វើដូច្នេះ។ នោះព្រះយេស៊ូក៏ឆ្លើយទៅកាន់គេថា «អញចង់បានសេចក្ដីមេត្តាមិនមែនយញ្ញបូជាទេ»។

ព្រះយេស៊ូបានធ្វើដំណើរជួបមនុស្សគ្រប់ប្រភេទទាំងអស់។ នោះទ្រង់ក៏បានជួប និងបុរសម្នាក់ដែលជាអ្នកធំក្នុងចំណោមក្រុមរបស់គាត់។ បុរសនោះមានកូនស្រីម្នាក់ដែលបានស្លាប់។ ព្រះយេស៊ូក៏បានយាងទៅចូលរួមក្នុងបុណ្យសពនោះទ្រង់លូកព្រះហស្តទាញដៃនាងនោះ ហើយនាងបានរស់ពីសេចក្ដីស្លាប់មកវិញ។

ទ្រង់ក៏បានព្យាបាលដល់មនុស្សខ្វាក់ពីរនាក់ឱ្យបានភ្លឺឡើងវិញ ក្រោយពេលដែល អ្នកទាំងពីរនោះដើរ តាម ទ្រង់ ហើយ សុំ ឱ្យ ទ្រង់ ព្យាបាល ។ ទ្រង់ បាន ធ្វើឱ្យ មនុស្សគរជាច្រើនបាននិយាយរួច ហើយ ក៏បានដេញ អារក្ស ចេញពីមនុស្ស ជាច្រើនដែរ អ្នកទាំងអស់នោះក៏បានជាសះស្បើយ។

ព្រះយេស៊ូបានឃើញសេចក្ដីត្រូវការជាច្រើនរបស់មនុស្ស ដែលគួរឱ្យអាណិតមេត្តា។ សេចក្ដីត្រូវការរបស់ពួកគេធំធេងណាស់។ ប្រជាជនទាំងនេះរស់នៅហាក់បីដូចជាចៀមដែលគ្មានអ្នកគង្វាល។ ព្រះយេស៊ូមានបន្ទូលទៅសាវ័ករបស់ទ្រង់ថា *«ចម្រូតធំណាស់ តែអ្នកច្រូតតិចទេ ដូច្នេះ សូមអធិស្ឋានដល់ព្រះជាម្ចាស់នៃចម្រូត សូមប្រទានអ្នកច្រូតមកក្នុងចំរូតទ្រង់»*។

បន្ទាប់មក ទ្រង់ក៏បានបញ្ជូនសិស្សរបស់ទ្រង់ទៅគ្រប់ទីកន្លែងនៅក្នុងស្រុក

អ៊ីស្រាអែល ។ ទ្រង់បាន ប្រទាន អំណាចឱ្យពួកគេបាន បំពេញ នូវ តម្រូវ ការ របស់ប្រជាជន ។ តួនាទីរបស់ពួកគេគឺដើម្បីរចែកចាយ និងបង្ហាញនូវសេចក្តីស្រឡាញ់របស់ទ្រង់ ។ ទ្រង់បាន ធ្វើការណែនាំគេ យ៉ាង ជាក់លាក់ថា ឱ្យទៅស្វែងរកមនុស្សដែលចង់ស្តាប់ដំណឹងល្អរបស់ទ្រង់ ។ ហើយទ្រង់ក៏ប្រាប់គេទៀតថា នៅពេលដែលគេបានជួបនឹងមនុស្សប្រភេទនោះហើយ ឱ្យពួកគេប្រទាននូវសេចក្តីសុខសាន្តរបស់ព្រះដល់អ្នកនោះ ។ ប៉ុន្តែ ទ្រង់ក៏បានដាស់តឿនគេដែរថា នឹងមានមនុស្សជាច្រើនបដិសេធមិនទទួលពួកគេ និងព្រះបន្ទូលរបស់ទ្រង់។

ទ្រង់បានមានបន្ទូលទៅកាន់ពួកគេថា «ខ្ញុំបញ្ជូនអ្នកឱ្យទៅដូចជាចៀមនៅកណ្តាលហ្វូងសត្វចចក។ ដូច្នេះ ចូរឆ្លាតដូចជាសត្វពស់ ហើយស្លូតដូចជាសត្វព្រាប»។ ទ្រង់បាន ប្រាប់ពួកគេកុំឱ្យមានការព្រួយបារម្ភពីសេចក្តីត្រូវការខាងរាងកាយ ព្រោះព្រះបិតាទ្រង់ដឹងគ្រប់ទាំងសរសៃសក់ដែលមាននៅលើក្បាលរបស់លោកអ្នក។ ទ្រង់គ្រប់គ្រងលើគ្រប់ទាំងអស់ ហើយទ្រង់ឱ្យតំលៃយើងធំណាស់។

ទ្រង់បានសរុបការណែនាំរបស់ទ្រង់មុនពេលដែលទ្រង់បញ្ជូនពួកគេដោយមានបន្ទូលថា «អ្នកណាឱ្យទឹកត្រជាក់ សូម្បីតែមួយកែវដល់អ្នកដែលតូចតាចម្នាក់ក្នុងនាមជាសាវ័ករបស់ខ្ញុំ ខ្ញុំសូមប្រាប់ឱ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកនោះនឹងទទួលរង្វាន់ជាមិនខាន»។

## សំណួរផ្ទាល់មាត់

១- តើព្រះយេស៊ូបានជួបអ្នកណាក្រោយពេលដែលទ្រង់បានឆ្លងសមុទ្រកាលីឡេជាមួយសិស្សរបស់ទ្រង់?

២- តើបុរសពីរនាក់នោះកើតអ្វី?

៣- តើព្រះយេស៊ូបានធ្វើអ្វីទៅលើគេ?

៤- ហេតុអ្វីបានជាជ្រូករត់ទៅក្នុងសមុទ្រ?

៥- តើព្រះយេស៊ូបានធ្វើអ្វីដល់មនុស្សខ្វិននោះ?

៦- ហេតុអ្វីបានជាមនុស្សនៅក្នុងភូមិនោះសុំឱ្យព្រះយេស៊ូចេញពីស្រុករបស់គេ?

៧- ហេតុអ្វីបានជាអាចារ្យផារិស៊ីហៅព្រះគ្រិស្ដថាជាអ្នកបោកប្រាស?

៨- តើអ្នកទារពន្ធដែលព្រះយេស៊ូបានជួប ហើយហៅមកធ្វើជាសិស្សនោះមានឈ្មោះអ្វី?

៩- ហេតុអ្វីបានជាពួកអាចារ្យផារិស៊ីធ្វើការរិះគន់ដល់ព្រះយេស៊ូ ពីការដែលទ្រង់បរិភោគជានៅទីមួយពួកអ្នកទារពន្ធនោះ?

១០- តើព្រះយេស៊ូបានតបទៅនឹងអ្នកទាំងនោះថាយ៉ាងម្ដេច?

១១- តើព្រះយេស៊ូបានធ្វើអ្វីខ្លះទៅកាន់កូនស្រីរបស់អ្នកធំម្នាក់នោះ?

១២- តើព្រះយេស៊ូបានធ្វើអ្វីទៅកាន់មនុស្សខ្វាក់នោះ?

១៣- តើព្រះគ្រិស្ដប្រោសមនុស្សគ នោះយ៉ាងដូចម្ដេច?

១៤- តើព្រះគ្រិស្ដបានបញ្ជូនសិស្សរបស់ទ្រង់ទៅធ្វើអ្វី?

១៥- ព្រះគ្រិស្ដបានប្រាប់សិស្សរបស់ទ្រង់ឱ្យឆ្លាតដូចជា______________ហើយសុភាពដូចជា__________________។

១៦- តើទ្រង់បានប្រាប់គេកុំឱ្យមានការបារម្ភអំពីអ្វី?

១៧- ទ្រង់បានមានព្រះបន្ទូលថា ព្រះទ្រង់ជ្រាបនូវសព្វអ្វី «ទាំងអស់ សូម្បីតែ_____ _________________________________ដែលយើងមាន»។

១៨- ទ្រង់បានមានព្រះបន្ទូលទៅគេថា ប្រសិនអ្នកណាឱ្យទឹកត្រជាក់តែមួយកែវទៅឱ្យក្រុមមនុស្សនោះ នោះពួកគេនឹងទទួលបានរង្វាន់។ តើក្រុមមនុស្សណាដែលទ្រង់បាននិយាយសំដៅលើនោះ?

## មេរៀនទី៥

# សេចក្ដីពិតខាងវិញ្ញាណ

ម៉ាថាយ ៨-១០

១- ព្រះយេស៊ូយកចិត្តទុកដាក់ចំពោះមនុស្សទាំងអស់: ទ្រង់យកចិត្តទុកដាក់ដល់អ្នកដែលមានអារក្សចូល អ្នកជំងឺ អ្នកក្រ អ្នកមានទ្រព្យសម្បត្តិ ជាពិសេសជាមួយក្មេងៗ។ មនុស្សទាំងអស់ទាំងអស់គ្នាមានតំលៃនៅក្នុងនគរព្រះ!

២- មនុស្សតែងតែមិនខ្វល់ខ្វាយចំពោះមនុស្សដ៏ទៃ: នៅក្នុងរឿងដែលព្រះយេស៊ូបានដេញអារក្សចេញពីមនុស្សនោះ មនុស្សនៅក្នុងទីក្រុងគេមិនសប្បាយចិត្តទេដោយសារការបាត់បង់ជ្រូកនោះ ហើយពួកគេចង់ឱ្យព្រះយេស៊ូយាងចេញពីតំបន់របស់ពួកគេ។ ពួកគេមិនបានគិតពីការដែលព្រះយេស៊ូបានជួយបុរសដែលមានអារក្សចូលនោះទេ។ ពួកគេខ្វល់ខ្វាយតែពីប្រាក់កាស់ដែលពួកគេបាត់បង់។ ជាការងាយស្រួលណាស់ក្នុងការឱ្យតម្លៃលុយខ្ពស់ជាងមនុស្ស។ ដែលជាការគួរឱ្យសោកស្ដាយពួកយើងជាច្រើនបានធ្លាក់ទៅក្នុងអន្ទាក់នោះដែរ។ ១ធីម៉ូថេ ៦:១០ *«ដ្បិតការស្រឡាញ់ប្រាក់ ជាឫសគល់នៃអំពើអាក្រក់គ្រប់បែបយ៉ាង។ ដោយបណ្ដោយខ្លួនឱ្យស្រឡាញ់ប្រាក់ដូច្នេះ លោកអ្នកខ្លះបានវង្វេងឆ្ងាយចេញពីសេចក្ដីជំនឿ ព្រមទាំងធ្វើបាបខ្លួនឯងឱ្យវេទនា ឈឺផ្សាជាច្រើនថែមទៀតផង»*។

លោកអ្នកប្រហែលជាចាំព្រះបន្ទូលរបស់ព្រះនៅក្នុងម៉ាថាយ *៦:១៩-២១ «កុំឱ្យសន្សំទ្រព្យសម្បត្តិទុកសម្រាប់ខ្លួន នៅលើផែនដី ជាកន្លែងដែលមានកណ្ដុរនិងច្រែះស៊ីជាកន្លែងដែលមានចោរទំលាយជញ្ជាំងចូរមកលួចប្លន់នោះឱ្យសោះ។ចូរប្រមូលទ្រព្យសម្បត្តិទុកនៅស្ថានបរមសុខវិញ ជាស្ថានដែលគ្មានកណ្ដៀរ និង ច្រែះស៊ី ជាស្ថានដែលគ្មានចោរទំលាយជញ្ជាំងមកលួចប្លន់ឡើយ។ ដ្បិតទ្រព្យសម្បត្តិអ្នកនៅកន្លែងណា ចិត្តរបស់អ្នកក៏នៅកន្លែងនោះដែរ»*។ លុយគឺមានអំណាចខ្លាំងណាស់ វាអាចគ្រប់គ្រងយើង ឬក៏យើងអាចប្រគល់វាឱ្យទៅព្រះជាម្ចាស់ ហើយឱ្យទ្រង់គ្រប់គ្រងយើងវិញ។

* ចូរគិតថា តើអ្នកចំណាយលុយរបស់អ្នកដោយរបៀបណានៅរៀងរាល់អាទិត្យ? ល្អបើយើងអាចសរសេរទុកនូវរាល់ការចំណាយនោះ។

* សួរខ្លួនឯងថា តើខ្ញុំបានថ្វាយកិត្តិយសដល់ព្រះគ្រិស្តតាមរយៈការចំណាយលុយរបស់ខ្ញុំទេ?

* តើខ្ញុំបានទិញរបស់ ឬក៏ធ្វើអ្វីមួយដែលមិនបានថ្វាយកិត្តិយសដល់ព្រះជាម្ចាស់? តើខ្ញុំធ្វើឱ្យអ្នកផ្សេងឈឺចាប់តាមរយៈការចំណាយលុយរបស់ខ្ញុំឬ? តើខ្ញុំបានជួយអ្នកដទៃតាមរយៈការចំណាយលុយរបស់ខ្ញុំឬទេ?

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះបានតម្រូវឱ្យមនុស្សគ្រប់គ្នាថ្វាយនូវដង្វាយមួយភាគដប់ (១០%)។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មីបានប្រាប់យើងថា យើងត្រូវប្រគល់ជីវិតរបស់យើង និងរបស់អ្វីៗតាំងអស់ដែលយើងមានទៅដល់ព្រះជាម្ចាស់។ ប៉ុន្តែ តាំងពីយូរយារណាស់មកហើយ យើងបានធ្វើតាមច្បាប់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយបានថ្វាយ ១០% នៃថវិកាដែលយើងរកបានសម្រាប់ការងាររបស់ព្រះជាម្ចាស់ឬក៏សម្រាប់ក្រុមជំនុំ ដែលនេះគេហៅថា «ដង្វាយមួយភាគដប់»។ សូមចាប់ផ្តើមអធិស្ឋានឥឡូវនេះ ហើយសួរថាព្រះជាម្ចាស់ចង់ឱ្យអ្នកថ្វាយប៉ុន្មាននៃប្រាក់របស់អ្នកសម្រាប់ការងាររបស់ទ្រង់។ ព្រះគម្ពីរបង្រៀនថា ព្រះជាម្ចាស់នឹងប្រទានព្រះពរដល់អ្នកណាដែលចូលរួមចំណែកដើម្បីពង្រីកនគររបស់ព្រះអង្គ។ហើយក៏បានបង្រៀនយើងផងដែរថា ព្រះយេស៊ូគ្រិស្ត នឹងផ្គត់ផ្គង់អស់ទាំងតម្រូវការរបស់យើង។ អ្នកប្រហែលជាកំពុងគិតថា «ប៉ុន្តែ ប្រហែលជាព្រះមិនយល់ថា ខ្ញុំក្រដល់កម្រិតណាទេ» «ព្រះមិនបានយល់ថាតើ្តជំពាក់បំណុលគេប៉ុន្មានទេ»។ ព្រះយេស៊ូក៏បានកើតនៅក្នុងគ្រួសារក្រីក្រមួយ ព្រះយេស៊ូយល់ពីភាពក្រីក្រច្បាស់។ប៉ុន្តែ ទ្រង់សូមឱ្យយើងទាំងអស់គ្នា មានភាពស្មោះត្រង់ក្នុងការស្តាប់បង្គាប់ទ្រង់ទោះបីជាទ្រង់សូមឱ្យយើងធ្វើអ្វីក៏ដោយ។ ព្រះជាម្ចាស់ចង់ឱ្យលោកអ្នកមានចំណែកក្នុងការគាំទ្រហិរញ្ញវត្ថុនៅក្នុងព័ន្ធកិច្ចរបស់ទ្រង់។

៣- <u>ដើម្បីធ្វើជាអ្នកដើរតាមព្រះគ្រិស្ត គឺបានន័យថា ត្រូវដើរតាមគំរូរបស់ទ្រង់ ហើយស្រឡាញ់អ្នកដទៃដូចដែលទ្រង់បានធ្វើ</u>៖ វាគឺជាការពិតដែលថា យើងមិនអាចប្រោសមនុស្សដូចដែលព្រះយេស៊ូបានធ្វើនោះទេ ប៉ុន្តែ ព្រះយេស៊ូនៅតែព្យាបាល និងប្រោសអ្នកជំងឺសព្វថ្ងៃ។ យើងត្រូវតែស្មោះត្រង់ក្នុងការអធិស្ឋានដល់អ្នកជំងឺ។ យើងគួរតែនៅក្បែរពួកគេហើយចាប់ដៃគេនៅពេលដែលគេកំពុងតែទទួលការឈឺ

ចាប់។ យើងត្រូវប្រាប់គេថា ព្រះយេស៊ូគ្រិស្តស្រឡាញ់គេ។ យើងត្រូវអធិស្ឋានឱ្យអ្នកដែលមានអារក្សចូល ព្រះយេស៊ូនៅតែបណ្តេញអារក្សចេញនៅពេញទាំងពិភពលោកតាមរយៈការអធិស្ឋានរបស់រាស្ត្រទ្រង់។ យើងត្រូវអធិស្ឋាន និងជួយដល់អស់អ្នកដែលកំពុងមានសេចក្តីត្រូវការ។ យើងត្រូវធ្វើនូវអ្វីដែលយើងអាចជួយនូវសេចក្តីត្រូវការខាងរាងកាយរបស់ពួកគេ ជាពិសេសសូមប្រាប់ពួកគេអំពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូគ្រិស្តដែលអាចផ្លាស់ប្រែការរស់នៅរបស់គេនៅខាងក្នុង។ ជាពិសេសយើងត្រូវជួយក្មេងៗ ព្រះយេស៊ូបានបង្គាប់សិស្សរបស់ព្រះអង្គឱ្យធ្វើកិច្ចការទាំងអស់នេះ តែទ្រង់បានសន្យាថា នឹងផ្តល់រង្វាន់ពិសេសដល់អស់អ្នកណាមានបំណងជួយដល់ក្មេងៗ។

៤- <u>អ្នកខ្លះពិបាកក្នុងការស្រឡាញ់ដល់អ្នកដទៃ ប៉ុន្តែព្រះជាម្ចាស់មានបំណងឱ្យយើងមានសេចក្តីមេត្តាករុណា</u>: នៅក្នុងសម័យនោះគេស្អប់អ្នកទាពន្ធណាស់ ពួកគេធ្វើការឱ្យរដ្ឋាភិបាលដែលពុករលួយ ដែលប្រមូលលុយពីប្រជាជន ហើយពួកគេតែងតែយកលើសកំណត់ដើម្បីយកដាក់ហោប៉ៅរបស់ពួកគេផ្ទាល់។ ការបង្ហាញសេចក្តីស្រឡាញ់ដល់អ្នកណាម្នាក់ដែលបានលួចលុយពីអ្នកនោះមិនមែនជាការងាយស្រួលដើម្បីធ្វើនោះទេ ជាពិសេសប្រសិនបើមនុស្សនេះមិនព្រមផ្លាស់ប្រែពីអ្វីដែលគេបានធ្វើនោះ។ ប៉ុន្តែ ព្រះយេស៊ូបានប្រាប់យើងថា អ្នកដែលដើរតាមទ្រង់យើងគ្មានសិទ្ធដើម្បីដាក់ទោសអ្នកទាំងនេះ ទោះបីការដែលគេធ្វើនោះខុសយ៉ាងណាក៏ដោយ។ ភារកិច្ចរបស់យើងគឺអធិស្ឋាន ដើម្បីគេស្រឡាញ់គ្នា ហើយប្រាប់គេពីសេចក្តីពិតនៃការអត់ទោសរបស់ព្រះជាម្ចាស់។ ប្រសិនបើគេប្រែចិត្តចេញពីអំពើបាប ពួកគេនឹងបានទទួលការលើកលែងទោសពីព្រះ យ៉ាងពិតប្រាកដ។ ព្រះគម្ពីរបានប្រាប់យើងថា យើងទាំងអស់គ្នាជាអ្នកមានបាបដែលសាកសមនឹងទទួលទោស។ ព្រះគម្ពីរក៏បានប្រាប់យើងថា យើងបានទទួលការលើកលែងទោស និងសេចក្តីមេត្តាករុណា ដូច្នេះ យើងត្រូវតែបង្ហាញពីការលើកលែងទោស និងសេចក្តីមេត្តាករុណា ការនេះជាការពិបាកធ្វើប្រសិនបើយើងគ្មានអំណាចរបស់ព្រះនៅក្នុងជីវិតរបស់យើង។

៥- <u>តម្រូវការរបស់ពិភពលោកគឺធំធេងណាស់ យើងមិនអាចធ្វើដោយម្នាក់ឯងបានទេ</u>: មានមនុស្សរាប់លាននាក់ដែលមិនដែលបានស្គាល់ និងទទួលសេចក្តីស្រឡាញ់របស់ព្រះគ្រិស្ត។ មានមនុស្សរាប់លាននាក់ដែលមិនដែលបានស្គាល់ និងទទួលសេចក្តីស្រឡាញ់ពីអ្នកផ្សេងៗ។ មានមនុស្សរាប់លាននាក់ដែលត្រូវការសេចក្តី

ស្រឡាញ់នោះ ប្រសិនបើជានរណាម្នាក់អាចបង្ហាញដល់ពួកគេ ឱ្យពួកគេប្រគល់ជីវិតរបស់ពួកគេដល់ព្រះគ្រិស្ត ហើយទទួលសេចក្តីស្រឡាញ់របស់ទ្រង់។ យើងគួរធ្វើអ្វីដែលយើងអាចធ្វើ ប៉ុន្តែ យើងក៏ត្រូវអធិស្ឋានទៅព្រះជាម្ចាស់ដែរ សូមទ្រង់នាំអ្នកផ្សេងទៀតឱ្យមកជួយដើម្បីនាំសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដល់មនុស្សច្រើនទៀត។

៦- លោកអ្នកអាចង្ហាញសេចក្តីស្រឡាញ់របស់លោកអ្នកចំពោះព្រះជាម្ចាស់ ហើយដល់គ្នាទៅវិញទៅមក តាមរយៈការថ្វាយដង្វាយមួយភាគដប់សម្រាប់កិច្ចការរបស់ព្រះជាម្ចាស់តាមរយៈក្រុមជំនុំក្នុងស្រុក៖ ព្រះជាម្ចាស់ប្រើក្រុមជំនុំក្នុងស្រុក ដើម្បីបម្រើប្រជាជនដែលមានបញ្ហាខាងព្រលឹងវិញ្ញាណអារម្មណ៍ និងផ្នែករាងកាយ។ ព្រះជាម្ចាស់ទ្រង់ប្រើដង្វាយមួយភាគដប់របស់អ្នក ដើម្បីជួយក្រុមជំនុំសម្រេចកិច្ចការរបស់ក្រុមជំនុំ។

## សំណួរពិភាក្សា

១- តើមានមធ្យោបាយអ្វីដែលខ្ញុំអាចបង្ហាញសេចក្ដីស្រឡាញ់របស់ព្រះដល់អ្នកដទៃ នៅក្នុងកាលៈទេសៈ និងនៅក្នុងពិភពលោករបស់ខ្ញុំ?

២- តើអ្វីជាតម្រូវការដែលធំជាងគេរបស់មនុស្សដែលនៅជុំវិញខ្ញុំ? តើនៅក្នុងតំបន់ដែលខ្ញុំរស់នៅ មនុស្សគេមានការឈឺចាប់យ៉ាងម៉េច?

៣- តើធ្វើយ៉ាងម៉េចខ្ញុំអាចឈោងចាប់មនុស្សដែលកំពុងតែមានការឈឺចាប់នៅជុំវិញខ្ញុំ?

៤- តើធ្វើយ៉ាងណាដើម្បីឱ្យខ្ញុំអាចសម្ដែងសេចក្ដីស្រឡាញ់ពិសេសដល់ក្មេងៗ?

៥- តើខ្ញុំអាចប្រើលុយជួយមនុស្សតាមវិធីណា?

៦- តើខ្ញុំបានថ្វាយកិត្តិយសដល់ព្រះនៅក្នុងការប្រើលុយរបស់ខ្ញុំទេ?

៧- តើខ្ញុំអាចបង្ហាញពីសេចក្ដីមេត្តាករុណារបស់ព្រះនៅក្នុងជីវិតរបស់ខ្ញុំដល់អ្នកដែលនៅជុំវិញខ្ញុំយ៉ាងម៉េច?

** នេះជាពេលដ៏ល្អផ្សេងទៀត ជួយដល់បេសកជនម្នាក់ ដែលនៅផ្នែកម្ខាងនៃពិភពលោក ហើយអធិស្ឋានឱ្យក្រុមមនុស្ស ដែលនៅប្រទេសផ្សេង ដែលមិនទាន់បានឮពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។*

# មេរៀនទី៦
## អំពើក្បត់ និងការលើកលែងទោស

ម៉ាថាយ ២១-២៧:១០

*«ប៉ុន្តែ បើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ និងសុចរិត ទ្រង់នឹងអត់ទោសឱ្យយើងរួចពីបាបព្រមទាំងជំរះយើងឱ្យបានបរិសុទ្ធរួចពីគ្រប់ទាំងអំពើទុច្ចរិតទាំងអស់ផង»១យ៉ូហាន ១:៩។*

<u>រំលឹក:</u>

១- ព្យាការីអេសាយបាន និយាយថាព្រះ យេស៊ូនិងត្រូវបានគេហៅថា អេម៉ាញូអែល ដែលប្រែថា «ព្រះ________________________________________»។

២- ព្រះយេស៊ូមានព្រះបន្ទូលថា អ្នកដែលដឹងថាពេលណាទ្រង់នឹងយាងមកផែនដីវិញគឺមានតែម្នាក់ទេគឺ________________________________________។

៣- លោកយ៉ូហានបានធ្វើពិធីជ្រមុជទឹកដល់មនុស្សជាច្រើនដែលប្រែចិត្តអំពី_____ ____________របស់ពួកគេ។

៤- ព្រះយេស៊ូបានឆ្លើយទៅសាតាំងបីដងដោយប្រើ__________នៃ_________។

៥- ប្រសិនបើយើង ចង់បាន ដូចជាព្រះគ្រិស្ត វាជាការចាំបាច់ ក្នុងការ ចំណាយ ពេលវេលាម្នាក់ឯង____________________________________ជាមួយទ្រង់។

៦- ព្រះយេស៊ូបានហៅយើងឱ្យក្លាយទៅជា_____________មនុស្ស________។

៧- ព្រះយេស៊ូបានបង្ហាញសេចក្តីស្រឡាញ់ទៅដល់គ្រប់មនុស្សទាំងអស់ដោយ____ ________________________________________ពីជំងឺរបស់ពួកគេ។

៨- ព្រះយេស៊ូបានពោរពេញដោយសេចក្តីរំជួលចិត្តជាមួយ និងហ្វូងមនុស្សដោយសារតែទ្រង់បានឃើញ________________________________ជាច្រើន។

៩- ព្រះយេស៊ូបានប្រាប់ទៅអ្នកដែលដើរតាមទ្រង់ ឱ្យចេញទៅគ្រប់មនុស្សទាំងអស់

ប៉ុន្តែ សូមឱ្យឆ្លាតដូចជា________________________និងសុភាពដូចជា__
__________។

១០- ព្រះយេស៊ូបានមានព្រះបន្ទូលថា ទ្រង់ជ្រាបសូម្បីតែចំនួន __________នៅលើក្បាលរបស់យើង។

១១- ទ្រង់បានមានព្រះបន្ទូលទៀតថា ប្រសិនបើគេឱ្យទឹកត្រជាក់មួយកែវទៅក្មេងតូចផឹក នោះគេនឹងមិនបាត់បង់______________________________។

១២- ព្រះគ្រិស្តបានប្រាប់ទៅសិស្សរបស់ទ្រង់នៅក្នុងទូកក្នុងពេលដែលកំពុងតែជួបប្រទះព្យុះថា________________________________________។

ព្រះគ្រិស្ត បាន បង្រៀន អធិប្បាយ និង ប្រោស មនុស្ស ជា ច្រើន នៅ ក្នុង ខេត្ត កាលីឡេ ប៉ុន្តែ នៅតែមានមនុស្សជាច្រើនបានបដិសេធព្រះបន្ទូលរបស់ទ្រង់។ ព្រះគ្រិស្ត បាន ពន្យល់ ទៅ សិស្ស របស់ ទ្រង់ ថា នេះ ក៏ ជា ផែន ការ របស់ ព្រះជាម្ចាស់ ដែរ ដោយ ទ្រង់ ជ្រើស ក្នុង ការ លាក់ កំបាំង សេចក្តី ពិត ពី អ្នក ដែល មាន ប្រាជ្ញា តែ បើក បង្ហាញដល់អ្នកដែលស្លូតត្រង់វិញ។

ពេលវេលាបានមកដល់ នូវអ្វីដែលទ្រង់បានដាស់តឿនដល់សិស្សរបស់ទ្រង់ជាមុន។ គឺជាពេលដែលទ្រង់ត្រូវធ្វើដំណើរទៅទីក្រុងយេរូសាឡឹម ដើម្បីទទួលរងការឈឺចាប់ជាច្រើនពីពួកអាចារ្យ និងអ្នក ដឹងនាំសាសនា ដើម្បីសុគត ហើយនិងរស់ឡើងវិញ។ កាលដែលទ្រង់យាងមកដល់ក្រុងយេរូសាឡឹម គឺមានមនុស្សឈរកកកុញនៅតាមសងខាងផ្លូវដោយបានក្រាលសំលៀកបំពាក់របស់គេ និងស្លឹកចាកដើម្បីធ្វើជាកម្រាលសម្រាប់ឱ្យទ្រង់យាងលើ។ ហើយនៅពេលដែលទ្រង់គង់នៅលើសត្វលាយាងកាត់ពួកគេនោះ គេក៏បានស្រែកយ៉ាងខ្លាំងថា *«ហូសាណាដល់ព្រះវង្សហ្លួងដាវីឌព្រះអង្គដែលយាងមកដោយនូវព្រះនាមព្រះអម្ចាស់ទ្រង់ប្រកបដោយព្រះពរ ហូសាណាដល់ស្តេចដ៏ខ្ពស់បំផុត»*។

ព្រះយេស៊ូបានចំណាយពេលជាច្រើនថ្ងៃនៅទីក្រុងយេរូសាឡឹមដើម្បីបង្រៀននៅក្នុងព្រះវិហារ ទ្រង់បានបង្រៀន អធិប្បាយ និងប្រោសជំងឺមនុស្សជាច្រើន។ ប៉ុន្តែ ទ្រង់មានការអ្នកតតាំង និងការប្រឆាំងយ៉ាងខ្លាំងពីសំណាក់ពួកអាចារ្យផារិស៊ី និងពួកសាឌូស៊ី។

យូដាសអេស្ការីយ៉ុត ដែលជាសិស្សម្នាក់ក្នុងចំណោមសិស្សរបស់ព្រះយេស៊ូក៏

បានទៅជួបនឹងពួកអាចារ្យ ហើយខំខ្នះខ្នែងដើម្បីបញ្ជូនព្រះយេស៊ូទៅឱ្យពួកគេ ដោយសារតែចង់បានលុយ។ ពួកអាចារ្យក៏ឱ្យប្រាក់គាត់ចំនួន៣០ដុំ ហើយយូដាសក៏បានទទួលយកប្រាក់នោះដោយក្បត់នឹងព្រះយេស៊ូ។

នៅយប់ក្នុងថ្ងៃបុណ្យរំលងដែលជាថ្ងៃបុណ្យដ៏សំខាន់របស់ជនជាតិយូដាប្រចាំឆ្នាំ នោះព្រះយេស៊ូក៏បានជុំគ្នាជាមួយនឹងសិស្សរបស់ទ្រង់ក្នុងការបរិភោគអាហារជុំគ្នាជាលើកចុងក្រោយ។ នៅក្នុងពេលបរិភោគនោះ ព្រះយេស៊ូក៏បានចាប់យកនំប៉័ងដែលគេកំពុងតែបរិភោគមកកាច់ហើយមានព្រះបន្ទូលថា *«យកទៅបរិភោគចុះនេះជាតំណាងឱ្យរូបសាច់របស់ខ្ញុំ»*។ បន្ទាប់មក ទ្រង់បានលើកស្រាមួយកែវហើយមានព្រះបន្ទូលថា *«សូមឱ្យអ្នកទាំងអស់គ្នាផឹកពីកែវនេះ គឺជាតំណាងឱ្យឈាមរបស់ខ្ញុំដែលនឹងហូរសម្រាប់មនុស្សលោក ដើម្បីលប់លាងនូវអំពើបាបរបស់គេ»*។

ក្រោយពេលបរិភោគអាហារពេលល្ងាចរួចហើយ ពួកសិស្សក៏បានធ្វើដំណើរទៅលើភ្នំអូលីវ ព្រះយេស៊ូបាននិយាយទៅកាន់គេថា ពួកគេនឹងរត់ចោលទ្រង់ តែពេត្រុសបាននិយាយថា គាត់គ្មានថ្ងៃនឹងក្បត់ទ្រង់ឡើយ។ នោះព្រះយេស៊ូក៏បានទាយជាមុនថា ពេត្រុសមិនត្រឹមតែក្បត់ទ្រង់ទេ តែគាត់នឹងបដិសេធថាមិនស្គាល់ទ្រង់បីដងមុនពេលដែលមាន់រងាវ គឺនៅពេលព្រឹកព្រលឹម។

ហើយព្រះយេស៊ូក៏នាំពួកសិស្សទៅសួនច្បារកេតសេម៉ានី។ ហើយទ្រង់បានចំណាយពេលដែលនៅសល់ក្នុងយប់នោះសម្រាប់អធិស្ឋាន។ ទ្រង់ក៏បានហៅសិស្សរបស់ទ្រង់ឱ្យអធិស្ឋានជាមួយនឹងទ្រង់ ប៉ុន្តែ ពួកគេទាំងអស់បានលង់លក់អស់ទៅ។ ពួកគេភ្ញាក់ឡើងនៅពេលដែលយូដាសនាំពួកអាចារ្យមកដល់ក្នុងសួនច្បារដើម្បីនឹងចាប់យកព្រះយេស៊ូទៅ។ យូដាសក៏បានថើបព្រះយេស៊ូជាសញ្ញានៃការក្បត់របស់ខ្លួន។ ពួកអាចារ្យក៏ចាប់យកព្រះយេស៊ូទៅផ្ទះរបស់លោកកៃផាសដែលជាសម្តេចសង្ឃនៅសម័យនោះ។ ឯពួកសិស្សក៏នាំគ្នារត់គេចចេញពីសួនអស់ទៅ។

នៅពេលដែលព្រះយេស៊ូកំពុងតែត្រូវបានលោកកៃផា និងពួកអាចារ្យសួរចម្លើយនោះពេត្រុសបាននៅខាងក្រៅផ្ទះឯទីធ្លា នៅពេលដែលគាត់កំពុងតែអង្គុយមានអ្នកបម្រើស្រីម្នាក់បានមកឯគាត់ហើយនិយាយថា «អ្នកឯងក៏ជាអ្នកដែលនៅជាមួយព្រះយេស៊ូដែរ» ពេលនោះពេត្រុសក៏បានបដិសេធ រួចហើយគាត់ក៏បានទៅនៅក្បែរក្លោងទ្វារនោះក៏មានអ្នកបម្រើម្នាក់ទៀតបានឃើញគាត់ ហើយបានចោទប្រកាន់ថា គាត់នៅជាមួយនឹងព្រះយេស៊ូនោះ ពេត្រុសក៏បដិសេធទៀត។ បន្ទាប់

ក្រោយ មកហ្វូង មនុស្សក៏បានមកឯពេត្រុសហើយក៏បានចោទគាត់ ពីការដែលនៅជាមួយនឹងព្រះយេស៊ូ ម្តងនេះពេត្រុសក៏បានស្បថថា «ខ្ញុំមិនដែលស្គាល់បុរសនោះទេ» រំពេចនោះមាន់ក៏រងាវ ហើយពេត្រុសក៏ចាំនូវព្រះបន្ទូលរបស់ព្រះយេស៊ូនៅឯលើភ្នំអូលីវ គាត់ដើរចេញទៅយំយ៉ាងខ្សឹកខ្សួល។

លុះព្រឹកឡើងពួកអ្នកដឹកនាំសាសនាបាននាំព្រះយេស៊ូទៅឯលោកពីឡាត់ ដើម្បីកាត់ទោសសម្លាប់ទ្រង់។ ពេលដែលយូដាសបានឃើញថា ព្រះយេស៊ូនឹងត្រូវគេសម្លាប់ នោះមានការសោកស្តាយ ហើយក៏យកប្រាក់នោះ ទៅឱ្យពួកអាចារ្យវិញ គាត់បាននិយាយថា «ខ្ញុំបានប្រព្រឹត្តអំពើបាបចំពោះឈាមមនុស្សសុចរិត» តែពួកអាចារ្យក៏បានឆ្លើយតបថា «តើមានអ្វីទាក់ទងនឹងយើង? ឯងក៏បានឃើញដែរ»នោះ យូដាសក៏បានបោះប្រាក់នោះទៅលើឥដ្ឋនៅក្នុងព្រះវិហារ ហើយក៏រត់ចេញពីទីនោះ ទៅចងកសម្លាប់ខ្លួនទៅ។

## សំណួរផ្ទាល់មាត់

១- គម្រោងការរបស់ព្រះ គឺលាក់កំបាំងសេចក្តីពិតពីអ្នកមានប្រាជ្ញា ហើយបើកបង្ហាញឱ្យអ្នកណាវិញ?

២- តើព្រះយេស៊ូត្រូវបានគេស្វាគមន៍យ៉ាងដូចម្តេចខ្លះនៅពេលដែលទ្រង់ធ្វើដំណើរទៅក្នុងទីក្រុងយេរូសាឡឹម?

៣- ហេតុអ្វីបានជាយូដាសទៅកាន់ឯពួកសង្ឃ ? ហើយតើហេតុអ្វីបានជាគេឱ្យប្រាក់គាត់៣០ដួង?

៤- នៅពេលដែលព្រះយេស៊ូបរិភោគអាហារពេលល្ងាចចុងក្រោយជាមួយនឹងពួកសិស្សទ្រង់ នោះទ្រង់មានព្រះបន្ទូលថា នំប៉័ង និងស្រាទំពាំងបាយជូរជាតំណាងយ៉ាងពិសេស តើជាតំណាងពីអ្វី?

៥- នៅលើភ្នំអូលីវព្រះយេស៊ូបានប្រាប់នៅពួកសិស្សថា ពួកគេនឹងរវាតចិត្តពីទ្រង់ ទៅតែពេត្រុសបានបដិសេធ នោះទ្រង់ក៏ធ្វើការទស្សទាយមួយអំពីពេត្រុស តើនោះគឺជាអ្វី?

៦- ព្រះយេស៊ូបានមានព្រះបន្ទូលទៅសិស្សថា ឈាមរបស់ទ្រង់ត្រូវតែបង្ហូរ តើហេតុអ្វី?

៧- តើយូដាសប្រើកាយវិការអ្វីដែលបង្ហាញថា គាត់បានបញ្ជូនព្រះយេស៊ូ?

៨- តើពេត្រុសនៅឯណាពេលដែលពួកអាចារ្យ និងអ្នកដឹកនាំសាសនាសួរចម្លើយព្រះយេស៊ូ?

៩- មានក្មេងស្រីពីរនាក់បានមកឯពេត្រុស ហើយបានចោទប្រកាន់គាត់ តើគេចោទប្រកាន់គាត់អំពីអ្វី?

១០- លើកទីបីមានមនុស្សជាច្រើនបានមក ហើយចោទថាពេត្រុសបាននៅជាមួយព្រះយេស៊ូ តើពេត្រុសឆ្លើយទៅនឹងអ្នកទាំងនោះយ៉ាងដូចម្តេច?

១១- តើនៅពេលណាដែលយូដាសមានអារម្មណ៍សោកស្តាយអំពីការដែលខ្លួនបាន

ក្បត់នឹងព្រះគ្រិស្ត ?

១២- តើហេតុអ្វីបានជាយូដាសត្រលប់ទៅឯពួកអាចារ្យវិញ ?

១៣- តើ យូដាស ធ្វើ អ្វី នៅ ពេល ដែល ពួក អាចារ្យ បាន បដិសេធ មិន យក ប្រាក់ នោះ វិញ ?

## មេរៀនទី៦

# សេចក្ដីពិតខាងវិញ្ញាណ

ម៉ាថាយ ២១-២៧:១០

នៅពេលដែលព្រះយេស៊ូបរិភោគអាហារចុងក្រោយជាមួយសិស្សរបស់ទ្រង់ ទ្រង់បានចាប់ផ្ដើមធ្វើតាមពិធីប្រពៃណីមួយ ដែលពិធីនោះត្រូវបានអ្នកដែលដើរតាមព្រះយេស៊ូសង្កេត និងយកមកអនុវត្តរហូតមកដល់សព្វថ្ងៃនេះ។ យើងហៅពិធីនេះថា«**ពិធីលៀងព្រះអម្ចាស់**» ពិធីលៀងព្រះអម្ចាស់នេះមិនមែនជាពិធីពិសេសសម្រាប់លាងអំពើបាប ឬការធ្វើអ្វីពិសេសមួយមកលើរាងកាយរបស់យើងទេ។ វាមិនមែនអស្ចារ្យរហូតដល់ធ្វើឱ្យនំប៉័ង និងទឹកទំពាំងបាយជូរធម្មតានេះប្រែក្លាយទៅជាសាច់ និងព្រះលោហិតរបស់ព្រះយេស៊ូដែរ។ តែវាគឺជាពេលដែលអ្នកដើរតាមព្រះយេស៊ូទាំងអស់មកជួបជុំគ្នា ហូបនំប៉័ង និងផឹកស្រាទំពាំងបាយជូរ ជាមួយគ្នាហើយនឹកដល់ព្រះយេស៊ូដែលត្រូវគេឆ្កាងនៅលើឈើឆ្កាង។ គឺជាពេលវេលាដែលត្រូវនឹកចាំពីតម្លៃដែលព្រះយេស៊ូបានបង់ ដើម្បីលោះអំពើបាបរបស់យើង។ នេះគឺជាពេលនៃសេចក្ដីអំណរ និងអរព្រះគុណដែលជាអំណរនិងការលើកលែងទោសដែលទ្រង់ប្រទានដល់យើងទាំងអស់គ្នា។ ២កូរិនថូស ១១:២៣-៣៣ បង្រៀនយើងថា វាគឺជាករណីដ៏លំបាកបំផុត វាមិនមែនជាអ្វីមួយដើម្បីធ្វើឱ្យច្បាស់លាស់ទេ តែគឺជាពេលដែលត្រូវរំពឹងគិត ចំពោះយញ្ញបូជារបស់ទ្រង់សំរាប់យើងរាល់គ្នា ហើយប្រៀបធៀបជីវិតរបស់យើងទៅក្នុងពន្លឺនៃអ្វី______________________________

______________________________________________________។

២- ព្រះទ្រង់ជ្រាបការបរាជ័យរបស់យើងមុនយើងខ្លួនឯងទៅទៀត តែទ្រង់នៅតែទទួលយើង ហើយចង់ប្រើយើងនៅក្នុងនគររបស់ទ្រង់: តាំងពីពេលដែលព្រះយេស៊ូបានដៅលោកពេត្រុសលើកដំបូងដើម្បីឱ្យក្លាយទៅជា «អ្នកនេសាទមនុស្ស»នោះទ្រង់ជ្រាបថា យប់នេះពេត្រុសនឹងបដិសេធទ្រង់។ ប៉ុន្តែបើយើងនៅតែបន្តរអានព្រះគម្ពីរ នោះយើងឃើញថា ព្រះបានប្រើពេត្រុសឱ្យដឹកនាំមនុស្សរាប់ពាន់នាក់មកកាន់ទ្រង់។ ហើយជាងនេះទៅទៀត គឺមានសៀវភៅពីរកណ្ឌនៅក្នុងព្រះគម្ពីរដែល

បានសរសេរឡើងដោយលោកពេត្រុស។

នៅក្នុងសៀវភៅកិច្ចការជំពូកពីរ ក្រោយពីការយាងត្រលប់ទៅវិញរបស់ព្រះយេស៊ូគ្រិស្ត យើងឃើញថា លោកពេត្រុសបានឈរអធិប្បាយនៅក្រុងយេរូសាឡឹមទៅកាន់ហ្វូងមនុស្សដែលគាត់ធ្លាប់ខ្លាចគេនៅយប់ដែលគេចាប់ព្រះយេស៊ូនោះ។ ជាមួយគ្នានេះដែរព្រះជាម្ចាស់មិនភ្ញាក់ផ្អើលនឹងការបរាជ័យរបស់យើងទេ ទោះបីជាក្រោយពេលដែលយើងជឿព្រះគ្រិស្ត ហើយក៏ដោយក៏យើងនៅតែមានការបរាជ័យដែរ។ យើងនៅតែមានបាប យើងនៅតែមានពេលបដិសេធទ្រង់ ហើយយើងនៅតែធ្វើនូវអ្វីដែលយើងស្អប់។

៣- តើយើងធ្វើដូចម្តេចដែលយើងដួលនៅចំពោះព្រះ?

មានសិស្សពីរនាក់ដែលបដិសេធទ្រង់នៅយប់នោះម្នាក់ឈ្មោះពេត្រុសដែលជាអ្នកបដិសេធទ្រង់ តែក្រោយមកត្រូវបានព្រះប្រើយ៉ាងសកម្ម និងម្នាក់ទៀតឈ្មោះយូដាសដែលជាអ្នកក្បត់ទ្រង់ ហើយក្រោយមកត្រូវធ្វើអត្តឃាតខ្លួនឯង។ មានមនុស្សជាច្រើនយល់ខុសថា ហេតុផលដែលថាលោកពេត្រុសក្លាយទៅជាអ្នកដែលទទួលជោគជ័យ ហើយយូដាសជាអ្នកបរាជ័យនោះ ដោយសារតែការក្បត់របស់លោកយូដាសខ្លាំងជាងពេត្រុស។ ប៉ុន្តែ វាមិនមែនដូច្នោះទេ ព្រោះព្រះគម្ពីរបានបង្រៀនយើងថាគ្រប់គ្នាមានអំពើបាប ហើយត្រូវការសេចក្តីសង្គ្រោះពីព្រះជាម្ចាស់។ យើងឃើញថា យូដាសមិនបានលន់តួនូវអំពើបាបរបស់ខ្លួន ដើម្បីទទួលនូវការលើកលែងទោសនោះទេ។

មានមនុស្សជាច្រើនដឹងខ្លួនថា គេធ្វើខុសនៅពេលដែលគេធ្វើអ្វីមួយមិនល្អ ហើយមនុស្សមួយចំនួនទៀតមានអារម្មណ៍ពិបាកចិត្តទៅនឹងអ្វីដែលគេបានធ្វើខុស ហើយមានមនុស្សខ្លះបានធ្វើការយ៉ាងអាក្រក់ ដែលគេគិតថាសូម្បីតែព្រះក៏មិនអាចជួយគេបានដែរ។ ព្រះគម្ពីរបានប្រាប់យើងថា នោះមិនមែនជាការពិតនោះទេ នៅក្នុង១យ៉ូហាន ១:៩ *«ប៉ុន្តែ បើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ និងសុចរិត ទ្រង់នឹងអត់ទោសឱ្យយើងរួចពីបាប ព្រមទាំងជំរះយើងឱ្យបានបរិសុទ្ធ រួចពីគ្រប់ទាំងអំពើទុច្ចរិតទាំងអស់ផង»*។

*មានន័យថា ប្រសិនបើមនុស្ស:*

*- ចូលមកឯព្រះ*

*- ទូលទៅព្រះអំពីអ្វីដែលគេបានធ្វើ*

*- លន់តួបាប*

*- សុំឱ្យព្រះលើកលែងទោសសម្រាប់អំពើបាបនោះ*

*- នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ដើម្បីនឹងលើកលែងទោសរបស់យើងសម្រាប់គ្រប់ការទាំងអស់។ ទោះបីជាការនោះអាក្រក់ យ៉ាងណាក៏ដោយព្រះគ្រិស្ត ត្រូវបានគេឆ្កាងនៅលើឈើឆ្កាង ដែលមានតម្លៃគ្រប់គ្រាន់នឹងសំអាតបាបរបស់យើងផង។*

នេះគឺមានន័យថា នៅក្នុងនាមជាអ្នកដែលដើរតាមព្រះគ្រិស្តនោះយើងគួររស់នៅក្នុងភាពបរាជ័យនោះទេ ដោយសារការចងចាំអំពីអតីតកាលនៃអំពើបាបដែលព្រះបានអត់ទោសឱ្យយើងរួចមកហើយនោះ។ ពេត្រុសបានលន់តួរនូវអំពើបាបរបស់គាត់ ហើយដែលក្រោយមកព្រះបានរើសគាត់យកប្រើ។ នោះយើងក៏អាចលន់តួរបាបរបស់យើង ហើយព្រមឱ្យព្រះបានប្រើយើងដែរ។

យើងឃើញថា យូដាស ពិតជាមានភាពកំសោយនៅក្នុងចិត្តរបស់គាត់។ វាជាការអាក្រក់បំផុតក្នុងការក្បត់មិត្តភ័ក្រជិតស្និទ្ធរបស់ខ្លួនឯង ហើយធ្វើឱ្យមិត្តភ័ក្រនោះទទួលនូវការឈឺចាប់រហូតដល់ស្លាប់ដោយគ្មានកំហុសអ្វីសោះ។ តែទោះជាយ៉ាងណាក៏ដោយ ព្រះនៅតែមានផែនការសម្រាប់ជីវិតរបស់យូដាស ព្រោះយូដាសនៅតែមានតម្លៃសម្រាប់នឹងទទួលនូវការលើកលែងទោសពីព្រះជាម្ចាស់។

យើងឃើញថា គាត់បានត្រលប់ចូលមកឯព្រះគ្រិស្ត ដោយគាត់បានដើរតាមភាពល្ងីងជូរចត់របស់គាត់ រហូតដល់ភាពល្ងីងជូរចត់នោះគ្រប់គ្រងលើខ្លួនរបស់គាត់ រហូតគាត់បញ្ចប់ជីវិតដោយខ្លួនឯង។

៤- ព្រះគ្រិស្តបានមានព្រះបន្ទូលទៅសិស្សរបស់ទ្រង់ថា ការព្រមព្រៀងរបស់យើងជាមួយនឹងព្រះបានធ្វើឡើង ដោយសារតែលោហិតរបស់ព្រះយេស៊ូបានហូរសម្រាប់លើកលែងទោស។ យើងមិនចាំបាច់ចំណាយអ្វី ឬក៏ធ្វើនូវអ្វីៗដើម្បីទទួលនូវការលើកលែងទោសពីព្រះនោះទេ។ នៅពេលដែលយើងទទួលព្រះគ្រិស្តមកក្នុងជីវិតយើងហើយនោះ គ្មានអ្វីដែលអាចកាត់ផ្តាច់យើងពីការលើកលែងទោសនោះបានឡើយ។ នៅក្នុងគម្ពីរអេភេសូរ១:១៣-១៤ និយាយថា « *ដោយរួមនៅក្នុងព្រះគ្រិស្ត*

*លោកអ្នកបានស្តាប់ព្រះបន្ទូលនៃសេចក្តីពិត ជាដំណឹងល្អដែលសង្គ្រោះលោកអ្នក»* ។ ក្នុងអង្គព្រះគ្រិស្ត លោកអ្នកបានជឿ ហើយបានទទួលសញ្ញាដៅសំគាល់ពីព្រះវិញ្ញាណបរិសុទ្ធតាមព្រះបន្ទូលសន្យាដែរ។ ព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណនេះមកបញ្ជាក់ចិត្តយើងឱ្យដឹងថា យើងនឹងទទួលមត៌កនៅពេលព្រះអង្គលោះប្រជារាស្ត្ររបស់ព្រះអង្គជាស្ថាបពរ ដើម្បីឱ្យគេលើកតម្កើងសិរីរុងរឿងព្រះអង្គ។

យ៉ូហាន ៣:១៦ និយាយថា *«អ្នកមានជីវិតអស់កល្ប»* ។ នៅពេលដែលព្រះគ្រិស្តគង់នៅក្នុងយើង នោះទ្រង់មិនដែលចាកចេញចោលយើងទេ គឺយើងបានសង្គ្រោះរហូតតាំងពីពេលដែលយើងទទួលជឿមក។ ព្រះគម្ពីរចែងថា យើងគួរតែចងចាំនៃការបូជារបស់ទ្រង់សម្រាប់យើង ហើយឈប់ធ្វើបាប។ យើងត្រូវតែព្យាយាមឱ្យអស់ពីសមត្ថភាព ដើម្បីរស់នៅក្នុងជីវិតប្រចាំថ្ងៃរបស់យើងដោយមានការគោរពកោតខ្លាចព្រះ ។ ប៉ុន្តែនៅក្នុង ១យ៉ូហាន២:១ រំលឹកយើងថា ប្រសិនបើយើងធ្វើអំពើបាប នោះយើងត្រូវតែចាំថា នរណាដែលកំពុងនៅក្នុងខ្លួនរបស់យើងចាំជួយការពារយើងនៅមុខព្រះវរបិតា។ ទ្រង់ជាដង្វាយលោះបាបជំនួសយើង។

## សំនួរពិភាក្សា

១- តើអ្នកគិតដូចម្តេចអំពីពេត្រុស និងយូដាស?

២- តើពាក្យ «លើកលែងទោស» មានន័យយ៉ាងដូចម្តេចចំពោះអ្នក?

៣- តើអ្នកធ្លាប់ដែលមានអារម្មណ៍ថាអ្នកមានកំហុសធ្ងន់ ធ្វើឱ្យអ្នកចាត់ទុកខ្លួនដូចជាចោទប្រកាន់ដែរឬទេ នៅពេលដែលអ្នកមើលទៅដូចជាយូដាសដែរឬតែ?

៤- មិនបាច់និយាយឮទេ។ តើអ្នកធ្លាប់បានធ្វើអ្វីដែលអាក្រក់យ៉ាងខ្លាំង ធ្វើឱ្យវាជាការពិតដែលអ្នកតែងតែធ្វើខុស ហើយគិតថាពិតជាមានការលំបាកនឹងទទួលយកការលើកលែងទោសពីព្រះគ្រិស្តដែរឬទេ?

៥- តើព្រះគ្រិស្តមានព្រះបន្ទូលទៅនឹងស្ថានការណ៍បែបយ៉ាងដូចម្តេច? ១យ៉ូហាន១:៩

គ្រប់គ្នាគួរនិយាយទៅកាន់ព្រះគ្រប់ទាំងអ្វីៗដែលមាននៅក្នុងជីវិតរបស់ពួកគេ។ ប្រសិនបើមានបាប ចូរលន់តួរសូមសេចក្តីមេត្តាករុណាពីព្រះភ្លាម ទូលសូមព្រះយកអ្នកចេញពីអំពើបាប។ លន់តួដោយចំហរថា ការដែលព្រះគ្រិស្តសុគតនៅលើឈើឆ្កាងនោះគ្រប់គ្រាន់ល្មមនឹងអត់ទោសបាបឱ្យយើងបានហើយ សូមប្រកាសនូវសេចក្តីពិតនេះ។ ប្រហែលជាពេលក្រោយមកអារក្សអាចនឹងព្យាយាមចោទប្រកាន់អ្នកតាមរយការដែលអ្នកចោទប្រកាន់ខ្លួនឯង។ គំនិតនេះមិនមែនមកពីព្រះទេ គំនិតនេះមិនមែនជាការអាក្រក់ដែលត្រឹមត្រូវទេ តែជាការអាក្រក់ដែលក្លែងក្លាយមិនពិតប្រាកដ។ ប្រសិនបើជាលោកអ្នកមានអារម្មណ៍ចោទប្រកាន់ណាមួយដែលព្រះបានធ្វើការលើកលែងទោសឱ្យអ្នករួចហើយ នោះសូមឱ្យអ្នកឈប់គិតហើយចាប់ផ្តើមអធិស្ឋានដោយនិយាយថា៖

«អរគុណព្រះយេស៊ូសម្រាប់ការលើកលែងនូវទោសកំហុសរបស់ទូលបង្គំ។ ព្រះអង្គអើយសូមអរគុណទ្រង់ ដែលដង្វាយលោះបាបរបស់ទ្រង់មានតម្លៃក្នុងការលើកលែងទោសរបស់ទូលបង្គំ។ ទូលបង្គំត្រូវតែជឿទុកចិត្តទៅលើព្រះលោហិតរបស់ទ្រង់ ហើយសូមទ្រង់ជួយយកនូវគំនិតនេះចេញពីទូលបង្គំផង»។ ព្រះអង្គមាន

ព្រះហឫទ័យស្មោះត្រង់ ហើយទ្រង់នឹងជួយយើង។ ប្រសិនបើយើងអធិស្ឋានសូមព្រះនៅពេលដែលអារក្សកំពុងតែវាយប្រហារយើងនោះ មិនយូរប៉ុន្មានវានឹងឈប់វាយប្រហារយើង ហើយយើងនឹងមានសេរីភាព។

យើងបានបំពេញនូវជោគជ័យលើគ្រប់ផ្នែកក្នុងការរស់នៅប្រចាំថ្ងៃក្នុងជំនឿលើព្រះគ្រិស្ត!

# មេរៀនទី៧

# ព្រះយេស៊ូគ្រិស្តនៅលើឈើឆ្កាង

ម៉ាថាយ ២៦-២៧

«ព្រះអង្គនឹងធ្វើឱ្យលោកអ្នកបានខ្ជាប់ខ្ជួនរហូតដល់ទីបំផុត ឥតមានទោសពៃរ៍អ្វីនៅថ្ងៃដែលព្រះយេស៊ូគ្រិស្ត ជាព្រះអម្ចាស់នៃយើងយាងមក» ១កូរិនថូស១:៨។

<u>រំលឹក</u>

១- ព្យាការីអេសាយបាននិយាយថា ព្រះយេស៊ូនឹងត្រូវបានគេហៅថាអេម៉ាញូអែល ដែលប្រែថាព្រះ______________________________________________។

២- ព្រះយេស៊ូមានព្រះបន្ទូលថា អ្នកដែលដឹងថាពេលណាទ្រង់នឹងយាងមកផែនដីវិញ គឺមានតែម្នាក់ទេគឺ______________________________________________។

៣- លោកយ៉ូហានបានធ្វើពិធីជ្រមុជទឹកដល់មនុស្សជាច្រើនដែលប្រែចិត្តអំពី_____ របស់ពួគេ។

៤- ព្រះយេស៊ូបានឆ្លើយទៅសាតាំងបីដងដោយប្រើ_________នៃ_________។

៥- ប្រសិនបើយើងចង់ឈ្នះនូវសេចក្តីល្បួង វាជាការចាំបាច់ក្នុងការដែលយើងត្រូវចំណាយពេលជាមួយ______________________________________________។

៦- ព្រះគ្រិស្តបានហៅអ្នកដែលដើរតាមទ្រង់ឱ្យទៅជា_______________មនុស្ស។

៧- ព្រះគ្រិស្តបានប្រាប់ទៅសិស្សរបស់ទ្រង់កុំឱ្យ____________________ព្រោះ វត្តមានរបស់ទ្រង់គង់នៅជាមួយគេជានិច្ច។

៨- ទ្រង់បានចំណាយពេលវេលានៅលើផែនដី______________នៅក្នុងសាលាប្រជុំជំនុំ_______________អំពីនគររបស់ព្រះ និង_______________អស់អ្នកជំងឺ។

៩- ព្រះគ្រិស្តបានប្រាប់សិស្សរបស់ទ្រង់ឱ្យចេញទៅគ្រប់ទាំងមនុស្ស ប៉ុន្តែ ត្រូវតែ__ ______________ដូចជាសត្វពស់ និងសុភាពដូចជា_________________។

១០- ព្រះយេស៊ូមានព្រះបន្ទូលថា ទ្រង់ដឹងទាំងចំនួន_______________នៅលើរបស់យើងទៀត។

១១- នៅលើកំពូលភ្នំអូលីវព្រះយេស៊ូបានមានព្រះបន្ទូលថា_____________នឹងបដិសេធទ្រង់បីដងមុនពេលដល់មាន់រងាវ។

១២- _____________________________ជាសិស្សរបស់ព្រះយេស៊ូដែលក្បត់ទ្រង់ដោយសារតែប្រាក់៣០ដួង។

១៣- _______________________________បានលន់តួនូវអំពើក្បត់របស់ខ្លួន ហើយក្រោយមកព្រះបានប្រើឱ្យធ្វើការងារធំសម្រាប់ទ្រង់។

១៤- _______________________________មានការសោកស្តាយអំពីអ្វីដែលគាត់បានធ្វើ ហើយក៏ចេញទៅសម្លាប់ខ្លួនឯងទៅ។

១៥- ព្រះបន្ទូលបានបង្រៀនថា ប្រសិនបើយើង «_______________បាបរបស់យើងទ្រង់ស្មោះត្រង់ ហើយលាងយើងអំពី_________ដែលមិនស្មោះត្រង់។

នៅពេលដែលពេត្រុសនៅក្រៅទ្វារទៅផ្ទះលោកកៃផាស ពីឡាត ព្រះយេស៊ូនៅខាងក្នុងដែលត្រូវបានគេចោទពីការធ្វើបន្ទាល់ក្លែងក្លាយ។ ព្រះបានបណ្តោយឱ្យអស់អ្នកទាំងនោះចោទប្រកាន់ទ្រង់ ដោយទ្រង់មិនទាំងហើបមាត់តវ៉ាការពារខ្លួនផង។ ដោយមិនមានធ្វើអ្វីកើតនោះ លោកកៃផាស់ក៏បានសួរសំណួរទៅព្រះគ្រិស្តថា «ចូរប្រាប់យើងមកថា តើអ្នកឯងជាព្រះគ្រិស្ត ជាព្រះរាជបុត្រាព្រះមែនទេ»។

ព្រះយេស៊ូនៅស្ងៀមមួយសន្ទុះក៏មានព្រះបន្ទូលថា «អ្វីដែលអ្នកនិយាយនោះត្រូវហើយ ខ្ញុំនិយាយទៅអ្នកថា នៅគ្រាបញ្ចប់ អ្នកនឹងឃើញកូនមនុស្សអង្គុយនៅខាងស្តាំដៃរបស់ព្រះវរបិតាដោយអំណាច និងយាងមកនៅលើពពក»។

នេះគឺជាភស្តុតាងគ្រប់គ្រាន់ណាស់ទៅហើយសម្រាប់លោកកៃផាស់ គាត់ក៏ហែកអាវរបស់គាត់ ហើយប្រកាសថា ព្រះគ្រិស្តជាអ្នកបោកប្រាស់។ ហើយពួកគេក៏បានយកព្រះយេស៊ូចេញទៅដោយស្តោះទឹកមាត់ដាក់មុខរបស់ទ្រង់ចំអកឱ្យទ្រង់ និងទះកំភ្លៀងទ្រង់។

លុះដល់ព្រឹកឡើងពួកសង្ឃ និងពួកអាចារ្យបានយកទ្រង់ទៅឱ្យលោកពីឡាត់ដែល ជា ចៅ ហ្វាយ ខេត្ត យូដា ជន ជាតិរ៉ូម ។ ចៅ ហ្វាយ ខេត្ត នោះ បាន សួរ ទៅព្រះយេស៊ូថា «តើអ្នកគឺជាស្តេចនៃសាសន៍យូដាឬ?» ចម្លើយរបស់ទ្រង់នៅដដែលគឺ

«*ដូចដែលអ្នកនិយាយនោះហើយ*»។ ឯពួកអាចារ្យផារិស៊ីក៏ព្យាយាមចោទប្រកាន់ទ្រង់ថែមទៀតតែព្រះគ្រិស្តមិននិយាយអ្វីមួយម៉ាត់ជាមួយពួកគេឡើយ លោកពីឡាត់មានការស្ញើចនឹងភាពស្ងៀមស្ងាត់របស់ព្រះយេស៊ូយ៉ាងក្រៃលែង។ លោកព្យាយាមនឹងរកវិធីដោះលែងព្រះយេស៊ូ ព្រោះគាត់មិនឃើញថា ព្រះយេស៊ូមានកំហុសអ្វីទេ។

កាលដែលបុណ្យរំលងមកដល់ដែលជាបុណ្យដ៏ធំសម្រាប់ជនជាតិយូដា ហើយដែលជាទំលាប់របស់លោកពីឡាត់គឺធ្វើការដោះលែងអ្នកទោសម្នាក់ទៅតាមចិត្តរបស់ប្រជាជន។ នៅឆ្នាំនេះលោកបាននាំអ្នកទោសពីរនាក់មកឱ្យប្រជាជនមួយគឺ បារ៉ាបាស ដែលជាឧក្រិដ្ឋជនហើយមួយទៀត គឺជាព្រះយេស៊ូ។ លោកបានសួរទៅពួកគេថា តើពួកគេចង់ដោះលែងអ្នកណាមួយ។ ឯប្រជាជនក៏ត្រូវបានពួកអាចារ្យ ផារិស៊ី ពង្វក់ ក៏សុំឱ្យលោកពីឡាត់ ដោះ លែងមេចោរឈ្មោះ បារ៉ាណា បាស់ ហើយព្រះយេស៊ូត្រូវយកទៅឆ្កាង។ ពេលនោះលោកពីឡាត់ក៏បានស្រែកទៅហ្វូងមនុស្សថា «តើអ្នកនេះបានធ្វើអ្វីខុស?» ចម្លើយរបស់គេគឺ «ឆ្កាងវាទៅ»។ លោកពីឡាត់មើលទៅឃើញថា លោកមិនអាចធ្វើអ្វីបានជាមួយមនុស្សទាំងនេះគាត់ក៏បាននិយាយថា «ខ្ញុំគ្មានទោស និងឈាមនៃអ្នកសុចរិតនេះទេ» នោះហ្វូងមនុស្សក៏តបថា «ឱ្យឈាមរបស់វាធ្លាក់មកលើយើង និងកូនចៅយើងចុះ»។ លោកពីឡាត់ក៏បញ្ជាឱ្យគេដោះលែងបារ៉ាបាស ហើយក៏យកព្រះយេស៊ូទៅឆ្កាង។

នៅកន្លែងកាត់ក្ដីនោះគេបានដោះសំលៀកបំពាក់របស់ទ្រង់ហើយបានយករ៉ូបពណ៌ស្វាយឱ្យទ្រង់វិញ ពួកគេបានព័ទ្ធបន្លាហើយបំពាក់នៅលើព្រះសិរសារបស់ទ្រង់។ ទាហ៊ានបានចំអកឡកឡឺយឱ្យទ្រង់ ហើយថែមទាំងស្ដោះទឹកមាត់លើទ្រង់។

បន្ទាប់ពីពួកគេបានបញ្ចប់ ហើយនោះពួកគេក៏បានពាក់សំលៀកបំពាក់របស់ទ្រង់ឱ្យទ្រង់វិញ ហើយក៏បណ្ដើរទ្រង់ទៅកូឡាកូថា ដែលមានន័យថា «ភ្នំលលាក្បាល» ហើយកន្លែងនោះ ហើយជាកន្លែងដែលគេឆ្កាងទ្រង់។

មនុស្សគ្រប់គ្នាបានដើរចេញពីកន្លែងកាត់ក្ដីនោះ គេបានបង្ខំមនុស្សម្នាក់ឈ្មោះស៊ីម៉ូនឱ្យលីឈើឆ្កាងជំនួសទ្រង់។

នៅពេលដែលគេឆ្កាងព្រះគ្រិស្តនៅលើឈើឆ្កាងទាហានបានដោះសំលៀកបំពាក់របស់ទ្រង់ហែក ហើយធ្វើឆ្នោតចាប់យកសំលៀកបំពាក់ទ្រង់ចែកគ្នា តើអ្នកណាបានអ្វីនៃសំលៀកបំពាក់របស់ទ្រង់។ ពួកគេបានឈរមើលទ្រង់សុគតពីក្រោម

ឈើឆ្កាងពួកអាចារ្យនិងសម្ដេចសង្ឃក៏បានចេញមកមើលកាលដែលព្រះគ្រិស្ដជាប់ឆ្កាង ហើយថែមទាំងពោលពាក្យឡកឡឺយថា ហេតុអីបានជាព្រះគ្រិស្ដមិនចុះពីលើឈើឆ្កាងមក។

មានមនុស្សជាច្រើនបានទៅកន្លែងដែលគេឆ្កាងទ្រង់ ហើយគ្រវីក្បាលទាំងបញ្ចោញវាចារ្យមិនសមរម្យ។ តែចោរពីរនាក់ដែលឆ្កាងនៅជិតទ្រង់មិនមានអ្នកណាចំអកឡើយ។

ប៉ុន្តែ តាំងពីថ្ងៃត្រង់រហូតដល់ម៉ោងបីរសៀលម៉ោងនោះមេឃងងឹតបាំងគ្របដណ្ដប់ទូទាំងផែនដី។ ព្រះយេស៊ូក៏បានស្រែកទៅព្រះវរបិតា «*អេលីអេលី ឡេម៉ាសាបាច់ថានីដែលមានន័យថា ឱព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជាព្រះអង្គបោះបង់ចោលទូលបង្គំដូច្នេះ*» ដោយឮទ្រង់ស្រែកដូច្នេះអ្នកមើលក៏រត់ទៅយកទឹកខ្មេះរុំ និងក្រណាត់ទៅឱ្យទ្រង់ឯអ្នកដទៃទៀតបាននិយាយថា «ទុកឱ្យវានៅម្នាក់ឯចុះ ចូរមើលប្រសិនបើលោកអេលីយ៉ាមកជួយសង្គ្រោះវាទេ» ។បន្ទាប់មកព្រះយេស៊ូក៏បានស្រែកម្ដងទៀត ហើយប្រគល់វិញ្ញាណទ្រង់ទៅឱ្យព្រះវរបិតាវិញ ។

នៅពេលដែលទ្រង់ផុតដង្ហើមនោះមានហេតុការណ៍ចម្លែក «កើតឡើងពេញទាំងទីក្រុងយេរូសាឡឹមដើម្បីបង្ហាញថា ទ្រង់គឺជាអ្នកណា។ វាំងននៅក្នុងព្រះវិហារដែលជាខណ្ឌនៃទីបរិសុទ្ធនៅក្នុងព្រះវិហារនោះបានរហែកតាំងពីលើចុះក្រោមមានរញ្ជួយដី ហើយមានផ្នូររបស់អ្នកដែលដើរតាមព្រះគ្រិស្ដមួយចំនួនបានរបើកចំហហើយអ្នកដែលស្លាប់ក្នុងផ្នូរក៏បានចេញមកដើរពេញទាំងទីក្រុងយេរូសាឡឹម។

នៅល្ងាចដែលព្រះយេស៊ូសុគតមានអ្នកមានម្នាក់ឈ្មោះយូសែបបានមកឯលោកពីឡាត ដើម្បីសុំយកសពព្រះយេស៊ូបញ្ចុះ។ លោកពីឡាត់ក៏បានយល់ព្រមរួចគេក៏យកសពព្រះយេស៊ូទៅដាក់ក្នុងផ្នូរថ្មីមួយដែលគេបានចោះភ្នំធ្វើជាផ្នូរ។ យូសែបក៏យកសពព្រះយេស៊ូ ហើយរុំនឹងក្រណាត់ស្អាតដាក់ព្រះយេស៊ូនៅក្នុងរូង ហើយយកថ្មដ៏ធំមួយផ្ទាំងមកបិទច្រកចេញ រួចគាត់ក៏ចេញទៅជាមួយនឹងម៉ារាទាំងពីរ។

# <u>សំណួរផ្ទាល់មាត់</u>

១- តើពួកអ្នកដឹកនាំជនជាតិយូដារកវិធីចោទប្រកាន់ទោសព្រះយេស៊ូនៅក្នុងផ្ទះលោកកៃផាស់យ៉ាងដូចម្ដេច?

២- តើព្រះយេស៊ូបានឆ្លើយតបទៅគ្រប់ទាំងការចោទប្រកាន់របស់ពួកគេចំពោះទ្រង់យ៉ាងម៉េច?

៣- តើលោកពីឡាត់មានប្រតិកម្មយ៉ាងណាទៅនឹងភាពស្ងៀមស្ងាត់របស់ព្រះយេស៊ូនៅចំពោះមុខអ្នកចោទប្រកាន់ទ្រង់?

៤- តើនរណាជាបារ៉ាបាស?

៥- តើទាហានរ៉ូមធ្វើយ៉ាងម៉េចខ្លះទៅលើព្រះយេស៊ូ?

៦- តើពួកអាចារ្យ និងហ្វូងមនុស្សបានធ្វើអ្វីខ្លះដល់ព្រះយេស៊ូនៅពេលដែលទ្រង់ត្រូវបានគេព្យួរនៅលើឈើឆ្កាង?

៧- តើមានអ្វីកើតឡើងនៅលើផែនដីតាំងពីថ្ងៃត្រង់រហូតដល់ម៉ោងបីរសៀល?

៨- តើព្រះយេស៊ូបានស្រែកថាម៉េចមុនពេលដែលទ្រង់បានប្រគល់ព្រលឹងរបស់ទ្រង់ទៅឱ្យព្រះវរបិតា?

៩- តើមានរឿងចម្លែកអ្វីទៅនៅពេលដែលព្រះយេស៊ូបានផុតដង្ហើម?

១០- តើលោកយ៉ូសែបបានធ្វើអ្វីជាមួយព្រះសពរបស់ព្រះគ្រិស្ដ?

# មេរៀនទី៧

# សេចក្តីពិតខាងវិញ្ញាណ

ម៉ាថាយ ២៦-២៧

ផ្លូវរបស់ព្រះមិនមែនជាផ្លូវរបស់មនុស្សទេ សូមយើងអានទាំងអស់គ្នានៅក្នុងបទគម្ពីរ ១កូរិនថូស១:១៨-២១, ២៧ សូមអានខព្រះគម្ពីរនេះចំនួនពីរទៅបីដង ដើម្បីឱ្យគ្រប់គ្នាមានពេលដើម្បីគិតអំពីអ្វីដែលព្រះគម្ពីរនេះបាននិយាយ។

*«អ្នកដែលត្រូវវិនាសអន្តរាយ ចាត់ទុកដំណឹងល្អអំពីព្រះគ្រិស្តសោយទិវង្គត់នៅលើឈើឆ្កាងថាលេលា រីឯយើងដែលកំពុងតែទទួលការសង្គ្រោះវិញ យើងជឿថាដំណឹងនេះជាឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ។ ដ្បិតមានចែងទុកមកថា «យើងនឹងរំលាយប្រាជ្ញារបស់ពួកអ្នកប្រាជ្ញ ហើយធ្វើឱ្យតំរេះរបស់ពួកអ្នកចេះដឹង រលាយសាបសូន្យទៅដែរ ។ ដូច្នេះអ្នកប្រាជ្ញបណ្ឌិត និងអ្នកដេញដោលនាសម័យនេះធ្វើអ្វីកើត បើព្រះជាម្ចាស់បានធ្វើឱ្យប្រាជ្ញារបស់លោកិយនេះ ទៅជាលេលាវិញនោះដោយប្រាជ្ញារបស់ខ្លួន មនុស្សលោកមិនស្គាល់ព្រះជាម្ចាស់ តាមអ្វីៗដែលព្រះប្រាជ្ញាញាណរបស់ព្រះអង្គ សម្តែងឱ្យគេស្គាល់នោះបានឡើយ ហេតុនេះហើយបានជាព្រះជាម្ចាស់សព្វព្រះហឫទ័យសង្គ្រោះអ្នកជឿ ដោយពាក្យប្រកាសដែលមនុស្សលោកចាត់ថាលេលានោះ។ ផ្ទុយទៅវិញព្រះជាម្ចាស់បានជ្រើសរើសអ្វីៗដែលមនុស្សលោកចាត់ទុកថាលេលាមកផ្ចាញ់ពួកអ្នកប្រាជ្ញ ព្រះអង្គបានជ្រើសរើសអ្វីៗដែលមនុស្សលោកចាត់ទុកថាខ្សោយមកផ្ចាញ់ពួកអ្នកខ្លាំងពូកែ។*

**នៅពេលដែលអ្នកមើលទៅលើជីវិតរបស់ព្រះគ្រិស្ត យើងអាចឃើញថាផ្លូវរបស់ព្រះមិនមែនជាផ្លូវរបស់យើងទេ**

*នៅពេលដែលស្តេចនៃផែនដីប្រសូត្រ គឺទ្រង់ប្រសូត្រនៅក្នុងព្រះរាជវាំង។ ប៉ុន្តែ ព្រះជាម្ចាស់បានបញ្ជូនព្រះយេស៊ូដែលជាស្តេចលើអស់ទាំងស្តេច ឱ្យមកប្រសូតក្នុងភាពក្រីក្រ។

*នៅពេលដែលមាននរណាម្នាក់បានប្រកាសនូវសារដ៏មានសារសំខាន់ ឬក៏ជាការមកដល់របស់មនុស្សដ៏សំខាន់ម្នាក់ អ្នកដែលនាំព្រះរាជសារនោះ ត្រូវតែជាអ្នកមានស្លៀកពាក់ស្អាតបាត ហើយជិះយានយន្តស្អាតៗ ។ តែព្រះបានបញ្ជូនលោកយ៉ូហានបាទីស្ទឱ្យមក ដោយស្លៀកខោអាវធ្វើពីរោមសត្វ ដើម្បីឱ្យប្រកាសពីការមកដល់របស់ព្រះយេស៊ូគ្រិស្ត នៅទីរហោស្ថានដែលមនុស្សមិនចង់ធ្វើដំណើរទៅដើម្បីស្តាប់នូវការប្រកាសនេះ។

*នៅពេលដែលស្តេចរបស់មនុស្សមានសត្រូវដែលគេងាយស្រួលកំចាត់គេនឹងកំចាត់ចោលមួយរំពេច។ ព្រះយេស៊ូត្រូវបានបញ្ជូនទៅទីរហោរស្ថានដើម្បីឱ្យរក្សល្បួង ហើយពេលនោះទ្រង់មិនទាន់បានបំផ្លាញអារក្សសាតាំងនៅឡើយទេ។

*នៅពេលដែលស្តេចនៃមនុស្ស ជ្រើសរើសយកមិត្តភ័ក្រជិតស្និទ្ធ គឺទ្រង់ជ្រើសរើសយកអ្នកណាដែលមានការអប់រំចេញពីសាលាជាន់ខ្ពស់។ មកពីគ្រួសារដែលមានស្តុកស្តម្ភ។ តែព្រះយេស៊ូបានជ្រើសរើសមនុស្សដែលមានមុខរបរធម្មតា គឺជាអ្នកនេសាទត្រី និងអ្នកទាពន្ធ។

*ស្តេចនៅលើផែនដីនេះបង្ខំឱ្យមនុស្សគោរព ហើយនឹងដាក់ទោសដល់អ្នកណាដែលប្រឆាំងនឹងទ្រង់។ តែព្រះយេស៊ូបានបង្រៀនយើងឱ្យស្រឡាញ់គ្នា។ទ្រង់បានឱ្យសិទ្ធដល់មនុស្សធ្វើការជ្រើសរើស ដើម្បីដើរតាមទ្រង់ឬបដិសេធទ្រង់។

*ស្តេចនៅលើផែនដីនេះបង្ខំឱ្យគេធ្វើការដើម្បីទ្រង់បង់ពន្ធ ហើយមានអ្នកខ្លះត្រូវបានសម្លាប់ចោលដោយសារតែក្បត់នឹងទ្រង់។ ព្រះយេស៊ូបានសុគតនៅលើឈើឆ្កាង ដោយព្រោះតែទ្រង់ចង់សងថ្លៃជំនួសបាបរបស់យើង ទ្រង់ចង់ឱ្យយើងមានសេរីភាពហើយរស់នៅអស់កល្បជាមួយទ្រង់។

*នៅពេលស្តេចផែនដីសុគត ទ្រង់ត្រូវគេយកទៅបញ្ចុះហើយបុត្ររបស់ទ្រង់ត្រូវឡើងសោយរាជបន្ត។ នៅពេលដែលព្រះយេស៊ូសុគតទ្រង់បានរស់ឡើងវិញម្តងទៀត ហើយគ្រងរាជនៅអស់កល្បជានិច្ច។

ព្រះយេសូគ្រិស្តមិនមែនជាមនុស្សទេ ទ្រង់គឺជាព្រះជាម្ចាស់ ទ្រង់គួរត្រូវបានយើងថ្វាយបង្គំលើកតម្កើង ហើយស្តាប់បង្គាប់។ ទ្រង់ស្រឡាញ់យើង ហើយចង់ឱ្យយើងបានប្រសើរឡើង ព្រះជន្មរបស់ទ្រង់នៅលើផែនដីនេះយើង មិនអាចយល់បានទេ។

ផ្លូវរបស់ព្រះជាម្ចាស់ គឺធំធេងជាងគំនិតដ៏តូចរបស់យើង ដែលអាចនឹងយល់

បានដោយប្រាជ្ញារបស់មនុស្ស។

*ព្រះគម្ពីរបានបង្រៀនយើងថា ការមួយដែលព្រះទ្រង់ចង់ឮ គឺជាការសរសើរតម្កើងពីរាស្ត្ររបស់ទ្រង់។ ការសរសើរតម្កើង គឺមានន័យថា ទូលដល់ព្រះយេស៊ូថា តើអ្នកស្រឡាញ់ទ្រង់ប៉ុណ្ណា និងស្ញប់ស្ញែងនូវការទាំងឡាយដែលទ្រង់បានធ្វើ។ ព្រះជាម្ចាស់ទ្រង់ចង់ឮសេចក្ដីស្រឡាញ់ចេញពីបេះដូងរបស់យើង គឺទ្រង់ចង់ឮថា «ទូលបង្គំស្រឡាញ់ទ្រង់ ព្រះបិតាអើយ ព្រោះទ្រង់ស្រឡាញ់ទូលបង្គំ» ឬក៏ «ទូលបង្គំសរសើរតម្កើងព្រះអង្គ ព្រោះទ្រង់ធំ និងមានអំណាចអស្ចារ្យ» នេះជាឃ្លាដែលត្រូវទូលទៅព្រះជាម្ចាស់ដោយផ្ទាល់ខ្លួនរបស់យើង។

នៅពេលដែលយើងគិតពីជីវិត និងការសុគតរបស់ព្រះយេស៊ូយើងអាចគ្រាន់តែស្ញប់ស្ញែងនូវអ្វីដែលព្រះអាទិករនៃចក្រវាឡបានធ្វើចំពោះយើង។ ទ្រង់ស្រឡាញ់យើងច្រើនជាងការដែលយើងអាចនឹងយល់បាន។ ផ្លូវរបស់ទ្រង់ធំ និងប្រសើរជាងអ្វីដែលយើងអាចយល់ទៅទៀត។ នេះជាពេលដ៏សមរម្យមួយដែលយើងអាចធ្វើការសរសើរព្រះជាម្ចាស់។

គោលបំណងដែលទ្រង់ឱ្យគេឆ្កាង គឺដើម្បីជាយញ្ញបូជាលោះបាបរបស់យើង។ ទ្រង់ត្រូវគេធ្វើទារុណកម្ម កាត់ទោស និងថ្កោលទោស ដោយសារតែអំពើបាបរបស់យើងដែលយើងបានធ្វើ។ យើងត្រូវតែអរព្រះគុណ និងសរសើរតម្កើងទ្រង់ជារៀងរាល់ថ្ងៃ ដែលទ្រង់ជាព្រះរបស់យើង និងជាអ្នកដែលសង្គ្រោះយើង។

យើងនឹងធ្វើការមួយដែលហៅថា«ការអធិស្ឋានជាប្រយោគៗ»។ ការអធិស្ឋានជាប្រយោគៗ គឺនៅពេលណាដែលគ្រប់គ្នាអធិស្ឋានប្រយោគមួយនៅក្នុងពេលមួយដោយមានគំនិតមានមកដល់ខ្លួនរបស់គេ ដែលពួកគេចង់បង្ហាញដល់ព្រះជាម្ចាស់។ សូមយើងទាំងអស់គ្នាអោនក្បាល ហើយគិតអំពីព្រះជាម្ចាស់ ពីព្រះយេស៊ូគ្រិស្តនូវអ្វីដែលទ្រង់បានធ្វើក្នុងពេលទ្រង់បំពេញបេសកកម្មនៅលើផែនដី អ្វីដែលទ្រង់បានធ្វើនៅលើឈើឆ្កាង អ្វីដែលទ្រង់បានធ្វើពេលដែលទ្រង់រស់ឡើងវិញ និងអ្វីដែលទ្រង់កំពុងធ្វើនៅក្នុងពេលនេះក្នុងជីវិតរបស់យើង។ ហើយសូមដាក់ពាក្យដែលមាននៅក្នុងអារម្មណ៍របស់យើងចំពោះព្រះជាម្ចាស់។ ឧទាហរណ៍ «ព្រះបិតាអើយ! ទូលបង្គំស្រឡាញ់ទ្រង់ ដោយទ្រង់បានសង្គ្រោះទូលបង្គំ» ហើយមនុស្សផ្សេងទៀតនិយាយថា «ព្រះបិតា! ទ្រង់ជាព្រះបិតាដែលមានសេចក្ដីសប្បុរសចំពោះទូលបង្គំ» គ្រប់គ្នាអាចធ្វើការនេះបាន ហើយគួរតែអធិស្ឋានឱ្យបានច្រើនដងតាមដែលព្រះវិញ្ញាណដឹក

នាំ។ នេះជាពេលចែកចាយជាសាធារណៈពីអ្វីដែលមាននៅក្នុងចិត្តរបស់យើង។ សូមបន្តឱ្យបានយូរតាមសេចក្តីត្រូវការ បន្ទាប់មកធ្វើការអធិស្ឋានតាមសំណូមពរ ហើយអធិស្ឋានឱ្យគ្នាទៅវិញទៅមក។

* អ្នកដឹកនាំ ចូររំលឹកសមាជិកឱ្យចាប់ផ្តើម សរសើរតម្កើងព្រះជាម្ចាស់នៅពេលដែលគេចំណាយពេលផ្ទាល់ខ្លួនជាមួយព្រះជាម្ចាស់។ សូមកុំភ្លេចសួរសមាជិកជារៀងរាល់សប្តាហ៍ តើពេលស្ងាត់របស់គេដំណើរការយ៉ាងណា។ លើកទឹកចិត្តដល់អស់អ្នកដែលកំពុងតែជួបវិបត្ត ហើយឱ្យពួកគេចែកចាយពីការដែលព្រះបានបង្ហាញពួកគេ និងការដ៏អស្ចារ្យដែលព្រះបានធ្វើចំពោះគេ។

## មេរៀនទី៨

# ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រិស្ដ

ម៉ាថាយ ២៧

*« យើងស្គាល់ច្បាស់នូវគម្រោងការដែលយើងបានគ្រោងទុក សំរាប់អ្នករាល់គ្នា ជាគម្រោងការដែលផ្ដល់សេចក្ដីសុខសាន្តដល់អ្នករាល់គ្នា គឺមិនមែនឱ្យអ្នករាល់គ្នាត្រូវវេទនានោះទេ»។ យេរេមា ២៩:១១*

<u>រំលឹក:</u>

១- ព្យាការីអេសាយបាន និយាយថាព្រះ យេស៊ូនិងត្រូវបានគេហៅថា អេម៉ាញូអែលដែលប្រែថា «ព្រះ____________________»។

២- ព្រះយេស៊ូមានព្រះបន្ទូលថា អ្នកដែលដឹងថាពេលណាទ្រង់នឹងយាងមកផែនដីវិញគឺមានតែម្នាក់ទេគឺ____________________។

៣- លោកយ៉ូហានបានធ្វើពិធីជ្រមុជទឹកដល់មនុស្សជាច្រើនដែលប្រែចិត្តអំពី________________របស់ពួកគេ។

៤- ព្រះយេស៊ូបានឆ្លើយទៅសាតាំងបីដងដោយប្រើ__________នៃ__________។

៥- ប្រសិនបើយើងចង់នៅកៀកនឹងព្រះ ដើម្បីប្រឆាំង និងអារក្សនោះយើងត្រូវតែចំណាយពេលវេលា______________ជាមួយទ្រង់______________។

៦- ព្រះយេស៊ូបានហៅយើងឱ្យក្លាយទៅជាអ្នកនេសាទ______________។

៧- ព្រះយេស៊ូបានមានព្រះបន្ទូលទៅសិស្សរបស់ទ្រង់នៅលើទូកថា កុំឱ្យ_________________________________________។

៨- ព្រះយេស៊ូបានមានព្រះទ័យអាណិតមេត្តាដល់ហ្វូងមនុស្សដោយសារតែទ្រង់បានឃើញ______________________________។

៩- ព្រះយេស៊ូបានប្រាប់ទៅអ្នកដែលដើរតាមទ្រង់ឱ្យចេញទៅនៅក្នុងព្រះនាមរបស់

ទ្រង់ហើយឱ្យឆ្លាតដូច________________ជា________________និងសុភាព ដូចជា________________________។

១០-ពេត្រុសក្បត់ព្រះគ្រិស្តដោយបាន____________________ចំនួនបីដងនៅឯទីដែលគេសួរចម្លើយព្រះយេស៊ូ។

១១- យូដាសបានបញ្ជូនព្រះយេស៊ូដោយលក់ព្រះយេស៊ូទៅឱ្យពួកអាចារ្យក្នុងតម្លៃប្រាក់____________ដួង។

១២- តើទាហានរ៉ូមបានធ្វើអ្វីខ្លះទៅលើព្រះយេស៊ូ?

១៣- ព្រះយេស៊ូ ព្រះ__________________________ដល់គ្រប់ទាំងអំពើបាបរបស់យើងនៅពេលដែលយើងធ្វើការលន់តួ។

១៤-សម្តេចសង្ឃបានមកក្រោមឈើឆ្កាងដើម្បី______________________នៅពេលដែលព្រះគ្រិស្តសុគត។

១៥- មានហេតុការណ៍ចម្លែក «ជាច្រើនកើតមានឡើងនៅពេលដែលព្រះយេស៊ូបានសុគត ដោយមានរាប់បញ្ចូលទាំងសាកសពរបស់អស់អ្នក________________ជុំវិញទីក្រុងយេរូសាឡឹម។

១៦- យ៉ូសែបមកពីអារីម៉ាធាបានយកព្រះសពរបស់ព្រះគ្រិស្តមកដាក់ក្នុង______ ________________________________________________មួយ។

នៅថ្ងៃបន្ទាប់ដែលព្រះគ្រិស្តត្រូវបានគេឆ្កាងនោះ ពួកសម្តេចសង្ឃ និងពួកអាចារ្យផារិស៊ីបានប្រជុំគ្នា ហើយក៏ទៅឯលោកពីឡាត់។ ពួកគេបានប្រាប់ទៅលោកពីឡាត់ថា ព្រះគ្រិស្តបានមានបន្ទូលទាយថា ទ្រង់នឹងរស់ឡើងវិញក្រោយពីសុគតបានបីថ្ងៃ។ ពួកគេបានសុំឱ្យមានការការពារយ៉ាងយកចិត្តទុកដាក់បំផុតក្រែងលោមាននរណាមួយមកលួចយកសពរបស់ព្រះយេស៊ូ។ នោះលោកពីឡាត់ក៏យល់ព្រមទៅនឹងសំណើររបស់ពួកគេ។ ដូច្នេះ ពួកគេក៏បានទៅឯផ្នូរ ហើយដាក់ផ្ទាំងថ្មបិទដោយមានបោះត្រានៅឯច្រកចូលទៅក្នុងផ្នូរ និងឱ្យពួកទាហាយាមនៅទីនោះទៀតផង។

នៅក្រោយថ្ងៃសម្រាកមួយថ្ងៃដែលជាថ្ងៃដំបូងនៅក្នុងសប្តាហ៍នោះម៉ារាមកពីស្រុកម៉ាដាលា និងម៉ារាមួយទៀតក៏បានត្រលប់មកឯផ្នូរ។ ប៉ុន្តែ នៅពេលដែលពួក

គេទៅដល់ទីនោះ ស្រាប់តែមានរញ្ជួយដីដ៏ធំមួយ ដែលធ្វើឱ្យថ្មដែលនៅបាំងមាត់ផ្នូរនោះបានរបើកឡើង ហើយទេវតារបស់ព្រះក៏បានអង្គុយនៅលើថ្មដែលគេបានបោះត្រាលើ។ សំលៀកបំពាក់របស់ទេវតានោះមានពណ៌សរដូចជាព្រិលដែលមើលទៅហាក់ដូចជាផ្លេកបន្ទោល។ ឯទាហានដែលបានយាមនៅមុខផ្នូរក៏ស្រឡាំងកាំងដូចជាមនុស្សស្លាប់។

ទេវតាបានប្រាប់ស្ត្រីទាំងពីរនោះកុំឱ្យខ្លាចអី ទេវតានោះបាននិយាយថា «ខ្ញុំដឹងថាអ្នកមកទីនេះ គឺដើម្បីរកព្រះយេស៊ូ ដែលត្រូវបានគេឆ្កាង ទ្រង់មិននៅទីនេះទេ ទ្រង់មានព្រះជន្មរស់ឡើងវិញដូចដែលទ្រង់បានសន្យានោះហើយ មកមើលកន្លែងដែលទ្រង់បានផ្ទុំចុះ។ ហើយចូរចេញទៅជាប្រញាប់ប្រាប់ពួកសិស្សទៅថា ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ហើយមើលទ្រង់យាងទៅឯស្រុកកាលីឡេមុនអ្នករាល់គ្នា «អ្នករាល់គ្នានឹងឃើញទ្រង់នៅទីនោះ ដូចដែលខ្ញុំបានប្រាប់អ្នករាល់គ្នាហើយ»។

ស្ត្រីទាំងពីរនាក់បានឮដូច្នេះហើយ ក៏ពេញដោយអំណរ ហើយបានរត់យ៉ាងលឿនត្រលប់ទៅឯសិស្សរបស់ព្រះយេស៊ូ។ នៅតាមផ្លូវព្រះយេស៊ូបានជួបពួកគេនិងមានបន្ទូលទៅកាន់ពួកគេថា *«ចូរមានអំណរចុះ»* នោះពួកគេក៏ឈប់ហើយចូលទៅថ្វាយបង្គំព្រះយេស៊ូ។ ព្រះយេស៊ូបានរំលឹកស្ត្រីទាំងពីរឱ្យទៅប្រាប់ពួកសិស្សឱ្យទៅជួបទ្រង់នៅឯកាលីឡេ។

នៅពេលដែលអ្នកយាមភ្ញាក់ដឹងខ្លួនវិញនោះក៏រត់ទៅក្នុងទីក្រុងដើម្បីនឹងប្រាប់ពួកសង្ឃអំពីអ្វីដែលបានកើតឡើង។ នោះពួកសង្ឃក៏បានព្រមព្រៀងគ្នាឱ្យលុយទៅពួកអ្នកយាមឱ្យដើរទៅក្នុងទីក្រុង ហើយប្រាប់ប្រជាជនថា នៅពេលដែលគេបានដេកលក់នោះមានមនុស្សមកលួចសពព្រះយេស៊ូយកទៅ។ ពួកសង្ឃក៏បានសន្យាទៀតដែរថា នឹងការពារពួកគេប្រសិនបើលោកពីឡាត់ដឹងឬក៏នៅពេលដែលពួកគេមានបញ្ហាអ្វី ពួកទាហានក៏យកលុយ ហើយបង្កើតពាក្យចចាមអារាមពាសពេញទីក្រុងយេរូសាឡឹមជាច្រើនឆ្នាំ។

ពួកសិស្សក៏បានទៅស្រុកកាលីឡេ ជាកន្លែងដែលព្រះយេស៊ូឱ្យពួកគេទៅនោះព្រះយេស៊ូក៏លេចមកឯពួកគេហើយពួកគេក៏ថ្វាយបង្គំទ្រង់ តែក៏មានសិស្សខ្លះមានការមន្ទិលសង្ស័យ។ ព្រះយេស៊ូក៏មានបន្ទូលជាចុងក្រោយទៅកាន់ពួកគេមុនពេលដែលទ្រង់យាងត្រលប់ទៅស្ថានសួគ៌វិញ ទ្រង់មានព្រះបន្ទូលថា *« ខ្ញុំបានទទួល*

*គ្រប់អំណាច ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី ។ ដូច្នេះចូរចេញទៅនាំមនុស្សគ្រប់ជាតិសាន៍ឱ្យធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកឱ្យគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ។ ត្រូវបង្រៀនគេឱ្យប្រព្រឹត្តិតាមសេចក្ដីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់ដល់អ្នករាល់គ្នា ។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក»*

## សំនួរផ្ទាល់មាត់

១- ហេតុអ្វីបានជាពួកអាចារ្យផារិស៊ីចង់ដាក់អ្នកយាមនៅឯផ្នូររបស់ព្រះយេស៊ូ?

២- តើពួកស្រ្តីនោះបានឃើញអ្វីនៅពេលដែលបានមកដល់ផ្នូរ?

៣- តើទេវតាបានប្រាប់ពួកគេយ៉ាងដូចម្ដេច?

៤- តើមានអ្វីកើតឡើងទៅលើអ្នកយាម?

៥- តើអ្នកយាមទៅណាក្រោយពេលដែលទេវតាបានលេចឡើង?

៦- តើពួកសង្ឃបានឱ្យអ្វីទៅដល់ពួកគេ?

៧- តើស្រ្តីទាំងនោះឃើញនរណានៅពេលដែលពួកគេកំពុងតែរត់ទៅឯពួកសិស្ស?

៨- តើព្រះយេស៊ូបានប្រាប់ឱ្យពួកសិស្សទៅជួបទ្រង់នៅឯណា?

៩- តើបញ្ញត្តិអ្វីដែលព្រះយេស៊ូឱ្យទៅពួកសិស្សមុនពេលដែលទ្រង់យាងត្រលប់ទៅស្ថានសួគ៌វិញ?

១០-តើព្រះយេស៊ូសន្យាថានឹងនៅជាមួយអ្នកណារហូតដល់ចុងបំផុតនៃផែនដីឬ?

# មេរៀនទី៨

# សេចក្តីពិតខាងវិញ្ញាណ

ម៉ាថាយ ២៨

១- ព្រះរាជសាររបស់ព្រះយេស៊ូ គឺសម្រាប់ចែកចាយដល់មនុស្សទាំងអស់: វាអាចព្រះកំពុងធ្វើការនៅក្នុងចិត្តរបស់លោកអ្នក កំពុងផ្តល់កម្លាំងដល់លោកអ្នក និងមានបំណងចង់ចែកចាយព្រះរាជសាររបស់ទ្រង់ដល់អ្នកផ្សេងទៀត។ មានវិធីជាច្រើនដើម្បីប្រាប់ដំណឹងល្អដល់មនុស្សដទៃ អំពីសេចក្តីស្រឡាញ់របស់ព្រះគ្រិស្ត។ វិធីដ៏ល្អមួយគឺដើម្បីនាំមនុស្សឬក៏ក្រុមនៃមនុស្សតាមរយៈរឿងនៃជីវិតរបស់ព្រះយេស៊ូ យើងអាចធ្វើរបៀបនេះតាមរយៈការប្រើសំភារៈ នៅក្នុងរយៈពេល៧សប្តាហ៍។ ចាប់តាំងពីមេរៀនទីបួន យើងបានអធិស្ឋានជាក្រុមដោយចំៗសម្រាប់នរណាម្នាក់ដែលព្រះបានដឹកនាំចិត្តរបស់អ្នក។ សង្ឃឹមថាលោកអ្នកបានមានឱកាស ដើម្បីប្រាប់មនុស្សទាំងនេះ អំពីការផ្លាស់ប្តូរដែលបានកើតមាននៅក្នុងជីវិតរបស់លោកអ្នក។ តែបើមិនមានទេ សូមធ្វើនៅក្នុងអាទិត្យនេះតែម្តង៖

- **សូមកុំទៅ** មនុស្សទាំងនេះហើយប្រាប់ពីការអាក្រក់របស់ពួកគេ ហើយថាព្រះនឹងដាក់ទោសពួកគេឱ្យធ្លាក់ទៅក្នុងបឹងភ្លើង ប្រសិនបើជាពួកគេមិនព្រមប្រែចិត្ត ។

- **សូម** អញ្ជើញពួកគេឱ្យចូលរួមការសិក្សាគម្ពីរខ្លីៗជាមួយអ្នក និងអ្នកផ្ទះរបស់គេ។ ហើយប្រាប់ពួកគេថា ពួកគេបានរៀនអំពីព្រះគម្ពីរ ហើយពួកគេកំពុងតែមានការអស្ចារ្យនៅក្នុងចិត្ត ឬក៏ប្រហែលជាគេមានការចាប់អារម្មណ៍ក្នុងការសិក្សាព្រះគម្ពីរជាមួយអ្នកអំពីជីវិតរបស់ព្រះយេស៊ូគ្រិស្តនៅក្នុងរយៈពេល៧សប្តាហ៍។

- នៅពេលដែលលោកអ្នកចេញទៅចំណាយពេលនិយាយទៅកាន់មនុស្សអំពីការដែលកំពុងតែកើតឡើងនៅក្នុងជីវិតរបស់ពួកគេ។ ចូរទៅជួបក្រុមគ្រួសាររបស់គេ ស្តាប់ពីតម្រូវការរបស់ គេអធិស្ឋានឱ្យគេ កិច្ចការរបស់គេគ្រួសាររបស់គេ ហើយសូមព្រះជាម្ចាស់ប្រទានសន្តិភាពបដល់គ្រួផ្ទះរបស់គេ។

◆ ចាប់ផ្ដើមរឿងដំបូងអំពីកំណើតរបស់ព្រះយេស៊ូ។ អនុញ្ញាតិឱ្យគេសួរសំណួរ។ ប្រសិនបើលោកអ្នកមិនដឹងចម្លើយមិនជាបញ្ហាទេ។ ប្រាប់ពួកគេថា អ្នកនឹងសួរទៅអ្នកដឹកនាំបង្រៀនព្រះគម្ពីររបស់អ្នកពីអ្វីដែលអ្នកមិនដឹង ហើយនឹងនាំចម្លើយដល់គេនៅអាទិត្យក្រោយ។

◆ **សូម**កុំស្នាក់នៅផ្ទះរបស់គេឱ្យលើសពីមួយម៉ោង។ ចូរចងចាំថា នេះជាការសិក្សាព្រះគម្ពីរខ្លីៗ។

◆ ចូរអធិស្ឋានឱ្យមនុស្សនេះជារៀងរាល់ថ្ងៃ និង គ្រួសាររបស់គេ។ សួរសមាជិកក្នុងក្រុមរបស់អ្នក ចូររួមអធិស្ឋានជាមួយអ្នកក្នុងការអធិស្ឋានដើម្បីពួកគេ។

**ចូរចងចាំថា៖** យើងមិនមានអំណាច និងប្រោសជំងឺឬក៏ដេញអារក្សចេញពីនរណាម្នាក់ទេ ហើយយើងក៏គ្មានអំណាចនឹងបញ្ចុះបញ្ចូលអ្នកដទៃឱ្យ គេទទួលជឿព្រះយេស៊ូគ្រិស្តបានដែរ។ អ្នកដែលមានអំណាច គឺជាព្រះវិញ្ញាណបរិសុទ្ធដែលរស់នៅក្នុងយើង។ ទ្រង់មានអំណាចដើម្បីប្រោសមនុស្សឱ្យជាពីជំងឺរបស់ពួកគេហើយទ្រង់មានអំណាចដេញអារក្សសាតាំងចេញពីមនុស្ស ហើយទ្រង់ជាអ្នកដែលបំបាក់ច្រវ៉ាក់នៃអំពើបាបនៅក្នុងជីវិតរបស់មនុស្ស ហើយនាំពួកគេឱ្យធ្វើការប្រែចិត្តចូលមកឯព្រះគ្រិស្ត។ ការទទួលខុសត្រូវរបស់យើង គឺចែកចាយ និងអធិស្ឋាន។

ប្រហែលជាអាចថា អ្នកនៅក្នុងស្ថានភាពដែលអ្នកមិនមានឱកាស ដើម្បីធ្វើទាំង៧សប្តាហ៍ក្នុងការបង្រៀនព្រះគម្ពីរជាមួយមនុស្សនេះ តែអ្នកចង់ចែកចាយដល់ពួកគេអំពីព្រះយេស៊ូ។

## អ្វីដែលត្រូវធ្វើ

● ប្រាប់ពួកគេ អំពីរឿងរបស់ព្រះយេស៊ូតាមដែលអ្នកអាចចាំបាន។ ប្រាប់ពួកគេអំពីកំណើតរបស់ទ្រង់ ជីវិតរបស់ទ្រង់ ការអស្ចារ្យដែលទ្រង់បានធ្វើ ព្រះរាជសារនៃការប្រែចិត្ត ការបញ្ចូនទ្រង់ ការសុគត និងការរស់ឡើងវិញរបស់ទ្រង់។

● ប្រាប់ពួកគេថាមនុស្សនៅក្នុងសម័យរបស់ព្រះយេស៊ូ គឺយើងបានធ្វើខុសនៅចំពោះព្រះជាម្ចាស់ ទោះបីយើងជាមនុស្សល្អយ៉ាងណាក៏ដោយ នេះមានន័យថាយើងទាំងអស់គ្នាបានធ្វើបាប។ លើកឧទាហរណ៍ពីអំពើបាបខ្លះៗឱ្យគេយល់ដូចជាការកុហក ការលួច ការស្អប់គ្នា ការច្រណែន ការកំផិត។ល។

● ប្រាប់ពួកគេថា ព្រះជាម្ចាស់បានអត់ទោសឱ្យមនុស្សនៅក្នុងព្រះគម្ពីរហើយ

ទ្រង់ក៏អភ័យទោសឱ្យលោកអ្នក ប្រសិនបើជាលោកអ្នកកែប្រែចិត្តចេញពីអំពើបាបរបស់លោកអ្នក។

● ពន្យល់ គេ បន្តិច អំពី ជីវិត របស់ លោក អ្នក មុន ពេល ដែល លោក អ្នក ជឿព្រះយេស៊ូ ហើយជីវិតរបស់លោកអ្នកមុនជឿព្រះយេស៊ូគ្រិស្ត (ទីបន្ទាល់របស់លោកអ្នក)។

● អាន ឬក៏ និទានរឿងប្រាប់ នៅខមួយដែលសំខាន់ជាងគេក្នុង ព្រះគម្ពីរ យ៉ូហាន៣:១៦ ដែលនិយាយថា «ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះ ហើយ បានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីឱ្យអស់អ្នកណាដែលជឿលើព្រះបុត្រាមានជីវិតអស់កល្បជានិច្ច គឺមិនឱ្យគេវិនាសឡើយ»។

● សួរមនុស្សនោះ ប្រសិនបើជាគេចង់ប្រែចិត្តចេញពីអំពើបាបរបស់ពួកគេ ជឿលើព្រះយេស៊ូ ហើយទទួលការអភ័យទោសដែលទ្រង់អាចផ្តល់ដល់ពួកគេ។

● ពន្យល់គេថាការជឿគឺមានន័យថា ប្រគល់ជីវិតអ្នកទាំងអស់ដល់ព្រះយេស៊ូគ្រិស្ត។ នេះគឺបានន័យថាទុកចិត្តដល់ព្រះអង្គ ហើយថ្វាយជីវិតអ្នកដល់ទ្រង់។

● ប្រសិនគេយល់ព្រម សូមជួយគេអធិស្ឋាន គឺអធិស្ឋានធម្មតាៗដោយប្រគល់ជីវិតរបស់គេទៅព្រះជាម្ចាស់។

● ប្រសិន បើ ជា គេ បដិសេធ សូម គេ ប្រសិន បើ គេ អនុញ្ញាតិ ឱ្យ លោក អ្នក អធិស្ឋានសម្រាប់គេនៅក្នុងពេលនេះ ហើយអធិស្ឋានទៅព្រះដែលទ្រង់អាចជួយគេ ដើម្បីឱ្យយល់ពីសេចក្តីពិតនៅក្នុងជីវិតរបស់ពួកគេ។

** សូម សម្រាក ហើយ ចំណាយ ពេល ជា ក្រុម ដើម្បី អនុវត្ត ចែក ចាយ ពី ព្រះយេស៊ូ ដល់មនុស្សដទៃ ។ ចែកគ្នាជាមួយមួយគូរៗ ហើយឱ្យ មនុស្ស ម្នាក់ៗ និយាយប្រាប់គ្នាទៅវិញទៅមក។*

បន្ទាប់ពីបានអនុវត្តហើយ លោកអ្នកប្រហែលជាគិតថា «នេះវាមិនអាចទៅរួចទេ ខ្ញុំមិនអាចប្រាប់អ្នកណាទៀតពីព្រះយេស៊ូបានទេ» សូមគិតពិចារណាពីសេចក្តីពិតចុងក្រោយនៅក្នុងការសិក្សានេះ។

២- <u>«ហើយខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសាននៃពិភពលោក</u>»: ព្រះគម្ពីរបានបង្រៀនយើងថា នៅពេលណាដែលយើងទទួលព្រះយេស៊ូ

គ្រិស្ត ព្រះវិញ្ញាណបរិសុទ្ធនៃព្រះយាងមក ហើយគង់នៅក្នុងជីវិតយើង។ ប្រហែលជាអ្នកមិនទុកចិត្តលើការនោះ ប៉ុន្តែទ្រង់បានធ្វើការនៅក្នុង ជីវិតរបស់យើងរួចមកហើយ (យ៉ូហាន ១៤:៧)។

◆ ទ្រង់គឺជាអ្នកដែលបង្រៀនយើងនៅពេលដែលយើង ប្រើពេលតែម្នាក់ឯងជាមួយទ្រង់ជារៀងរាល់ថ្ងៃ (យ៉ូហាន ១៤:៦)។

◆ ទ្រង់ជាអ្នកធ្វើឱ្យយើងមានអារម្មណ៍ពិបាកចិត្ត នៅពេលដែលយើងមិនស្តាប់បង្គាប់ព្រះ។ ទ្រង់ជាអ្នកជួយឱ្យយើងដឹងនូវអំពើបាបដែលយើងបានធ្វើកាលពីមុន ហើយត្រូវការព្រះគ្រិស្តអត់ទោសបាបនៅក្នុងជីវិតរបស់យើង(យ៉ូហាន១៦:៨-១១)។

◆ ទ្រង់ជាអ្នកប្រទានប្រាជ្ញាដល់យើង ហើយដឹកនាំយើងឱ្យរស់ទៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង (យ៉ូហាន ១៦:១៣)។

◆ ទ្រង់ជាអ្នកលួងលោមកំសាន្តចិត្តយើងនៅពេលណាដែលយើងពិបាកចិត្ត (កិច្ចការ ៩:១៣)។

◆ ទ្រង់ប្រទានអំណាចដល់យើងជាមួយអំណោយទានដ៏វិសេស ដើម្បីឱ្យយើងអាចធ្វើកិច្ចកាដែលយើងមិនធ្លាប់ស្រមៃថាយើងអាចធ្វើទៅបាន។ ទ្រង់បានប្រទានពាក្យដល់យើង ដើម្បីប្រាប់អ្នកផ្សេងអំពីព្រះយេស៊ូគ្រិស្ត (១កូរិនថូស១២)

យើងប្រហែលជាគិតថា យើងមិនអាចក្លាយដូចជាអ្នកដែលដើរតាមព្រះយេស៊ូគ្រិស្ត ដូចដែលទ្រង់ចង់ឱ្យយើងធ្វើនោះទេ។ យើងប្រហែលជាគិតថា ការស្តាប់បង្គាប់ព្រះគឺពិបាកណាស់។ សេចក្តីពិតគឺជាសេចក្តីពិត យើងមិនអាចធ្វើទាំងអស់ដើម្បីដើរតាមព្រះយេស៊ូគ្រិស្តទេ ប៉ុន្តែ ព្រះជាអ្នកធ្វើការនោះតាមរយៈព្រះវិញ្ញាណដែលគង់នៅក្នុងជីវិតរបស់យើង។

នេះជាការសម្ងាត់ ដើម្បីប្រាប់អ្នកផ្សេងអំពីព្រះយេស៊ូគ្រិស្ត វាគឺជាការសម្ងាត់ដែលរស់នៅដោយគ្មានការភ័យខ្លាច។ គឺជាការសម្ងាត់នៃការធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវជារៀងរាល់ថ្ងៃ។ នៅពេលដែលយើងអនុញ្ញាតិឱ្យអ្នកដែលបង្កើតចក្រវាឡមករស់នៅក្នុងជីវិតរបស់យើងទ្រង់បានប្រទានអំណោយទាន គឺជាព្រះវត្តមាននៅជាមួយយើងជារៀងរហូត។ ព្រះវត្តមាននៃព្រះវិញ្ញាណបរិសុទ្ធ គឺជាប្រភពនៃកម្លាំង និងអំណាចរបស់យើង។ នេះគឺជាការរំភើបមួយ ព្រោះព្រះគម្ពីរបានបង្រៀនយើងថា ព្រះមានផែនការដ៏ពិសេស។ គំនិតដែលមិនគួរឱ្យជឿ ហើយនិងគោលបំណងដ៏

ប្រពៃសម្រាប់ជីវិតរបស់យើងគ្រប់ៗគ្នា។

សូមឱ្យយើងបញ្ចប់ការសិក្សានេះជាមួយ ការសន្យាដ៏ពិសេសដែលយើងអាចរកឃើញនៅក្នុងកណ្ឌគម្ពីរយេរេមា ២៩:១១-១៣។

*«យើងស្គាល់ច្បាស់នូវគម្រោងការដែលយើងបានគ្រោងទុក សម្រាប់អ្នករាល់គ្នា ជាគម្រោងការដែលផ្ដល់សេចក្តីសុខសាន្តដល់អ្នករាល់គ្នាគឺមិនមែនឱ្យអ្នករាល់គ្នាត្រូវវេទនាទេ។ យើងនឹងផ្ដល់សេចក្តីសង្ឃឹម និងអនាគតល្អឱ្យអ្នករាល់គ្នានេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ ។ ពេលនោះអ្នករាល់គ្នានឹងអធិស្ឋាន អ្នករាល់គ្នានឹងធ្វើដំណើរទៅទូលអង្វរយើង ហើយយើងនឹងឆ្លើយតមមកអ្នករាល់គ្នាវិញ ។ អ្នករាល់គ្នាស្វែងរកយើង ហើយនឹងជួបយើងមិនខាន ព្រោះអ្នករាល់គ្នាស្វែងរកយើងដោយចិត្តស្មោះ។*

# កំណត់ចំណាំ